សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
មហាវិទ្យាល័យអប់រំ
កម្មវិធីលើកកម្ពស់គុណវុឌ្ឍិគណៈគ្រប់គ្រងសាលារៀន កម្រិតបរិញ្ញាបត្រ



# មុខវិជ្ជា៖
# ការគ្រប់គ្រងការរៀន និងបង្រៀន

## កញ្ចប់សមត្ថភាពទី១
## ចំណេះដឹងឯកទេសបរិញ្ញាបត្រ

# មុខវិជ្ជាៈ
# ការគ្រប់គ្រងការរៀន និងបង្រៀន

## កញ្ចប់សមត្ថភាពទី ១
## ចំណេះដឹងឯកទេសកម្រិតបរិញ្ញាបត្រ

## ការពណ៌នាអំពីមុខវិជ្ជា

មុខវិជ្ជានេះត្រូវបានរៀបចំឡើងដើម្បីឲ្យនិស្សិតស្វែងយល់អំពី ទ្រឹស្តីការប៉ះទង្គិចអារម្មណ៍នៅក្រោយសង្គ្រាម ការឆ្លុះបញ្ចាំងអត្តចរិត និងចរិយាបស់ខ្លួនក្នុងជីវិតនិងការងារ ការសិក្សាពីឥទ្ធិពលនៃជីវិត និងគ្រួសារសិស្សលើការរៀនសូត្រ រៀនសូត្រនូវវិធីនាំខ្លួនឲ្យក្លាយជាមនុស្សល្អ ។ ការទទួលស្គាល់ការពិតនៃជីវិត និងការងាររបស់មនុស្សម្នាក់ៗ ការស្វែងយល់អំពីការប៉ះទង្គិចផ្លូវអារម្មណ៍ និងការកែប្រែជីវិតការងាររបស់ខ្លួន ដើម្បីសិស្ស និងសហគមន៍ដែលនិស្សិតស្ថិតនៅ បទបពិសោធក្នុងការជួយខ្លួនឯង គ្រួសារ និងកូនរបស់ខ្លួន និងសិស្ស ក្នុងការកសាងសមត្ថភាពរស់មួយជីវិតដែលល្អ និងអនាគត់គេអាចថែទាំគ្រួសារបាន និងកូនរបស់គេបាននៅពេលក្លាយជាមាតិបិតារបស់គេ ។

**លទ្ធផលសិក្សារំពឹងទុក៖**

*ក្រោយពីបញ្ចប់ការសិក្សាមុខវិជ្ជានេះដោយជោគជ័យអ្នកសិក្សានឹង៖*

លទ្ធផលសិក្សារំពឹងទុក១៖ បរិយាយអំពីទ្រឹស្តីការប៉ះទង្គិចអារម្មណ៍នៅក្រោយសង្គ្រាម

លទ្ធផលសិក្សារំពឹងទុក២៖ បរិយាយអំពីការឆ្លុះបញ្ចាំងពីអត្តចរិត និងចរិយារបស់ខ្លួនក្នុងជីវិតនិងការងារ

លទ្ធផលសិក្សារំពឹងទុក៣៖ ដឹងពីឥទ្ធិពលនៃជីវិត និងគ្រួសារសិស្សលើការរៀនសូត្រ

លទ្ធផលសិក្សារំពឹងទុក៤៖ រៀនសូត្រនូវវិធីនាំខ្លួនឲ្យក្លាយជាមនុស្សល្អ។

លទ្ធផលសិក្សារំពឹងទុក៥៖ បកស្រាយនិងប្រើប្រាស់ទ្រឹស្តីប៉ះទង្គិចអារម្មណ៍នៅក្នុងសកម្មភាពនៃការបង្រៀននិងរៀនពិតប្រាកដនៅក្នុងថ្នាក់រៀន។

**វាយតម្លៃសិក្សា**

*ដើម្បីបំពេញគ្រប់លក្ខខណ្ឌបញ្ចប់ការសិក្សាមុខវិជ្ជានេះ អ្នកសិក្សាត្រូវ*

១. វត្តមានចូលសិក្សា ១០%

២. ការចូលរួមសកម្មភាពសិក្សា ២០%

៣. ការវាយតម្លៃកំឡុងពេលសិក្សា ៣០%

៤. ការប្រឡងបញ្ចប់មុខវិជ្ជាសិក្សា ៤០%

# អារម្ភកថា

ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៦ នៃរដ្ឋសភា យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ក្នុងចំណុចចតុកោណទី១ បានកំណត់យក "ការអភិវឌ្ឍធនធានមនុស្ស" មុំទី១ជាវិស័យអាទិភាព។ សាកលវិទ្យាល័យ-ភូមិន្ទភ្នំពេញដើរតួនាទីយ៉ាងសំខាន់ជាចំណែកមួយនៃការកែទម្រង់វិស័យអប់រំក្នុងការស្តារប្រព័ន្ធអប់រំជាតិឡើងវិញ តាមរយៈការផលិតអ្នកអប់រំដែលមានគុណភាពខ្ពស់។

នៅដើមអាណត្តិទី៦នេះ ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវយុទ្ធសាស្ត្រកំណែទម្រង់ វិស័យអប់រំ ២០១៨-២០២៣ ដែលមានចក្ខុវិស័យ "កសាង និងអភិវឌ្ឍន៍ធនធានមនុស្សប្រកបដោយគុណភាព និងគុណធម៌ប្រសើរបំផុតលើគ្រប់ផ្នែក ដើម្បីកសាងសង្គមកម្ពុជាឱ្យក្លាយជាសង្គមរីកចម្រើនផ្អែកចំណេះដឹង និងចំណេះធ្វើជាមូលដ្ឋាន"។ ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ក៏បានលើកឡើងពីតួនាទីយ៉ាងសំខាន់របស់គ្រូបង្រៀនក្នុងវិស័យអប់រំ និងសង្គមជាតិ ដោយបញ្ជាក់ថា "គុណភាពគ្រូ ជាគុណភាពមូលធនមនុស្ស សម្រាប់ ការអភិវឌ្ឍប្រកបដោយចីរភាព" ដែលប្រែក្លាយប្រទេសមានប្រាក់ចំណូល មធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ២០៣០ និងប្រទេសអភិវឌ្ឍន៍ក្នុងឆ្នាំ២០៥០។

ដើម្បីឆ្លើយតបនឹងផែនការយុទ្ធសាស្ត្រ និងចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា រួមជាមួយនឹងកំណែទម្រង់របស់ក្រសួងអប់រំ យុវជន និងកីឡា សាកលវិទ្យាល័យភូមិន្ទភ្នំពេញបានទទួលភារកិច្ចបន្ថែមទៀត តាមរយៈការអនុវត្តគម្រោងកែលម្អការអប់រំនៅកម្រិតមធ្យមសិក្សា និងបន្តអនុវត្តគម្រោងកែលម្អការអប់រំចំណេះទូទៅរយៈពេលបួនឆ្នាំបន្តទៀត ចាប់ពីឆ្នាំ២០២២-២០២៦។ ឯកឧត្តមបណ្ឌិតសភាចារ្យ **ណាត ប៊ុនរឿន** រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា និងជាប្រធានគម្រោងកែលម្អការអប់រំនៅមធ្យមសិក្សាបានដឹកនាំ និងផ្តល់អនុសាសន៍យ៉ាងច្រើន ដែលធ្វើឱ្យគម្រោងប្រព្រឹត្តទៅដោយរលូន និង ជោគជ័យ។

គម្រោងកែលម្អការអប់រំនៅមធ្យមសិក្សារៀបចំឡើង ដើម្បីលើកកម្ពស់គុណវុឌ្ឍិគ្រូឯកទេសលើមុខវិជ្ជាគោល៦ តាមគ្រឹះស្ថានមធ្យមសិក្សាគោលដៅ។ សាកលវិទ្យាល័យភូមិន្ទភ្នំពេញទទួលបណ្តុះបណ្តាលក្របខណ្ឌកម្មវិធីកម្រិតបរិញ្ញាបត្រអប់រំដល់នាយកសាលារៀន និងគ្រូឯកទេសដែលពុំទាន់មានសញ្ញាបត្របរិញ្ញាបត្រ ឬមានសញ្ញាបត្រខុសឯកទេស នៅតាមគ្រឹះស្ថានមធ្យមសិក្សាចំនួន១០០ នៅក្នុងគោលដៅគម្រោងនៅប្រទេសកម្ពុជា។ ដើម្បីពង្រីកវិសាលភាពនៃកំណែទម្រង់អប់រំ គម្រោងកែលម្អការអប់រំចំណេះទូទៅ ដែលប្រើប្រាស់យុទ្ធសាស្ត្រសហគមន៍សាលារៀនជាយុទ្ធសាស្ត្រស្នូលក្នុងការអនុវត្ត បានលេចរូបរាងឡើងក្នុងគោលបំណងបណ្តុះបណ្តាលនាយកសាលា និងគ្រូបង្រៀនចំនួនប្រមាណ ១៧០០០ នាក់ ដែលមកពី ១៧០០សាលា ក្នុងអនុវិស័យបី រួមមាន កុមារតូច បឋមសិក្សា និងមធ្យមសិក្សា។ មហាវិទ្យាល័យអប់រំក៏ត្រូវសហការផងដែរ ជាមួយស្ថាប័ន បណ្តុះបណ្តាលគ្រូទាំងអស់ ដើម្បីឈានទៅបង្កើតស្តង់ដាគុណភាពរួមមួយក្នុងការអប់រំគ្រូបង្រៀន និងគណៈគ្រប់គ្រងសាលាឱ្យបានទូលំទូលាយ។ ដើម្បីឈានទៅសម្រេចបានការអនុវត្តគម្រោងថ្មីនេះ មហាវិទ្យាល័យត្រូវមានយុទ្ធសាស្ត្ររយៈពេលវែងមួយ សម្រាប់ឆ្នាំ ២០២១-២០៣០ ដើម្បីជាមគ្គុទេសបង្ហាញផ្លូវ។

សៀវភៅសិក្សាគោលយុទ្ធសាស្ត្រសហគមន៍សាលារៀននេះ បានរៀបចំឡើងជាការឆ្លើយតបជាមួយតម្រូវការដែលអ្នកសិក្សាជានាយក និងគ្រូបង្រៀនក្នុងគម្រោងកែលម្អការអប់រំចំណេះទូទៅដើម្បីធ្វើការស្វ័យសិក្សាលើខ្លឹមសារសំខាន់ៗ នៃយុទ្ធសាស្ត្រសហគមន៍សាលារៀន ដែលការស្វ័យសិក្សានេះបានភ្ជាប់មកជាមួយសំណួរស្វ័យសិក្សា ដែល

បញ្ជាក់ពីកម្រិតយល់ដឹងពីខ្លឹមសារគោលនីមួយៗនៃយុទ្ធសាស្ត្រសហគមន៍សាលារៀន។ តាមរយៈសៀវភៅសិក្សាគោលនេះ អ្នកសិក្សាក្នុងគម្រោងកែលម្អការអប់រំចំណេះទូទៅ (GEIP) និងគ្រឹះស្ថានបណ្តុះបណ្តាលឯទៀតអាចយកជាប្រយោជន៍ក្នុងការអនុវត្តកំណែទម្រង់សាលារៀន ដែលយកសហគមន៍ជាធនធានគោល ដើម្បីអភិវឌ្ឍន៍សាលារៀនឱ្យឈានទៅរកសាលារៀនជាប់ស្តង់ដាសហគមន៍សាលារៀន។

ទន្ទឹមនឹងនេះ វាជាឯកសារដែលឆ្លុះបញ្ចាំងពីមេរៀន បទពិសោធន៍នៃការអនុវត្ត និងផលសម្រេចជាក់ស្តែង និងជាឯកសាររស់ដែលមានលក្ខណៈបើកទូលាយឱ្យមានការកែលម្អបន្តផ្អែកលើការរៀនពីការអនុវត្ត ដែលនាំមកនូវលទ្ធផលវិជ្ជមាន។ ឯកសារនេះមានខ្លឹមសារ ដែលជាអត្ថប្រយោជន៍សម្រាប់ប្រើប្រាស់ក្នុងពេល ដែលបានអនុវត្តន៍កន្លងមក និងបន្តប្រើប្រាស់ក្នុងពេលបច្ចុប្បន្ន ហើយអាចនឹងប្រើប្រាស់សម្រាប់អនាគត ឬអាចនឹងកែសម្រួលបន្ថែមឱ្យសមស្របតាមកាលៈទេសៈ និងល្បឿននៃការអភិវឌ្ឍក្នុងសង្គមជាតិ។

សាកលវិទ្យាល័យភូមិន្ទភ្នំពេញមានជំនឿយ៉ាងមុតមាំ ក្នុងការរៀបចំក្របខណ្ឌកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន ក្រោមគម្រោងកែលម្អការអប់រំនៅមធ្យមសិក្សាពិតជាដើរតួនាទីយ៉ាងសំខាន់ និងឆ្លើយតបទៅនឹងចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា និងបេសកកម្មរបស់ក្រសួងអប់រំ យុវជន និងកីឡាក្នុងការសាងធនធានមនុស្សប្រកបដោយគុណភាព សមត្ថភាព និងក្រមសីលធម៌។ យើងនឹងបន្តការខិតខំប្រឹងប្រែងក្នុងការអនុវត្តគម្រោងកែលម្អការអប់រំចំណេះទូទៅ (GEIP) ឱ្យបានកាន់តែប្រសើរជាមួយនឹងសៀវភៅសិក្សាគោលយុទ្ធសាស្ត្រសហគមន៍សាលារៀន និងឧត្តមានុវត្តន៍ផ្សេងៗដែលបានចងក្រង។

ខ្ញុំសូមថ្លែងអំណរគុណ និងសូមកោតសរសើរចំពោះក្រុមការងារដែលបានខិតខំកសាងក្របខណ្ឌកម្មវិធីឱ្យទទួលបានលទ្ធផលល្អ។

ថ្ងៃ ពុធ ១៤ រោច ខែ ទុតិយាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ កក្កដា ឆ្នាំ២០២២
**សាកលវិទ្យាធិការ**

**បណ្ឌិត ជេត ចាលី**

## រចនាសម្ព័ន្ធកម្មវិធីសិក្សា

កម្មវិធីសិក្សាកម្រិតបរិញ្ញាបត្រអប់រំមានចំនួន ៦៣ ក្រេឌីត ដោយបញ្ចូលការសិក្សាលើមុខវិជ្ជាសិក្សា ការចូលរួមវគ្គសិក្ខាសាលាជាបន្តបន្ទាប់ ការអនុវត្តផ្ទាល់ និងការចងក្រងរបាយការណ៍ស្រាវជ្រាវ។ ដោយសារអ្នកសិក្សាក្នុង កម្មវិធីលើកកម្ពស់គុណវុឌ្ឍិគណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀនបានបំពេញគុណវុឌ្ឍិចំនួន ៦៣ ក្រេឌីត។ (១)ចំណេះដឹងឯកទេសកម្រិតបរិញ្ញាបត្រ (៣៦ ក្រេឌីត) (២)ចំណេះដឹងវិធីសាស្ត្រដឹកនាំ និងការគ្រប់គ្រងតាមសាលារៀន (១២ (+៣) ក្រេឌីត) (៣)ហ្វឹកហាត់កម្មសិក្សា និងការអនុវត្តជាក់ស្តែង (១២ ក្រេឌីត)។

ការចូលរួមសិក្ខាសាលាតម្រូវឱ្យនិស្សិត/អ្នកសិក្សារៀនបន្ថែម និងចែករំលែកបទពិសោធអំពីការអនុវត្តការងារនៅសាលារៀន។ ការអនុវត្តផ្ទាល់ គឺភ្ជាប់និស្សិត/អ្នកសិក្សាទៅនឹងការបំពេញកិច្ចការអនុវត្ត ដើម្បីចងក្រងបទពិសោធនៃការបំពេញការងារផ្អែកលើលទ្ធផល។ របាយការណ៍ស្រាវជ្រាវតម្រូវឱ្យនិស្សិត/អ្នកសិក្សាចងក្រងនូវបទពិសោធដែលអនុវត្តការងារប្រកបដោយផលសម្រេច។

| កញ្ចប់សមត្ថភាព | ចំនួនមុខវិជ្ជា | ចំនួនក្រេឌីត |
|---|---|---|
| (១)ចំណេះដឹងឯកទេសកម្រិតបរិញ្ញាបត្រ (៦០%) | ១២ មុខវិជ្ជា | ៣៦ |
| (២)ចំណេះដឹងវិធីសាស្ត្រដឹកនាំ និងការគ្រប់គ្រងតាមសាលារៀន (២០%) | ៤(+១) មុខវិជ្ជា | ១២ (+៣) |
| (៣)ហ្វឹកហាត់កម្មសិក្សានិងការអនុវត្តជាក់ស្តែង (២០%) | ៣ មុខវិជ្ជា | ១២ |
| សរុប | ២០ | ៦៣ |

## ក្របខណ្ឌកម្មវិធីសិក្សាបរិញ្ញាបត្រអប់រំ

មុខវិជ្ជាសិក្សាសម្រាប់កម្រិតបរិញ្ញាបត្រអប់រំនេះនឹងជួយឱ្យនិស្សិត/អ្នកសិក្សាបំពេញកញ្ចប់សមត្ថភាពដូចខាងក្រោមដើម្បីឆ្លើយតបនឹងលទ្ធផលសិក្សាកម្មវិធីអប់រំហើយឱ្យនិស្សិត/អ្នកសិក្សាមានសមត្ថភាពសម្រាប់បំពេញការងារប្រកបដោយវិជ្ជាជីវៈ។

| កញ្ចប់សមត្ថភាព | មុខវិជ្ជាសិក្សា | ចំនួនក្រេឌីត |
|---|---|---|
| (១)ចំណេះដឹងឯកទេសកម្រិតបរិញ្ញាបត្រ ៣៦ ក្រេឌីត(៦០%) | ចិត្តវិទ្យាអប់រំ | ៣ |
| | មូលដ្ឋានគ្រឹះអប់រំ | ៣ |
| | ការប្រើប្រាស់កុំព្យូទ័រ និងបច្ចេកវិទ្យាឌីជីថលសម្រាប់ការអប់រំ | ៣ |
| | ភាសាអង់គ្លេសសម្រាប់ការអប់រំ | ៣ |
| | មូលដ្ឋានគ្រឹះនៃវង្វាយតម្លៃអប់រំ | ៣ |
| | មូលដ្ឋានគ្រឹះការស្រាវជ្រាវប្រែតិបត្តិ | ៣ |
| | វិធីសាស្ត្រស្រាវជ្រាវ | ៣ |
| | ការគ្រប់គ្រងការរៀន និងបង្រៀន | ៣ |

| | | |
|---|---|---|
| | ភាពជាអ្នកដឹកនាំក្នុងការគ្រប់គ្រងសាលារៀននិងរដ្ឋបាលសាលារៀន | ៣ |
| | ការសិក្សាពហុវិន័យនៅមធ្យមសិក្សា | ៣ |
| | ការអប់រំអំពីបម្រែបម្រួលអាកាសធាតុនៅមធ្យមសិក្សា | ៣ |
| | បញ្ញត្តិ និងគោលការណ៍ការអនុវត្តការគ្រប់គ្រងតាមសាលារៀន | ៣ |
| (២)ចំណេះដឹងវិធីសាស្ត្រដឹកនាំ និងការគ្រប់គ្រងតាមសាលារៀន ១២ (+៣) ក្រេឌីត (២០%) | ការគ្រប់គ្រង និងការវិភាគទិន្នន័យអប់រំ | ៣ |
| | ការគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់ការអប់រំ | ៣ |
| | ការគ្រប់គ្រង និងការអភិវឌ្ឍសមត្ថភាពបុគ្គលិកអប់រំ | ៣ |
| | ដំណើរការ ការគ្រប់គ្រងសាលារៀននៅមធ្យមសិក្សា | ៣ |
| | ការអនុវត្តយុទ្ធសាស្ត្រសហគមន៍សាលារៀនសម្រាប់មធ្យមសិក្សា | ៣ |
| (៣)ហ្វឹកហាត់កម្មសិក្សា និងការអនុវត្តជាក់ស្តែង ១២ ក្រឌីត (២០%) | ការពិនិត្យតាមដាន និងការវាយតម្លៃគ្រឹះស្ថានសិក្សា | ៣ |
| | ការធ្វើអធិការផ្ទៃក្នុងតាមសាលារៀន | ៣ |
| | ការសរសេររបាយការណ៍ស្រាវជ្រាវ | ៦ |
| សរុប | | ៦៣ |

## លំហូរបង្រៀន និងរៀន

**លំហូរបង្រៀននិងរៀន ១មេរៀន ឬកិច្ចការមួយ រួមជាមួយបំណិនមួយ និងចរិយាមួយ**



## ស្តង់ដាស្តង់ដាគណៈគ្រប់គ្រងសាលារៀននៃយុទ្ធសាស្ត្រសហគមន៍សាលារៀន

**ស្តង់ដាទី១ និង ៤** សាលារៀនដំណើរការសម្រាប់ផលសម្រេចការអប់រំនិងការសិក្សារបស់សិស្ស និងដំណើរការរដ្ឋបាល និងប្រតិបត្តិការសហគមន៍សាលារៀន។ក្នុងការបណ្តុះបណ្តាលលើកកម្ពស់គុណវុឌ្ឍិគណៈគ្រប់គ្រងសាលារៀន គណៈគ្រប់គ្រងសាលារៀនទាំងអស់ត្រូវបានណែនាំឱ្យអនុវត្តកិច្ចការដូចតទៅៈ

| | |
|---|---|
| ១ | កែលម្អការសិក្សារៀនសូត្ររបស់សិស្សពីថ្នាក់ទី៧ ដល់ទី១២ នាំឱ្យសិស្សអាចទទួលបានកម្រិតល្អ និងល្អប្រសើរលើមុខវិជ្ជាគោល។ |
| ២ | ផ្តោតការសិក្សារបស់សិស្សលើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យាជាអទិភាព ពិសេសនៅមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សា។ |
| ៣ | អនុវត្តអនុសាសន៍របាយការណ៍ការគ្រប់គ្រងហិរញ្ញវត្ថុ និងសវនកម្ម។ |
| ៤ | ធ្វើឱ្យការសិក្សាមានភាពបន្សុីគ្នារវាងសាលាមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សាដើម្បីឈានឆ្ពោះទៅឧត្តមសិក្សា។ |
| ៥ | បង្កើនប្រសិទ្ធផល និងកំណត់មុខសញ្ញាប្រើប្រាស់ធនធាន ដោយផ្តោតលើអទិភាពរបស់សាលារៀនដែលមានមូលដ្ឋានលើយុទ្ធសាស្ត្រ វប្បធម៌ និងគុណតម្លៃ។ |

## ការវាយតម្លៃលើការសិក្សា

ការវាយតម្លៃលើការសិក្សារបស់និស្សិត/អ្នកសិក្សាគឺផ្តោតលើលទ្ធផលសិក្សាជាគោល។ ការវាយតម្លៃលើការសិក្សាមានបីដំណាក់កាលធំៗ គឺ (១) ការវាយតម្លៃលើការសិក្សាមុខវិជ្ជា (២) ការវាយតម្លៃលើការសរសេររបាយការណ៍ស្រាវជ្រាវ និង (៣) ការវាយតម្លៃសរុបដោយពិនិត្យលើការបំពេញគ្រប់លក្ខខណ្ឌសម្រាប់បញ្ចប់ការសិក្សា។

## គោលការណ៍វាយតម្លៃ

គោលការណ៍រួមសម្រាប់ការវាយតម្លៃលើការសិក្សារបស់និស្សិត/អ្នកសិក្សាមានដូចតទៅៈ

១) និស្សិត/អ្នកសិក្សាតម្រូវឱ្យមានវត្តមានក្នុងការសិក្សាតាមមុខវិជ្ជានីមួយៗ មិនតិចជាង៧០%។ ក្នុងករណីអ្នកសិក្សាមានវត្តមានតិចជាង៧០% នឹងមិនត្រូវបានអនុញ្ញាតឱ្យប្រឡងបញ្ចប់មុខវិជ្ជានោះទេ។

២) ក្នុងករណីដែលនិស្សិត/អ្នកសិក្សាធ្លាក់មុខវិជ្ជាណាមួយក្នុងឆមាស នឹងមិនអនុញ្ញាតឱ្យបន្តការសិក្សាទៅឆ្នាំបន្ទាប់ និងប្រឡងបញ្ចប់ឡើយ។

៣) និស្សិត/អ្នកសិក្សាទាំងអស់ត្រូវធ្វើកិច្ចការស្រាវជ្រាវសំខាន់ៗតាមមុខវិជ្ជានីមួយៗ និងប្រគល់ជូនគ្រូឧទ្ទេសតាមមុខវិជ្ជាដែលបានកំណត់។

៤) និស្សិត/អ្នកសិក្សាត្រូវប្រឡងបញ្ចប់ការសិក្សាដែលធ្វើឡើងបន្ទាប់ពីចប់ឆមាសនីមួយៗ តាមការកំណត់ក្នុងកម្មវិធីសិក្សា។

៥) និស្សិត/អ្នកសិក្សាត្រូវចងក្រងឯកសារវឌ្ឍនភាពនៃកិច្ចការស្ទួលរួមមានការហាត់ការ និងកម្មសិក្សាដែលផ្តោតលើ (ក) សកម្មភាពប្រតិបត្តិ (ខ) លទ្ធផលដែលសម្រេចបាន និង (គ) ការឆ្លុះបញ្ចាំង និងមេរៀនបទពិសោធន៍។

៦) និស្សិត/អ្នកសិក្សាត្រូវតែជាប់មធ្យមភាគនៃការសិក្សាមុខវិជ្ជានិងការធ្វើកម្មសិក្សា ដើម្បីទទួលការអនុញ្ញាតឱ្យការពាររបាយការណ៍ស្រាវជ្រាវ។

## ការផ្តល់ពិន្ទុ និងប្រព័ន្ធចំណាត់ថ្នាក់

និស្សិត/អ្នកសិក្សាអាចទទួលពិន្ទុចាប់ពី 00 ដល់ 100 ទៅតាមការវាយតម្លៃផ្អែកលើលក្ខណៈវិនិច្ឆ័យដែលបានកំណត់ក្នុងការសិក្សាមុខវិជ្ជា ការបំពេញកម្មសិក្សា និងការសរសេរនិងការការពាររបាយការណ៍។ ពិន្ទុដែលជាប់ត្រូវចាប់ផ្តើមពីមធ្យមភាគពិន្ទុ 50% ឬពិន្ទុនិទ្ទេស 2.00 ឡើងទៅ។

ពិន្ទុគឺកំណត់ពី 00.00 ដល់ 100 (មធ្យមភាគនៃពិន្ទុនិទ្ទេសសរុប ឬ Grade Point Average – GPA)។ រូបមន្តគណនារកមធ្យមភាគនៃពិន្ទុនិទ្ទេសសរុប (GPA) គឺមធ្យមភាគនៃពិន្ទុនិទ្ទេសសរុប (GPA) ស្មើផលបូកសរុបរវាងផលគុណនៃពិន្ទុនិទ្ទេស (Grade Point – P) និងតម្លៃក្រេឌីតដែលត្រូវយកនៃមុខវិជ្ជានីមួយៗ (Attempted Credit Value – C) ចែកនឹងផលបូកសរុបនៃតម្លៃក្រេឌីតដែលត្រូវយកគ្រប់មុខវិជ្ជា។

ប្រព័ន្ធចំណាត់ថ្នាក់កម្មវិធី គឺផ្អែកទៅលើតម្លៃនៃពិន្ទុអតិបរមា 100% និង 50% នៃពិន្ទុអប្បបរមា។ ប្រព័ន្ធដាក់ពិន្ទុនេះ ត្រូវបានបកប្រែទៅជា "ពិន្ទុជានិទ្ទេស" និង "ពិន្ទុជាតម្លៃលេខ" ដូចដែលពិពណ៌នាដូចខាងក្រោមៈ

| ពិន្ទុជាភាគរយ% | និទ្ទេស | ពិន្ទុនិទ្ទេស | មូលវិចារណ៍ |
|---|---|---|---|
| 85%-100% | A | 4.00 | ល្អប្រសើរ |
| 80%-84% | B+ | 3.50 | ល្អណាស់ |
| 70%-79% | B | 3.00 | ល្អ |
| 65%-69% | C+ | 2.50 | ល្អបង្គួរ |
| 50%-64% | C | 2.00 | មធ្យម |
| <49% | F | 1.50 | ធ្លាក់ |

## គោលការណ៍ប្រតិបត្តិ

ដើម្បីធានានូវការផ្តល់សេវាអប់រំប្រកបដោយគុណភាព និងភាពស័ក្តិសិទ្ធ មហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញអនុវត្តតាមគោលការណ៍ បទបញ្ញត្តិ និងបទដ្ឋានគតិយុត្តិរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងគោលការណ៍ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

ជាមួយគ្នានេះដែរ និស្សិត/អ្នកសិក្សាម្នាក់ៗ ត្រូវគោរពតាមបទបញ្ជាផ្ទៃក្នុងរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងឈរលើស្មារតីស្មោះត្រង់ ទទួលខុសត្រូវខ្ពស់ និងភាពម្ចាស់ការ និងគោលការណ៍សុចរិតភាពនៃការសិក្សា។ សម្រាប់គោលការណ៍សុចរិតភាពនៃការសិក្សា និស្សិត/អ្នកសិក្សាម្នាក់ៗ ត្រូវបានវាយតម្លៃលើចំណុចសំខាន់ៗដូចខាងក្រោម៖

**ការវាយតម្លៃលើវិន័យ សីលធម៌ ឥរិយាបថ និងអាកប្បកិរិយា**

ការវាយតម្លៃលើវិន័យ សីលធម៌ ឥរិយាបថ និងអាកប្បកិរិយារបស់និស្សិត/អ្នកសិក្សាម្នាក់ៗ ត្រូវបានប្រមូលផ្តុំលើការគោរពវិន័យចាត់តាំង ការមករៀនទៀងទាត់ ការយកចិត្តទុកដាក់ក្នុងការសិក្សា ការខិតខំស្រាវជ្រាវ ការអនុវត្ត ភារកិច្ច និងស្មារតីសាមគ្គីភាពនៅក្នុងថ្នាក់ ក្នុងសាលារៀន និងក្រៅសាលារៀន។ ការវាយតម្លៃលើវិន័យ សីលធម៌ ឥរិយាបថ និងអាកប្បកិរិយារបស់និស្សិតម្នាក់ៗ ត្រូវបានធ្វើឡើងតាមរយៈយោបល់ឯកភាពពីមតិភាគច្រើនដាច់ខាតរបស់ក្រុមប្រឹក្សាវិន័យ ដោយផ្អែកលើលក្ខណសម្បត្តិជាក់ស្តែងរបស់និស្សិត/អ្នកសិក្សាម្នាក់ៗ និងបទបញ្ជាផ្ទៃក្នុងរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

**ការក្លែងបន្លំឯកសារ**

និស្សិត/អ្នកសិក្សាដែលក្លែងបន្លំឯកសារ នឹងត្រូវលុបឈ្មោះចេញពីបញ្ជីនិស្សិតដោយស្វ័យប្រវត្តិ ព្រមទាំងទទួលទោសតាមច្បាប់ជាធរមាន។ និស្សិតត្រូវចាំថា ការលួចចម្លងស្នាដៃ ការលួចកម្មសិទ្ធិបញ្ញា និងគំនិតរបស់អ្នកដទៃគឺជាបទល្មើសសិក្សាធ្ងន់ធ្ងរដែលអាចឈានដល់ការបញ្ឈប់និស្សិតដែលប្រព្រឹត្តបទល្មើសពីកម្មវិធី។ និស្សិត/អ្នកសិក្សានឹងត្រូវធ្លាក់ជាស្ថាពរ បើនិស្សិត/អ្នកសិក្សារូបណាចម្លងដោយផ្ទាល់ពីនិស្សិតដទៃទៀត ឬប្រភពផ្សេងៗ ឬការប្រើសម្ភារៈ ឬឯកសារផ្សេងទៀត ដែលមិនត្រូវបានអនុញ្ញាតក្នុងការប្រឡង។

**របាយការណ៍/កិច្ចការស្រាវជ្រាវ**

និស្សិត/អ្នកសិក្សាត្រូវបង្ហាញនូវសុចរិតភាពនៃការស្រាវជ្រាវរបស់ខ្លួនឱ្យបានខ្ជាប់ខ្ជួនចាប់តាំងពីពេលចូលរៀនរហូតដល់ចុងបញ្ចប់នៃវគ្គបណ្តុះបណ្តាល។ រាល់សំណេរការងារសិក្សាទាំងអស់ មិនត្រូវដកស្រង់គំនិត សរសេរ ឬចម្លងស្នាដៃផ្សេងៗរបស់អ្នកដទៃមកធ្វើជាគំនិតជាស្នាដៃ ឬជាកម្មសិទ្ធិរបស់ខ្លួនដោយគ្មានការបញ្ជាក់ពីប្រភពច្បាស់លាស់នៃឯកសារយោង ឯកសារពិគ្រោះ ឬការអនុញ្ញាតពីម្ចាស់ប្រភព។

ក្នុងករណីរកឃើញមានការលួចចម្លងស្នាដៃអ្នកដទៃ និស្សិត/អ្នកសិក្សានឹងត្រូវប្រឈមមុខចំពោះក្រុមប្រឹក្សា បច្ចេកទេស និងក្រុមប្រឹក្សាវិន័យរបស់មហាវិទ្យាល័យអប់រំ ឬសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដោយត្រូវទទួលពិន័យឱ្យរៀនត្រួតថ្នាក់ ឬអាចត្រូវបញ្ឈប់ពីកម្មវិធីដោយគ្មានសំណងប្រាក់សិក្សាដែលបានបង់រួចហើយទេ និងមិនមានការចេញលិខិតស្នាមបញ្ជាក់ការសិក្សាអ្វីដែរ។

**សំគាល់៖** កម្មវិធីបណ្តុះបណ្តាលសូមរក្សាសិទ្ធិក្នុងការកែប្រែការអនុវត្តជាក់ស្តែងដើម្បីឆ្លើយតបវឌ្ឍនភាពការរៀននិងបង្រៀន សមត្ថភាពរៀន និងអនុវត្តជាក់ស្តែង ស្ថានភាពរៀននិងបង្រៀនជាក់ស្តែង ដើម្បីសម្រេចបានលទ្ធផលសិក្សាល្អបំផុត និងសម្រេចស្តង់ដាសហគមន៍សាលារៀននៃគម្រោង GEIP។

# សមត្ថភាពចិត្តសង្គមរបស់សិស្ស

4*5%0-03!". &5



❖ វត្ថុបំណងនៃមេរៀន

- អ្នកចាប់ផ្ដើមទទួលស្គាល់ការពិតនៃជីវិត និងការងាររបស់អ្នក
- អ្នកចាប់ផ្ដើមស្វែងយល់ពីឥទ្ធិពលនៃការប៉ះទង្គិចអារម្មណ៍ និងកែប្រែជីវិតនិងការងាររបស់អ្នក ដើម្បីសិស្ស និងសហគមន៍របស់អ្នក
- អ្នកបានទទួលយកនូវពិសោធន៍សាមញ្ញក្នុងការជួយខ្លួនឯង គ្រួសារ និងកូនរបស់អ្នក និងសិស្សកសាងបាននូវសមត្ថភាពរស់ជាមួយជីវិតដែលល្អ និងអនាគតគេអាចថែទាំគ្រួសារគេ និងកូនរបស់គេនៅពេលគេក្លាយជាមាតាឬបិតា

## ❖ ខ្លឹមសារចម្បង

១. សិក្សាទ្រឹស្តីពីការប៉ះទង្គិចអារម្មណ៍នៅក្រោយសង្រ្គាម
២. ឆ្លុះបញ្ចាំងពីអត្តចរិត និងចរិយារបស់អ្នកក្នុងជីវិតនិងការងារ
៣. សិក្សាពីឥទ្ធិពលនៃជីវិត និងគ្រួសារសិស្សលើការរៀនសូត្រ
៤. រៀនសូត្រនូវវិធីនាំខ្លួនឲ្យក្លាយជាមនុស្សល្អ

១. សិក្សាពីការប៉ះទង្គិចផ្លូវចិត្តសង្គមក្នុងពេលមានសង្រ្គាម និងក្រោយសង្រ្គាម

## ❑ ព្រឹត្តិការណ៍កើតមាននៅក្នុងសង្គ្រាម

- បាត់បង់តម្រូវការរស់រានមានជីវិតៈ ផ្ទះសម្បែង ចំណីអាហារ សម្លៀកបំពាក់ ការអប់រំ គ្រួសារ ឈឺថ្កាត់ត្រូវបានទុកចោលគ្មានការព្យាបាល
- បាត់បង់សុវត្ថិភាពសង្គមនិងសេដ្ឋកិច្ចៈ ការធ្វើបាតុកម្ម ការបំផ្ទុះគ្រាប់បែក ការចាប់ចង ការធ្វើទារុណកម្ម ការសម្លាប់ មិនមានលុយ ការធ្វើការលើសកម្លាំង

## ❑ ព្រឹត្តិការណ៍កើតមាននៅក្នុងសង្គ្រាម

- បាត់បង់ការស្រឡាញ់នូវអ្វីដែលជារបស់ខ្លួនៈ មិនបានរស់នៅជាមួយគ្រួសារ មាតាបិតានិងបងប្អូន សមាជិកគ្រួសារត្រូវបានស្លាប់ដោយជំងឺ ឬបាត់ខ្លួន
- បាត់បង់ការផ្ដល់នូវតម្លៃជាមនុស្សដល់ខ្លួនដោយខ្លួនឯងៈ លួចម្ហូបអាហារ ពុធធ្វើឈឺ ដល់វាលស្រែតែមិនធ្វើការ ផ្ដើមឡើងនូវការទារសំណូកសម្រាប់ប្រឡងជាប់ថ្នាក់ទីបញ្ចប់

❑ ព្រឹត្តិការណ៍កើតមាននៅក្នុងសង្គ្រាម

- បាត់បង់ការស្គាល់ការពិតរបស់បុគ្គលខ្លួនឯងៈ រស់សម្រាប់តែបុគ្គលខ្លួនឯង មិនទុកចិត្តអ្នកណាទាំងអស់ គ្មានសង្ឃឹមថាមានអ្វីដែលអាចជួយបាន មិនឲ្យនិយាយឬមិនអាចនិយាយ។ ល។

❑ ព្រឹត្តិការណ៍កើតមាននៅក្រោយសង្គ្រាម

- ការបញ្ឈប់នូវវិនាសកម្មប្រល័យពូជសាសន៍នៅឆ្នាំ១៩៧៩ បាននាំមកនូវការបន្ថយស្ទើរតែទាំងអស់នូវការបាត់បង់ទាំងនេះ
- ការបញ្ឈប់សង្គ្រាមនៅឆ្នាំ១៩៩៨ បាននាំមកនូវឱកាសកសាងជាប់ជាបន្តនូវតម្រូវការមូលដ្ឋានរបស់មនុស្ស
- តែអ្វីដែលនៅសេសសល់សម្រាប់បុគ្គលគ្រប់រូប ពិសេសនាយកសាលារៀន និងគ្រូបង្រៀនគឺ ត្រូវជួយគ្នាលុបបំបាត់នូវការប៉ះទង្គិចអារម្មណ៍ និងបំពេញតម្រូវការមូលដ្ឋានរបស់មនុស្ស ហើយនេះគឺជាអ្វីដែលយើងនាំគ្នាពិភាក្សាពេលនេះ

## *ការប៉ះទង្គិចនៅមានបន្តក្រោយពីសង្គ្រាម*

## ការប៉ះទង្គិចតម្រូវការមូលដ្ឋានរបស់មនុស្ស

- ប៉ះទង្គិចតម្រូវការរស់រានមានជីវិត៖ ទទួលរងនូវភាពក្រីក្រ កូនឬកុមារខ្វះអាហារូបត្ថម្ភ ការរៀនសូត្រមានគុណភាពទាប ភ័យខ្លាចពេលមានជម្ងឺដោយគ្មានលុយព្យាបាល កង្វះសមត្ថភាពធ្វើការងារតាមទីផ្សារត្រូវការ ចំណូលតិចមិនគ្រប់រស់ គ្មានលុយទិញផ្ទះ

## ការប៉ះទង្គិចតម្រូវការមូលដ្ឋានរបស់មនុស្ស

- កង្វះសុវត្ថិភាពសង្គម និងសេដ្ឋកិច្ចៈ ការលែងលះប្តីប្រពន្ធដោយមិនរវល់ពីទុក្ខលំបាករបស់កូន ការសង្ស័យនិងខ្វះការទុកចិត្តក្នុងគ្រួសារ ហឹង្សាក្នុងគ្រួសារ ហឹង្សាក្នុងអង្គភាព ហឹង្សាក្នុងសេវាសាធារណៈ ហឹង្សាក្នុងពេលបើកបរបើទោះជាដឹងថាគ្រោះថ្នាក់ក៏នៅតែប្រព្រឹត្ត ឥទ្ធិពលថ្នាំញៀន ការលេងល្បែងស៊ីសង ការកេងប្រវ័ញ្ច ការប្រព្រឹត្តខុសច្បាប់ មិនមានប្រាក់សន្សំ ភ័យខ្លាចពីការបាត់បង់ទ្រព្យសម្បត្តិដោយគ្មានលុយសងការជំពាក់ធនាគារ ការខឹងសម្បារពីគម្លាតនៃអ្នកមាននិងអ្នកក្រ

## ការប៉ះទង្គិចតម្រូវការមូលដ្ឋានរបស់មនុស្ស

- ស្រឡាញ់នូវអ្វីដែលជារបស់អ្នកដទៃៈ ចរិយាដែលយល់ថាធម្មតាដូចជា ការយករបស់ ឬលុយ ឬទ្រព្យសម្បត្តិអ្នកដទៃ ការប្រើពេលវេលាធ្វើការទៅធ្វើអ្វីផ្សេង មិនខ្វីធ្វើដឹងពីការចំណាយធ្វើការងារដោយមិនបានលទ្ធផល កេងប្រវ័ញ្ច
- មិនផ្តល់នូវតម្លៃជាមនុស្សដល់ខ្លួនដោយខ្លួនឯងៈ ភាពមិនស្មោះត្រង់ជាមួយខ្លួន ឬអ្នកដទៃ ឬអង្គភាព ការទាមទារ ការជេរប្រមាថ ឬប្រើហឹង្សា មិនទទួលខុសត្រូវ

## ការប៉ះទង្គិចតម្រូវការមូលដ្ឋានរបស់មនុស្ស

- ការមិនស្គាល់ការពិតរបស់បុគ្គលខ្លួនឯង៖ មិនស្វែងយល់ពីអ្វីដែលខ្លួនត្រូវធ្វើ ធ្វើមិនបានលទ្ធផលជារឿងធម្មតា បន្តមានជំនឿថាខ្លួនជាអ្នកចេះជាងគេ មិនឆ្លើយតបទៅនឹងអ្វីជាសំណើររបស់មនុស្សជុំវិញ បន្តធ្វើខុសលើកិច្ចការដដែលៗ ទោះជារាប់ទស្សវត្សក៏ដោយ។ល។

## ការប៉ះទង្គិចតម្រូវការមូលដ្ឋានរបស់មនុស្ស

ការប៉ះទង្គិចទាំងនេះនាំបុគ្គលម្នាក់ៗសុំនឹងវា **បន្តយល់ថាវាជារឿងធម្មតា ជាមួយនឹងការកើនឡើងនូវភាពតានតឹងអារម្មណ៍** ឈានទៅដល់**ការសម្តែងចេញនូវចរិយាប្រទ្បោតតោតតួងដែលមិនសមហេតុសមផល** ឬមួយ **ការកើនឡើងនូវការយល់ឃើញថាអ្វីដែលជាការប៉ះទង្គិចទាំងនេះគឺបណ្តាលមកពីអ្នកដទៃទាំងអស់ អត្តចរិតបែបនេះបន្តបង្កើនកំហឹងជាមួយការគុំគួនលើអ្នកនៅជុំវិញទាំងអស់ និងចំពោះសង្គម។** នៅទីបញ្ចប់បញ្ហា ឬការប៉ះទង្គិចទាំងអស់នេះគឺ **គ្មានម្ចាស់ទេ** ហើយបុគ្គលម្នាក់ៗបាត់បង់ការស្គាល់ការពិតរបស់ខ្លួន។ ការរស់ក្នុងសភាពបែបនេះ **នាំបុគ្គលកសាងឡើងនូវភាពងងឹតនៅក្នុងចិត្ត** ) Darkness ) ឬមួយជា **ចិត្តបីសាច** ( Evil ) ។

*សិក្សាពីទ្រឹស្តីនៃការប៉ះទង្គិចអារម្មណ៍*

## សិក្សាពីនិយមន័យការប៉ះទង្គិចអារម្មណ៍

ជាអារម្មណ៍ឆ្លើយតបទៅនឹងព្រឹត្តិការណ៍ដែលជះឥទ្ធិពលនាំមកនូវ ការរំខានអារម្មណ៍ និងការទង្គិចអារម្មណ៍ ហើយព្រឹត្តិការណ៍នេះគ្របសង្កត់សមត្ថភាពបុគ្គលក្នុងការដោះស្រាយបញ្ហា ជាហេតុធ្វើឲ្យបុគ្គលមានអារម្មណ៍គ្មានសង្ឃឹមថានឹងមានអ្វីដែលអាចមកជួយបាន ហើយវានាំបន្ថយនូវញាណស្វែងយល់ថាខ្លួនប្រាកដជាខ្លួនរហូតនាំបាត់បង់នូវញាណស្វែងស្គាល់ការពិតរបស់ខ្លួន និងចុងបញ្ចប់បន្ថយសមត្ថភាពរបស់ខ្លួនក្នុងការស្វែងយល់ពីការពិតនៃការទទួលអារម្មណ៍ថា ខ្លួនត្រូវមានពេញលេញនូវសុខភាពផ្លូវចិត្ត និងពិសោធន៍ជីវិត។

## សញ្ញារបស់បុគ្គលមានការប៉ះទង្គិចអារម្មណ៍

ការឆ្លើយតបទៅនឹងព្រឹត្តិការណ៍នាំឲ្យមានការប៉ះទង្គិចអារម្មណ៍មានភាពខុសៗគ្នាទៅតាមមនុស្សម្នាក់ៗ តែមានចរិយាទូទៅមូលដ្ឋានដែលដូចគ្នា.

សញ្ញាផ្លូវចិត្តមានៈ
- ទុក្ខព្រួយ
- ខឹង
- មិនខ្វីធ្វើដឹង
- ភ័យខ្លាច
- ខ្មាស់

**សញ្ញាទាំងនេះអាចនាំមកនូវៈ**
- យល់សប្តិអាក្រក់
- ស្ទើដេកស្ទើភ្ញាក់
- ពិបាកនិយាយគ្នា
- ចរិយាប្រទ្បេតតោតតូង

បណ្តុំរោគសញ្ញាសរីរៈសាស្ត្រ
- ចង្អោ
- វិលមុខ
- លំនាំនៃការដេកមានការប៉ះទង្គិច
- ផ្លាស់ប្តូរការឃ្លានអាហារ
- ឈឺក្បាល
- បញ្ហាដំណើរការក្រពះពោះវៀន

វិបត្តិចិត្តវិទ្យាអាចមាន
- វិបត្តិតានតឹងអារម្មណ៍ក្រោយការប៉ះទង្គិចអារម្មណ៍
- ទុក្ខគ្រាំគ្រាក្នុងចិត្ត
- ភាពអន្ទះអន្ទែង
- វិបត្តិបំបែកបំបាក់ដកខ្លួនចេញពីគេ
- បញ្ហាទទួលរងនូវថ្នាំញៀន

## ភាពធ្ងន់ធ្ងរនៃវិបត្តិតានតឹងអារម្មណ៍ក្រោយការប៉ះទង្គិចអារម្មណ៍

មិនមែនគ្រប់មនុស្សទេ ដែលទទួលការប៉ះទង្គិចអារម្មណ៍ដូចគ្នាតាមរយៈការបង្ហាញជាសញ្ញានៃវិបត្តិតានតឹងអារម្មណ៍ ក្រោយការប៉ះទង្គិចអារម្មណ៍ (Post-traumatic stress disorder (PTSD).) ។ មនុស្សខ្លះមានរោគសញ្ញាមួយចំនួនខាងលើ(ទំព័រមុន) តែរោគសញ្ញាទាំងនេះរលាយបាត់ទៅវិញក្នុងរយៈប៉ុន្មានសប្ដាហ៍ក្រោយ បែបនេះគេហៅថា វិបត្តិតានតឹងអារម្មណ៍ស្រួចស្រាវក្នុងរយៈពេលខ្លី (Acute stress disorder (ASD)).

## ប្រភេទ ប៉ះទង្គិចអារម្មណ៍

- ដូចបាននិយាយខាងដើម ការប៉ះទង្គិចអារម្មណ៍ ត្រូវកំណត់ន័យបាន ដោយសារការទទួលនូវពិសោធន៍របស់អ្នកនៅមានជីវិត ពីព្រឹត្តការណ៍នាំទង្គិចអារម្មណ៍។ ពេល ប្រភេទនៃការប៉ះទង្គិចអារម្មណ៍ អាចចាត់បានជាពីរប្រភេទ គឺ ប្រភេទធ្ងន់ធ្ងរ និងប្រភេទស្រាល។

ប្រភេទស្រាលជាប្រភេទដែលមិននាំមកនូវ **ការបំភ័យដល់សុវត្ថិភាពបុគ្គល ឬជីវិតឡើយ** តែទោះយ៉ាងណាក៏នាំឲ្យកើតមាននូវសញ្ញានៃការប៉ះទង្គិចអារម្មណ៍ដែរ។ ព្រឹត្តិការណ៍នាំទង្គិចអារម្មណ៍ប្រភេទស្រាល **ជាព្រឹត្តិការកើតមានតែម្តងដែលនាំបង្អាក់ដំណើរការអារម្មណ៍** ហើយចប់ទៅវិញ។ ព្រឹត្តិការបែបនេះ **ជាការពិតហើយមិនមែនជារឿងតូចតាចទេនៅពេលវាកើតឡើង** តែវាមិនធ្ងន់ធ្ងរដល់ប្រភេទនៃការប៉ះទង្គិចអារម្មណ៍ធ្ងន់ធ្ងរនោះទេ។ ម៉្យាងវិញទៀត **វាជាព្រឹត្តិការណ៍ដែលអាចពុះពារបាន តែវាក៏អាចបង្ករហានិភ័យឬគ្រោះថ្នាក់ ប្រសិនបើមិនមានការដោះស្រាយ** ហើយភាពធ្ងន់ធ្ងរចេះតែកើនឡើងដល់បុគ្គល ប្រសើនបើមិនមានភាពស្រាកស្រាន ឬការទទួលបាននូវភាពមេត្តា។ ឧទាហរណ៍មានដូចជា៖ ការផ្លាស់ប្តូរការងារថ្មីឬទៅកន្លែងថ្មី ព្រឹត្តិការណ៍ទំនាក់ទំនងដូចជាការលែងលះគ្នា ភាពមិនស្មោះត្រង់ ភាពសោកសៅដែលបណ្តាលពីជម្លោះបុគ្គល វិបត្តិហិរញ្ញវត្ថុដែលកៀបសង្កត់ជីវិត ភាពតានតឹងក្នុងការងារឬជម្លោះ សមរភូមិផ្លូវច្បាប់។ល។

ប្រភេទធ្ងន់ធ្ងរ **ជាប្រភេទពិសោធន៍មិនអាចទទួលយកបាន វានាំបុគ្គលនូវ ភាពតានតឹងអារម្មណ៍ធ្ងន់ធ្ងរ និងភាពគ្មានសង្ឃឹមថានឹងមាននូវអ្វីដែលអាចជួយបាន**។ វាអាចជា **ព្រឹត្តិការណ៍កើតមានតែម្តងដូចជា ភេរវកម្ម ការបំផ្លាញដោយគ្រោះធម្មជាតិ ការរំលោភផ្លូវភេទ**។ ឬមួយជា**ព្រឹត្តិការណ៍អូសបន្លាយពេលវេលដូចជា សង្គ្រាម ការរំលោភបំពានកុមារឬស្ត្រី ការបំភ្លេចឬទុកកុមារឬស្ត្រីចោល ឬការប្រព្រឹត្តហឹង្សាលើកុមារឬស្ត្រី**។ **វាជាការប៉ះទង្គិចអារម្មណ៍ដែលពិបាកណាស់ក្នុងការយកជំនះលើវាបាន ហើយវាក៏អាចត្រូវបានគេជៀសវាងមិនដោះស្រាយតែម្តង**។ ឧទាហរណ៍ មនុស្សដែលកំពុងទទួលរងការប៉ះទង្គិចអារម្មណ៍ប្រភេទធ្ងន់ធ្ងរនេះ**អាចឆ្លើយតបលើព្រឹត្តិការណ៍ឬសកម្មភាពប្រចាំថ្ងៃជាការប្រឆាំងតបវិញ ដោយយកការចងចាំពីអតីតកាលជាសំអាងថាធ្វើអញ្ចឹងត្រឹមត្រូវហើយ**។ ជាយន្តការដោះស្រាយ វាត្រូវការរយៈពេលយូរណាស់ទើបអាចដោះស្រាយបាន តែការពន្យាពេលដោះស្រាយកាន់តែយូរកាលណា ការផ្សះបាននូវការប៉ះទង្គិចអារម្មណ៍បែបនេះគឺត្រូវការពេលវេលាកាន់តែយូរដូចគ្នា។

តើអ្នកយល់ថា ព្រឹត្តិការណ៍ដែលអ្នកបានទទួល
ជាការប៉ះទង្គិចអារម្មណ៍ ប្រភេទស្រាល
ឬមួយជាប្រភេទធ្ងន់ធ្ងរ ?
តើអ្នកចង់រស់នៅជាមួយវាឬទេ ?

## ២. ការរស់នៅ និងធ្វើការងារជាមួយការប៉ះទង្គិចអារម្មណ៍

## ការបន្តទទួលរងពីការប៉ះទង្គិចអារម្មណ៍

- រយៈពេល៥២ឆ្នាំ (សង្គ្រាម៣០ឆ្នាំ បូកជាមួយក្រោយសង្គ្រាម២២ឆ្នាំ) នៃការរស់នៅជាមួយអត្តចរិត និងចរិយានៃការប៉ះទង្គិចអារម្មណ៍ ដែលសង្គមយល់ថាវាជាការធម្មតា ឬវាមិនមានសង្ឃឹមថានឹងមានអ្វីមកអាចកែប្រែវាបានឡើយ

## សញ្ញារបស់បុគ្គលមានការប៉ះទង្គិចអារម្មណ៍ "ទុក្ខព្រួយ"

ដោយសារៈ

- ភាពគ្មានសង្ឃឹមក្នុងការរងារឬជីវិត ព្រោះវាខ្វះរហូត
- អារម្មណ៍យល់ថាខ្លួនគ្មានប្រយោជន៍
- មានអារម្មណ៍ថាមានភាពឯកោ
- មានអារម្មណ៍ថាបានធ្វើអ្វីដែលខុស

## សញ្ញារបស់បុគ្គលមានការប៉ះទង្គិចអារម្មណ៍ “ខឹង”

ដោយសារ៖

- យល់ថាខ្លួនទទួលរងការមើលងាយ ការបំពាន ឬការកេងប្រវ័ញ្ច
- ឥទ្ធិពលនៃការទាមទារឲ្យការគិតរបស់គេដូចអ្វីដែលខ្លួនគិត
- ការនិយាយគ្មានហេតុនិងផល ឬ មានតែអ្នកនិយាយគ្មានអ្នកស្តាប់ ឬយកតែឈ្នះ
- ទារមិនបាន ហើយគ្មានអ្នកផ្តល់ឲ្យ

## សញ្ញារបស់បុគ្គលមានការប៉ះទង្គិចអារម្មណ៍ “មិនខ្វីធ្វើដឹង”

ដោយសារ៖

- មិនមាននរណាម្នាក់មករវល់ជាមួយអ្នកឡើយ ម្នាក់ៗយកតែរួចខ្លួនហ្នឹង
- ធ្លាប់ធ្វើតែអញ្ចឹងរាប់ទសវត្សមកហើយ វាមិនដែលអីទេ
- មិនមានអ្វីដែលអាចធ្វើបាននោះទេ កុំចង់សាកនាំអំពល់ទេ ឬនាំទទួលការស្តីបន្ទោស
- បើទោះបីជាប្រឹងក៏នឹងគ្មានអ្វីជាប្រយោជន៍ដែរ ធ្វើដូចគេដូចឯងទៅ

## សញ្ញារបស់បុគ្គលមានការប៉ះទង្គិចអារម្មណ៍ "ភ័យខ្លាច"

ដោយសារ៖

- ការបរាជ័យ ព្រោះថាបើធ្វើខុសនឹងទទួលបានតែការប្រមាទតែប៉ុណ្ណោះ
- បានប្រាប់ឬបង្កើតការពិតដែលមិនមែនជាការពិត ឬជាការកុហក
- ការពិតពីអ្វីដែលបានធ្វើខុស
- ការពុំមានរំពឹងថាអាចរក្សាបាននូវអ្វីដែលធ្លាប់បានធ្វើ ឬកំពុងធ្វើ

## សញ្ញារបស់បុគ្គលមានការប៉ះទង្គិចអារម្មណ៍ "ខ្មាស"

ដោយសារ៖

- ការដឹងខ្លួនថាចេះតែនិយាយ
- អំនួតពីអ្វីដែលមិនពិត ឬ ពីអ្វីដែលបានមកដោយការធ្វើអ្វីដែលខុស
- មិនមានសមត្ថភាពជួយខ្លួនឯង ឬជួយសង្គម
- ការយល់ថាសង្គមស្គាល់ថាខ្លួនជាមនុស្សប្រភេទអ្វី

## ៣. ពិសោធន៍ជីវិតក្នុងការរើបម្រះចេញពីការប៉ះទង្គិចអារម្មណ៍

បុគ្គលមានភាពងងឹតក្នុងចិត្ត ឬចិត្តបីសាច (EVIL)

ជាសំណល់អត្តចរិតចរិយាដែលបានកសាងក្នុងរយៈពេល៥២ឆ្នាំ

វាត្រូវការរយៈពេលប្រហាក់ប្រហែលគ្នាដើម្បីលុបបំបាត់

បើយើងទាំងអស់គ្នាចាប់ផ្តើមលុបបំបាត់វានៅថ្ងៃនេះ

បុគ្គលមានភាពងងឹតក្នុងចិត្ត ឬចិត្តបីសាច (Evil)

ជាចរិយាដែលស្តែងចេញដោយសារ

“ការទាមទារ ទារមិនចេះគ្រប់ ឲ្យយ៉ាងណាក៏មិនគ្រប់ ”

ហើយវាមិនទាក់ទងទាល់តែសោះជាមួយការផ្តល់ឲ្យ

ជាចរិយាដែលស្តែងចេញដោយសារ

“ការទាមទារ ទារមិនចេះគ្រប់ ឲ្យយ៉ាងណាក៏មិនគ្រប់ ”

ព្រោះគ្រប់បុគ្គលម្នាក់ៗគិតតែពីទារ ដោយសារមិនដែលគិតពីការផ្តល់ឲ្យ ឬគ្មានសមត្ថភាពផ្តល់ឲ្យទេ

ហើយស្ទើរតែគ្មានទេអ្នកជុំវិញដែលគិតពីការផ្តល់ឲ្យនោះ

ការទារខ្លះជាការទារនូវអ្វីដែលត្រូវការ និង

ការទារជាច្រើនទៀតជាការទារនូវអ្វីដែលមិនត្រូវការ

ទាររហូត ដល់បានហើយគឺមិនឲ្យវិញទេ

ទារបានដោយការបំពាន ហើយបន្តទារការគោរពពីអ្នកត្រូវបំពានទៀត

ប្រមាទគេហើយ ទារឲ្យគេទទួលការប្រមាទ

ទារនូវអ្វីដែលត្រូវការ ទារមិនចេះគ្រប់ មានដូចជា

អាហារ លុយ ផ្ទះសម្បែង សុខភាព

សុវត្ថិភាព ទ្រព្យសម្បត្តិ ផ្លូវភេទ

ទារនូវអ្វីដែលមិនត្រូវការ ទារមិនចេះគ្រប់ មានដូចជា

ពេល ពាក្យ ការគិត ការគោរព

កោតសរសើរ កិត្តិយស ភាពថ្លៃថ្នូរ ភាពថ្កើងថ្កាន

ទារនូវអ្វីដែលមិនត្រូវការ ទារមិនចេះគ្រប់ មានដូចជា

ការទារពេល និងពាក្យ នាំឲ្យអ្នកផ្តល់ឲ្យកែប្រែអត្តចរិតពី

ការស្រឡាញ់ជាការមានអារម្មណ៍ថាមានទោស

ទារនូវអ្វីដែលមិនត្រូវការ ទារមិនចេះគ្រប់ មានដូចជា

ការគិត ការគោរព កោតសរសើរ កិត្តិយស ភាពថ្លៃថ្នូរ ភាព

ថ្កើងថ្កាន នាំឲ្យអ្នកដែលត្រូវគេទាមទារមានចិត្ត

ខឹងសម្បារ មើលងាយ គុំគួន ផ្ទាញ់ផ្ទាល  តែមិនអាចធ្វើអីគេ

បាន ហើយការបន្តរស់បែបនេះបន្សល់នូវភាពកាន់តែធ្ងន់ធ្ងរ នៃការប៉ះទង្គិច
អារម្មណ៍

ការទាមទារ និងការផ្តល់ឲ្យត្រូវមានតុល្យភាព

បើម្ខាងគិតតែពីទារ ដោយមិនផ្តល់ឲ្យសោះ ឬមិនដែលគិតពីការកសាងសមត្ថ

ភាពដើម្បីផ្សល់ឲ្យវិញនោះ

ទោះជាព្រះ ក៏ទទួលយកមិនបានដែរ ឬផ្តល់្យមិនបានដែរ

តែតុល្យភាពនេះមិនមានទេនៅក្នុងលោក

ទារមិនបាននាំឲ្យកើតនូវការសង្ស័យ ការមិនទុកចិត្ត
ការជជីកសួរ ការអស់សង្ឃឹម ការឈ្លោះទាស់ទែង
និងឈានដល់ការបែកបាក់គ្រួសារ
អ្នកដែលរងគ្រោះគឺ កូន ហើយវាបន្តជាវដ្តវិលជុំ
ក្នុងជីវិតកូន និងចៅជាប់ជាបន្ត

ពិសោធន៍ក្នុងជីវិតរយៈពេល៥២ឆ្នាំ ពីការព្យាយាម
ជួយមនុស្សឲ្យចាកចេញពីការមោនភាពងងឹតក្នុងចិត្តឬចិត្តបីសាច
តាមរយៈការគិតអ្វីដែលល្អ និងធ្វើអំពើល្អគ្រប់បែបយ៉ាង
បាននាំមកនូវការយល់ឃើញមួយជាក់ច្បាស់គឺ
ជាការពិបាកបំផុត និងមិនអាចទៅរួចទេ  បើដូចនេះតើអ្វីទៅដែលអាចជួយបាន ?

តាមរយៈការគិតអ្វីដែលល្អ និងធ្វើអំពើល្អគ្រប់បែបយ៉ាង

បាននាំមកនូវការយល់ឃើញមួយដាក់ច្បាស់គឺ

អាចទៅរួចតែជាការពិបាកបំផុត រួមជាមួយនឹងការធ្វើបាបខ្លួនឯងជាប់រហូត

ព្រោះជាមនុស្ស

បើដូចនេះតើអ្វីទៅដែលអាចជួយជួយមនុស្សឲ្យចាកចេញពីភារមានភាពងងឹត

ក្នុងចិត្តឬចិត្តបីសាចបាន ?

ចំម្លើយមានតែមួយគត់គឺ

ការផ្តល់លទ្ធភាពឲ្យមនុស្សមានចិត្តបីសាច



ធ្វើអំពើល្អពី១ដែលជាការផ្តល់ឲ្យនូវអ្វីដែលមនុស្សនៅជិតគាត់ត្រូវការ

ហើយវាជា

ភ្លើងទៀនបំភ្លឺផ្លូវជីវិតគាត់ហើយ

បើអ្នកបន្តផ្តល់លទ្ធភាពបែបនេះរហូត

នោះអ្នកនឹងជួយឲ្យបុគ្គលម្នាក់ៗឈប់ទាមទារ

តែក្លាយទៅជាបុគ្គលដែលមានតែការផ្តល់ឲ្យ

ចាប់ផ្តើមផ្តល់ឲ្យថ្ងៃនេះ នោះអ្នកនឹងអាចកសាងបានមិនចេះអស់នូវអ្វីដែលត្រូវ
ផ្តល់ឲ្យដល់មនុស្សនៅជុំវិញខ្លួនអ្នក

ចាប់ផ្តើមផ្តល់ឲ្យថ្ងៃនេះ នោះអ្នកនឹងអាចកសាងបានមិនចេះអស់នូវអ្វីដែលត្រូវ
ផ្តល់ឲ្យដល់មនុស្សនៅជុំវិញខ្លួនអ្នក

នៅពេលនោះហើយដែលការទាមទារ និងការផ្តល់ឲ្យមានតុល្យភាពហើយ

នៅពេលនោះហើយដែលការទាមទារ និងការផ្តល់ឲ្យមានតុល្យភាពហើយ

ហើយក៏ជាពេលដែលមនុស្សម្នាក់គប្បីរៀនស្គាល់ថា អ្វីដែលអ្នកកំពុងមានទាំងនេះ វាល្អមគ្រប់គ្រាន់ហើយ

អ្នកអាចផ្តល់លទ្ធភាពឲ្យមនុស្សនេះបាន

លុះណាអ្នកបណ្តុះបាននូវ៖

ចិត្តមេត្តាដែលបានពីការអាណិតអាសូរ

ចិត្តករុណាដែលបានពីការសណ្តោសប្រណី

ចិត្តមុទិតាដែលបានមកពីចិត្តចង់ឃើញមនុស្សបានសុខ

និងចិត្តឧបេក្ខាដែលបានមកពីចិត្តមិនទាមទារ

សួរសំនួរមួយទៀតថា តើអ្នកត្រូវធ្វើអ្វីដើម្បីអាចមានចិត្ត៖

មេត្តា ករុណា មុទិតា និងឧបេក្ខាបាន?

ចាប់ផ្តើមផ្តោតលើអ្វីដែលអ្នកត្រូវធ្វើ ធ្វើអំពើល្អ តាមរយៈការ

ផ្តល់ឲ្យនូវអ្វីដែលមនុស្សនៅក្បែរអ្នកត្រូវការទៅ

នោះអ្នកនឹងបណ្តុះបាននូវចិត្តទាំងនេះហើយ តែអ្នកត្រូវចង

ចាំថា កុំទារឲ្យសោះពេលដែលអ្នកផ្តល់ឲ្យ

តែអ្នកត្រូវចង

ចាំថា កុំទារឲ្យសោះនៅពេលដែលអ្នកផ្តល់ឲ្យ

ការទារនេះហើយវានាំឲ្យអ្នកឈឺចាប់

នៅពេលអ្នកទារមិនបាន

បើអ្នកនៅតែទារ នោះអ្នកមិនអាចបណ្តុះចិត្ត មេត្ត ករុណា មុទិតា និងឧបេក្ខា
បានទេ

## ៤. រៀនសូត្រនូវវិធីនាំខ្លួនឲ្យក្លាយជាមនុស្សល្អ

## តើត្រូវចាប់ផ្តើមពីអ្វីដើម្បីអ្នកអាចក្លាយខ្លួនជាមនុស្សល្អ?

- ការចាប់ភ្ញាក់ដឹងថាខ្លួនកំពុងទទួលរងនូវការប៉ះទង្គិចអារម្មណ៍ បញ្ឈប់ការគិតពីវា
- សួរថា តើអ្វីដែលល្អនិងអ្វីដែលអាក្រក់  ហើយអ្វីដែលត្រូវនិងអ្វីដែលខុស
- សិក្សា និងស្វែងយល់ដឹងពីអ្វីដែលល្អ នឹងនាំមនុស្សឲ្យធ្វើតែអ្វីដែលត្រូវ
- សិក្សាស្វែងយល់ដឹងពីអ្វីដែលអាក្រក់ នឹងនាំមនុស្សមិនឲ្យធ្វើអ្វីដែលខុស
- សិក្សានៅទំព័របន្ទាប់ជាមួយគ្នា

៦. ខ្វល់ខ្វាយពីសិស្សរៀនចេះឬមិនចេះ ខិតខំធ្វើតេស្តស្តង់ដាទៀងទាត់

៧. បង្រៀនមានការស្រាវជ្រាវ ឬរៀបចំផែនការបង្រៀន ចំណាយម៉ោងវេជ្ជទាំងអស់អនុវត្តសកម្មភាពវិជ្ជាជីវៈ

៨. ជួយសិស្សម្នាក់ៗរៀនឲ្យចេះ និងធ្វើលំហាត់គ្រប់សព្វ គ្រូដាក់លំហាត់ ឬគម្រោងឲ្យសិស្សរៀនក្នុង ឬក្រៅថ្នាក់ទៀងទាត់

៩. គ្រូលើកទឹកចិត្តសិស្សឲ្យរៀនដោយការសន្យាជួយ ជួយសិស្សដោះស្រាយបញ្ហាសង្គមក្នុងគ្រួសារ ឬការប៉ះទង្គិចអារម្មណ៍របស់សិស្ស

## តើត្រូវចាប់ផ្តើមពីអ្វីដើម្បីអ្នកអាចក្លាយខ្លួនជាមនុស្សល្អ?

- ចាប់ផ្តើមធ្វើកិច្ចការមួយដែលល្អ បើជាគ្រូបង្រៀនត្រូវជួយសិស្សអ្នកឲ្យរៀនចេះ បើជានាយកសាលារៀនត្រូវជួយគ្រូរបស់អ្នកឲ្យចេះធ្វើការ
- ជួយសិស្សរៀនចេះបានត្រូវបង្រៀនសិស្សសម្របតាមសមត្ថភាពគេ
- ប្រើការបង្រៀនដែលអាចនាំសិស្ស និងគ្រូបង្រៀនរកចំណូលបានដោយភាពត្រឹមត្រូវនិងថ្លៃថ្នូរ
- ជួយដល់សិស្សក្រីក្រឲ្យអាចរៀនបានចេះដូចសិស្សអ្នកមាន

## តើត្រូវចាប់ផ្ដើមពីអ្វីដើម្បីអ្នកអាចក្លាយខ្លួនជាមនុស្សល្អ?

- គិត និងប្រព្រឹត្តចរិយាដើម្បីជាប្រយោជន៍ដល់សង្គមជាជាងប្រយោជន៍បុគ្គល ឬមនុស្សមួយក្រុម កែសម្រួលក្បួនច្បាប់ឬបទបញ្ញាដើម្បីឆ្លើយតបទៅនឹងប្រយោជន៍របស់មនុស្សច្រើនឬសង្គម ជាជាងបម្រើឲ្យមនុស្សម្នាក់ ឬមនុស្សមួយក្រុម
- គិត និងប្រព្រឹត្តនូវចរិយាលើសពីក្បួនច្បាប់ឬបទបញ្ញា ប៉ុន្តែជាចម្លើយសម្រាប់សមធម៌ យុត្តិធម៌ សិទ្ធិមនុស្ស សុជីវធម៌ និងប្រជាធិបតេយ្យ។ ជួយមនុស្សទាំងអស់កសាងសង្គមមួយដែលរស់នៅជាមួយគ្នាយ៉ាងសុខសាន្ត។

# ទ្រឹស្តីអប់រំ គោលវិធី និងវិធីសាស្ត្រ

លោក ព្រឹង មរកត ប្រធាននាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ
សាស្ត្រាចារ្យ សុខ សូត្រ ព្រឹទ្ធបុរសមហាវិទ្យាល័យអប់រំ

រាជធានីភ្នំពេញ ២៩ មិថុនា ២០២៤

## មាតិកា

- និយមន័យអប់រំ? ទ្រឹស្តី? និងទ្រឹស្តីអប់រំ?
- គោលវិធីអប់រំ?
- វិធីសាស្ត្របង្រៀន
- តិចនិចបង្រៀន?
- ទ្រឹស្តីការអប់រំ
- វិធីសាស្ត្របង្រៀន
- ទម្រង់កិច្ចតែងការដែលត្រូវបន្សីសមាសធាតុទាំងអស់ខាងលើ



# កំណត់និយមន័យ «អប់រំ»

- «ការអប់រំ គឺជាការអនុវត្តជាប់ជាប្រចាំនូវដំណើរការរៀនដែលមានកម្មវិធីសិក្សាច្បាស់លាស់ ដើម្បីជួយឱ្យសម្រេចគោលបំណងចុងក្រោយមួយដែលជារួមត្រូវបានទទួលស្គាល់ថា ល្អប្រសើរ»

***Education: a basic definition***

Education is a continuous practice consisting of purposively structured learning processes aimed at the realisation of ends that are consciously derived from a certain conception of the 'good'. [Author's definition]

Articles

**A theory of education**

Ariel Sarid

Pages 479-494 | Received 26 Oct 2016, Accepted 13 Jul 2017, Published online: 24 Aug 2017

Cite this article https://doi.org/10.1080/0305764X.2017.1356267 Check for updates

# ការប្រទាញប្រទង់រវាងគោលបំណងចុងក្រោយនៃការអប់រំ

អភិរក្ស vs. អភិវឌ្ឍ
(conservation vs. change)

សម្រេចបំណងបុគ្គល vs. សម្រេចបំណងសកល (self-flourishing/self-actualisation vs. universal well-being)

## គុណតម្លៃទាំង ១០ នៃការអប់រំ

**ស្វ័យអភិវឌ្ឍ**
- *អំណាច*
- *ផលសម្រេច*
- *តម្រេកនិយម*

**ស្វ័យឧត្តមភាព**
- *សកលនិយម*
- *សប្បុរសធម៌*

**ការបើកទទួលយកការផ្លាស់ប្តូរ**
- *ការរំញោច*
- *ការស្វ័យស្វែងរកផ្លូវ*

**ការអភិរក្ស**
- *ប្រពៃណី*
- *ភាពសម្របគ្នា*
- *សុខសុវត្ថិភាព*




Figure 1. Theoretical model of relations between 10 basic values (Schwartz, 1992; Schwartz et al., 2012). Reproduced figure taken from Martin & Upham (2016).

## ការអប់រំ ៤ ប្រភេទ

1. ការអប់រំសាសនា
2. ការអប់រំដើម្បីចំណេះដឹង
   - ‛Liquid learning … is characterized by emancipation, reflexivity and flexibility so that knowledge and knowledge boundaries are contestable and always on the move′
3. ការអប់រំបែបវិភាគស៊ីជម្រៅបរិវត្តកម្ម
4. ការអប់រំបច្ចេកទេស




Figure 2. Connecting four generic educational types to Schwartz's value scale.

# កំណត់និយមន័យ «ទ្រឹស្តី»

- ក្នុងជីវិត និងក្នុងវិស័យសិក្សាស្រាវជ្រាវ ទ្រឹស្តី ត្រូវបានគេកំណត់និយមន័យ ដូចតទៅ៖
  - ទ្រឹស្តីដែលផ្ទុយនឹងការអនុវត្ត៖ ទ្រឹស្តី (ការគិតវិភាគ និងឆ្លុះបញ្ចាំង) ការអនុវត្ត (ការធ្វើ)
  - ទ្រឹស្តីជាសម្មតិកម្ម៖ ទ្រឹស្តីជាគំនិតដំបូង ជាគំរូ ដែលត្រូវគេស្តបញ្ជាក់រហូតផ្ទៀងផ្ទាត់ថា «ពិត»
  - ទ្រឹស្តីជាការពន្យល់៖ ទ្រឹស្តីគឺជាការពន្យល់លម្អិតបាតុភូតជាក់លាក់ណាមួយ

DEFINING THEORY

In public life and in academic texts, people use the word 'theory' in a myriad ways. Consider the following examples:

- **Theory as the opposite of practice:** Theory is about thinking and reflecting, as opposed to doing things.
- **Theory as hypothesis:** Theory is an initial idea, r… needs to be tested or followed up to determine… true.
- **Theory as explanation:** Theory is a more or les… tion for a specific phenomenon, such as how ch…




# មុនដល់ទ្រឹស្តី






# គោលវិធី

នៅក្នុងសៀវភៅ «ក្របខណ្ឌគរុកោសល្យសតវត្សរ៍ទី២១ សម្រាប់ប្រទេសកម្ពុជា» របស់ក្រសួងអប់រំ យុវជន និងកីឡា (២០២០ ទំ. ១១) «គោលវិធី» ត្រូវបានពិភាក្សាដូចតទៅ៖

> ក្នុងកម្រិតអន្តរជាតិ អ្នកអប់រំកំណត់ពាក្យ "គោលវិធី" ថាជាកម្រិតខ្ពស់បំផុតនៃប្រព័ន្ធគំនិតអប់រំ។ នៅក្នុងក្របខណ្ឌដែលបង្ហាញក្នុងរូបភាព ៣.១ យើងកំណត់និយមន័យ គោលវិធី ថាជាទស្សនវិជ្ជានៃការបង្រៀន និងរៀន (ឧ. ការសិក្សាបែបស្ថាបនានិយម វឌ្ឍនភាពនិយម។ល។)។ គោលវិធីទស្សនវិជ្ជាបង្កប់នូវគោលការណ៍បែបអរូបី ដែលជាមគ្គុទ្ទេសសម្រាប់ឈានទៅអភិវឌ្ឍវិធីសាស្ត្រ...។ នៅក្នុងគោលវិធីមួយ អាចមានវិធីសាស្ត្រជាច្រើននៅក្នុងនោះ (ឧ. IBL, PBL, ។ល។) ហើយនៅក្នុងវិធីសាស្ត្រអាចមានល្បិចបង្រៀនជាច្រើន។

*រូបភាព៣.១ ទំនាក់ទំនងតាមឋានានុក្រមរវាង គោលវិធី វិធីសាស្ត្រ និង ល្បិច*







# វិធីសាស្ត្រ

ក្នុងបរិបទបង្រៀន និងរៀន «វិធីសាស្ត្រ» ឬអ្វីដែលភាសាអង់គ្លេសហៅថា Method សំដៅដល់លំដាប់លំដោយនៃសកម្មភាពគ្រូ និងសិស្សជាប្រព័ន្ធមួយ ក្នុងការរៀននិងបង្រៀន។ វិធីសាស្ត្រ មានលក្ខណៈចង្អុលបង្ហាញបែបបង្គាប់បញ្ជាដោយមានបែងចែកជាជំហាន និងដំណាក់កាលផ្សេងៗដែលត្រូវធ្វើក្នុងការបង្រៀន និងរៀន។ រាល់ជំហាន និងសកម្មភាពទាំងអស់នៃវិធីសាស្ត្របង្រៀនគឺត្រូវអនុលោមទៅតាមខ្លឹមសារគោលនៃគោលវិធីការបង្រៀន និងរៀន។ ឧទាហរណ៍ ក្នុងគោលវិធី «សិស្សមជ្ឈមណ្ឌល» តួនាទីគ្រូគឺអាចធ្វើបានត្រឹមតែជាអ្នកសម្របសម្រួល ហើយត្រូវធ្វើគ្រប់យ៉ាងដើម្បីធានាឱ្យបានថា រាល់ការផ្តួចផ្តើមនានានោះ ពិតជារបស់សិស្ស។ សិស្សត្រូវរៀនស្នើមេរៀនណាមួយមុនពេលដែលគេត្រូវរៀន ហើយក៏ត្រូវស្នើផងដែរពីវិធីរៀន និងវាយតម្លៃការរៀនយ៉ាងដូចម្តេច។ ដោយសារការរៀនបែបនេះទាមទារស្វ័យភាពខ្ពស់ សិស្សានុសិស្សភាគច្រើនកម្រនឹងរៀនតាមវិធីនេះបានពេញលេញណាស់ ទោះបីមានគ្រូភាគច្រើនអះអាងថាគាត់ប្រើប្រាស់ «គោលវិធីសិស្សមជ្ឈមណ្ឌល» ក៏ដោយ។

នៅក្នុងសៀវភៅ «ក្របខណ្ឌគរុកោសល្យសតវត្សរ៍ទី២១ សម្រាប់ប្រទេសកម្ពុជា» របស់ក្រសួងអប់រំ យុវជន និងកីឡា (២០២០ ទំ. ១២) វិធីសាស្ត្រត្រូវបានពន្យល់ថា «គឺជាប្រព័ន្ធនៃល្បិច ការអនុវត្ត និងដំណើរការ ដែលគ្រូប្រើដើម្បីបង្រៀន។ វិធីសាស្ត្របង្កើតឡើងដោយផ្អែកលើទ្រឹស្តីទស្សនវិជ្ជាជាក់លាក់ចំពោះការបង្រៀន និងការរៀន»។



# តិចនិច

នៅក្នុងសៀវភៅ «ក្របខណ្ឌគរុកោសល្យសតវត្សរ៍ទី២១ សម្រាប់ប្រទេសកម្ពុជា» របស់ក្រសួងអប់រំ យុវជន និងកីឡា (២០២០ ទំ. ១២) ល្បិចបង្រៀន ឬពាក្យជាក់លាក់ ដែលសៀវភៅនេះប្រើ «ល្បិចអប់រំ» «គឺជាបំណិន និងសកម្មភាពជាក់លាក់ដែលគ្រូប្រើ (ឧ. ការសួរសំណួរ ការចាត់តាំងគម្រោងឱ្យសិស្ស ការរៀបចំសិស្សជាក្រុម។ល។) ដែលជាផ្នែកមួយនៃវិធីសាស្ត្រទូលំទូលាយ»។ សៀវភៅនេះមិនបានបញ្ជាក់ច្បាស់ទេថា «វិធីសាស្ត្រទូលំទូលាយ» មានន័យដូចម្ដេច។

ស្រដៀងគ្នានេះដែរ លោកអេដវ៉ាដ អែនថូនី (១៩៦៣) បានហៅផ្នែកតូចបំផុតនៃសកម្មភាពបង្រៀនថា «តិចនិច» ដែលទំនងជាពាក្យដែលសៀវភៅ «ក្របខណ្ឌគរុកោសល្យសតវត្សរ៍ទី២១ សម្រាប់ប្រទេសកម្ពុជា» របស់ក្រសួងអប់រំ យុវជន និងកីឡា (២០២០ ទំ. ១២) បកប្រែថា «ល្បិចអប់រំ» នោះផងមើលទៅ។ ក្នុងសៀវភៅនេះ ពាក្យតិចនិចមិនត្រូវបានបកប្រែទេ ព្រោះពាក្យនេះក៏ត្រូវបានប្រើប្រាស់ទូលំទូលាយជាពាក្យកម្ចីរួចហើយក្នុងភាសាខ្មែរ ហើយបើទោះជាបកប្រែ ក៏ទំនងជាបកថា ល្បិចបង្រៀន សមរម្យជាងព្រោះ «បង្រៀន» មានលក្ខណៈជាក់លាក់ជាង «អប់រំ»។ ការបកស្រាយពីភាពខុសគ្នារវាងពាក្យ អប់រំ និង បង្រៀន គួររក្សាទុកជាប្រធានបទដោយឡែកសម្រាប់ពេលក្រោយ ឬសម្រាប់អ្នកផ្សេងទៀតបកស្រាយ។




# អន្តរកម្ម




រូបភាពទី...៖ ឧទាហរណ៍អំពីគោលវិធី វិធីសាស្ត្រ និងល្បិចបង្រៀន ក្នុងឋានានុក្រមប្រព័ន្ធអប់រំ
(ប្រភព៖ ក្របខណ្ឌគរុកោសល្យសតវត្សរ៍ទី២១ សម្រាប់ប្រទេសកម្ពុជា ២០២០ ទំ. ១២)

ក្នុងបរិបទរៀន និងបង្រៀនភាសា លោកអេដវ៉ាដ អែនថូនី (១៩៦៣) បានកំណត់ថា «គោលវិធី» គឺឋិតក្នុងលំដាប់ខ្ពស់ជាង គេគ្របដណ្តប់ «វិធីសាស្ត្រ» ហើយ «តិចនិច» ឬសកម្មភាពគោលនៃកិច្ចតែងការ[4]។ រូបភាពខាងក្រោមបង្ហាញពីលំដាប់លំដោយ ឬស្រទាប់នៃ «គោលវិធី វិធីសាស្ត្រ និងតិចនិច»[5]។




រូបភាពទី...៖ លំដាប់លំដោយ ឬស្រទាប់នៃ «គោលវិធី វិធីសាស្ត្រ និងតិចនិច» របស់ លោកអេដវ៉ាដ អែនថូនី (១៩៦៣)




ទ្រឹស្តីអប់រំចម្បងៗ និងវិធីសាស្ត្ររបស់វា
អាកប្បកិរិយានិយម
វិធីត្រាប់តាម
វិធីឧទ្ទេស
ការគិតនិយម
វិធីសិក្សាបញ្ញតិ
វិធីសួរសំណួរ
ស្ថាបនានិយម
វិធីរិះរក
វិធីស្វ័យបង្កើតការយល់ដឹង


ទ្រឹស្តីអប់រំចម្បងៗ និងវិធីសាស្ត្ររបស់វា
ស្ថាបនាសង្គមនិយម
វិធីសហការ
វិធីរុករក
ការរៀនដោយពិសោធផ្ទាល់
វិធីវិទ្យាសាស្ត្រ
វិធីរិះរក
មនុស្សនិយម
វិធីផ្តោតលើស្ទីលការរៀន
វិធីសហការ

# ទ្រឹស្តីអប់រំចម្បងៗ និងវិធីសាស្ត្ររបស់វា




# អាកប្បកិរិយានិយម

អកប្បកិរិយានិយម ឬ Behaviorism (Skinner 1974) ជាទ្រឹស្តីអប់រំដែលមានប្រភពពីចិត្តសាស្ត្រ ហើយផ្តោតលើតួនាទីការរៀន និងអក្បកិរិយាដែលអាចសង្កេតមើលបានដើម្បីជាមធ្យោបាយក្នុងការយល់ពីសកម្មភាពមនុស្ស និងសត្វ។ ទ្រឹស្តីអក្បកិរិយានិយមមានលក្ខណៈសំគាល់ដូចតទៅ៖

| | |
|---|---|
| ១ | ចំណេះដឹងគឺត្រូវ បានកំណត់ទុកជាមុនច្បាស់លាស់ |
| ២ | គោលបំណងសិក្សាត្រូវតែអនុម័តទុកជាមុនឱ្យបានច្បាស់លាស់ |
| ៣ | ការទាក់ទាញទឹកចិត្ត សិក្សាគឺទាក់ទងនិងកត្តាខាងក្រៅបុគ្គល |
| ៤ | ជាតុភ្ញោចសម្រាប់សិក្សាគឺចាំបាច់ដើម្បីឱ្យការរៀនអាចកើតឡើងទៅបាន |
| ៥ | គ្រូមជ្ឈមណ្ឌលគឺជាការអនុវត្តជាទូទៅ (គ្រូជាអ្នកកំណត់ការរៀន និងលទ្ធផលសិក្សា) |
| ៦ | អ្នករៀនមិនទាមទារឱ្យសកម្មទេ |
| ៧ | ការរៀនគឺផ្តោតលើការទន្ទេញចាំរត់មាត់ខ្លឹមសារគន្លឹះនៃមេរៀន |
| ៨ | ការរៀនទាមទារឱ្យសិស្សបំពេញកិច្ចការមួយចំនួនដែលគ្រូដាក់ឱ្យសិស្សធ្វើតែប៉ុណ្ណោះ |
| ៩ | ការដាក់ទណ្ឌកម្មដល់សិស្សគឺច្រើនត្រូវបានអនុវត្តទូលំទូលាយ |
| ១០ | ការរៀនមិនទាមទារការគិតទេ (តែផ្តោតលើការបង្កើតទម្លាប់) |



# ការគិតនិយម

គំនិតនិយម ការគិតនិយម ឬវិចារណញាណនិយម Cognitivism ( Jean Piaget 1960s ) គឺជាក្របខណ្ឌទ្រឹស្តីក្នុងចិត្តសាស្ត្រដែលជឿថាខួរក្បាលមានតួនាទីសំខាន់ក្នុងការគិត វិភាគ ហើយការរៀនអាចកើតឡើងបានលុះត្រាសិស្សបានគិត និងវិភាគដោយខ្លួនឯង។ គំនិតនិយមមានលក្ខណៈសំគាល់ដូចតទៅ៖

| | |
|---|---|
| ១ | ការរៀន និងការអភិវឌ្ឍពឹងផ្អែកទាំងស្រុងលើបទពិសោធន៍ផ្ទាល់របស់អ្នកសិក្សា |
| ២ | សិស្សបង្កើតចំណេះដឹងដោយខ្លួនឯងដើម្បីជាការយល់បទពិសោធន៍ដែលខ្លួនឯងបានឆ្លងកាត់ |
| ៣ | ការប្រាស្រ័យទាក់ទងគ្នាក្នុងសង្គម និងការប្រើប្រាស់ភាសា និងបំណិនទំនាក់ទំនងជួយសម្របសម្រួលការបង្កើតចំណេះដឹង |
| ៤ | ការរៀនទាមទារឱ្យមានការបង្កើតបទពិសោធន៍ និងយោបល់ត្រឡប់ ហើយគោលដៅនៃការបង្រៀនគឺប្រាស្រ័យទាក់ទងចំណេះដឹងជាមួយគ្នា |
| ៥ | ការរៀននឹងកាន់តែទទួលបានការពង្រឹងពេលដែលបទពិសោធន៍នាំឱ្យមានការរៀនមានការផ្សារភ្ជាប់ទៅនឹងជីវិតជាក់ស្តែង |
| ៦ | ការរៀនត្រូវផ្តោតលើការវិភាគ និងរៀបចំដំណើរការព័ត៌មានដែលអ្នករៀនទទួលបាន |
| ៧ | អ្នករៀនត្រូវតែបុរេសកម្ម ហើយការបង្រៀនត្រូវផ្តើមចេញពីងាយស្រួលទៅលំបាក |
| ៨ | គ្រូដើរតួជាអ្នកបំផុសការគិតរបស់សិស្ស និងជាអ្នកសម្របសម្រួលការសិក្សា |
| ៩ | ការសិក្សាត្រូវធ្វើឡើងជាក្រុម និងយកលំនាំតាមការប្រស្រ័យទាក់ទងក្នុងសង្គមជាក់ស្តែង |
| ១០ | សម្ភារៈរៀន និងបង្រៀន ត្រូវសម្របតាមសមត្ថភាពគិត យល់របស់អ្នកសិក្សា |




# ស្ថាបនានិយម

ស្ថាបនាសង្គមនិយម ឬ Social Constructivism ( Lev Vygotsky 1980s ) ខុសពី ស្ថាបនានិយម ត្រង់ថា ស្ថាបនានិយម ផ្តោតលើវិធីបង្កើត ឬ «ស្ថាបនា» ចំណេះដឹងរបស់បុគ្គលម្នាក់ៗតាមរយៈបទពិសោធន៍ផ្ទាល់ខ្លួនរបស់គេរៀងៗខ្លួន។ ចំណែកស្ថាបនាសង្គមនិយមវិញសង្កត់ធ្ងន់ត្រង់ថាចំណេះដឹងត្រូវតែបង្កើតឡើងដោយការប្រាស្រ័យទាក់ទងក្នុងសង្គម និងក្នុងបរិបទវប្បធម៌។ ស្ថាបនាសង្គមនិយម មានលក្ខណៈសំគាល់ដូចតទៅ៖

| | |
|---|---|
| ១ | អ្នករៀនបង្កើត ឬស្ថាបនាការយល់ និងចំណេះដឹងរបស់គេផ្ទាល់តាមរយៈបទពិសោធន៍ និងការប្រាស្រ័យទាក់ទងគ្នាក្នុងចំណោមអ្នកសិក្សា។ |
| ២ | ការផ្តោតសំខាន់គឺលើសារៈសំខាន់របស់អន្តរកម្មសង្គម និងការសហការគ្នាក្នុងចំណោមអ្នកសិក្សាទាំងអស់ ដើម្បីសម្របសម្រួលការយល់រួមគ្នារបស់អ្នកសិក្សាទាំងនោះ។ |
| ៣ | ក្នុងទ្រឹស្តីអប់រំនេះ ភាសាគឺត្រូវបានគេទទួលដឹងថាជាឧបករណ៍ដ៏សំខាន់មួយសម្រាប់ការប្រាស្រ័យទាក់ទងគ្នា និងសម្រាប់ការគិតពិចារណា។ ភាសាក៏ដើរតួសំខាន់សម្រាប់ការអភិវឌ្ឍមុខងារការពិចារណាផងដែរ។ |
| ៤ | ការរៀនត្រូវកើតឡើងនៅក្នុងបរិបទវប្បធម៌មួយដែលទទួលឥទ្ធិពលពីទំនោរទូទៅ តម្លៃ និងជំនឿរបស់សង្គម។ |
| ៥ | ការរៀនកើតឡើងក្នុងតំបន់អរូបីមួយដែលអ្នកស្រាវជ្រាវហៅថា «តំបន់កណ្តាលនៃការអភិវឌ្ឍ» ឬ Zone of Proximal Development ជាទី ឬពេលដែលអ្នករៀនអាចអនុវត្តកិច្ចការដែលគ្រូដាក់ឱ្យក្រោមការចង្អុលបង្ហាញពីអ្នកពាក់ព័ន្ធណាម្នាក់ និងបើគ្មានអ្នកចង្អុលបង្ហាញទេ គេមិនអាចធ្វើបានទេ |
| ៦ | គ្រូត្រូវផ្តល់ការជួយដល់សិស្ស ឬការដឹកដៃធ្វើ ដើម្បីឱ្យគេបានជួយខ្លួនឯងសម្រេចនូវសក្តានុពលរបស់គេក្នុង «តំបន់កណ្តាលនៃការអភិវឌ្ឍ» ឬ Zone of Proximal Development រហូតដល់គេអាចរៀនបានដោយឯករាជ្យ |
| ៧ | លើកទឹកចិត្តឱ្យពិចារណា និងប្រើប្រាស់ ទស្សនៈវិស័យចម្រុះប្រភេទ និងការបកស្រាយដែលសំបូរបែបដើម្បីពង្រឹងការយល់ដឹងរបស់គេ |
| ៨ | ការរៀនគឺមានឫសគល់ពីការងារពិតប្រាកដជាក់ស្តែង ( Authentic Tasks ) ដែលមានលក្ខណៈពាក់ព័ន្ធទៅនឹងជីវិតជាក់ស្តែងរបស់អ្នកសិក្សា |
| ៩ | លើកកម្ពស់ការគិតឆ្លុះបញ្ចាំងឡើងវិញ ដើម្បីឱ្យអ្នកសិក្សាអាចធ្វើឱ្យអ្វីដែលគេសិក្សាទៅក្នុងខ្លួន និងជីវិតរបស់គេ។ |
| ១០ | គ្រូដើរតួជាអ្នកសម្របសម្រួល ឬមគ្គុទេស ជាជាងអ្នកផ្ទេរចំណេះដឹង ដែលជាការលើកកម្ពស់បរិយាកាសសិក្សាបែបសិស្សមជ្ឈមណ្ឌល។ |



# ការរៀនតាមពិសោធន៍ផ្ទាល់




ការរៀនតាមពិសោធន៍ផ្ទាល់ ឬ Experiential Learning (Kolb 1984) គឺជាគោលវិធីដែលទាក់ទងការរៀនតាមរយៈសកម្មភាពជាក់ស្តែង ការឆ្លុះបញ្ចាំង និងការអនុវត្តជាក់ស្តែង។ ការរៀនតាមពិសោធន៍ផ្ទាល់មានលក្ខណៈសំគាល់ដូចតទៅ៖

| | |
|---|---|
| ១ | ផ្តោតលើអ្វីដែលអ្នកសិក្សាត្រូវការ ចាប់អារម្មណ៍ និងចង់ពិសោធន៍ផ្ទាល់ដើម្បីឱ្យគេអាចមានដំណើរនៃការសិក្សាដែលមានលក្ខណៈផ្ទាល់ខ្លួន |
| ២ | សិស្សគឺសកម្មក្នុងការរៀនរបស់គេខ្លួនឯង ទាំងការសួរសំណួរ ការសង្កេត និងពិសោធន៍ស្វែងរកចម្លើយ |
| ៣ | ឆ្លុះបញ្ចាំងស៊ីជម្រៅលើបទពិសោធន៍គឺជារឿងខានមិនបាន ព្រោះវានាំឱ្យសិស្សមានការយល់ដឹងកាន់តែជ្រាលជ្រៅ និងចាប់ផ្តើមសំយោគចំណេះដឹង |
| ៤ | សិស្សត្រូវបានលើកទឹកចិត្តឱ្យផ្តួចផ្តើមការរៀន ធ្វើការសម្រេចចិត្ត និងទទួលខុសត្រូវលើលទ្ធផលដែលគេសម្រេចបាន |
| ៥ | ការរៀនគឺផ្សារភ្ជាប់ផ្ទាល់ជាមួយស្ថានការណ៍ជាក់ស្តែងក្នុងជីវិតនិងការរស់នៅ ដែលជួយឱ្យសិស្សចេះចាំបានយូរអង្វែង និងកែលម្អភាពជាក់ស្តែងរបស់កិច្ចការ |
| ៦ | សិស្សត្រូវរៀនដោយធ្វើការជាមួយគ្នាដើម្បីដោះស្រាយការប្រឈម ការផ្តួចផ្តើម និងបញ្ហាដែលគេជួបប្រទះ ឬស្នើឡើងដើម្បីសិក្សា |
| ៧ | គោលវិធីរៀនតាមពិសោធន៍ផ្ទាល់ដោះស្រាយបញ្ហាប្រាជ្ញា ស្មារតី សង្គម និងរាងកាយរបស់អ្នកសិក្សា |
| ៨ | ការរៀនគឺផ្តោតលើការដោះស្រាយបញ្ហាតាមរយៈការធ្វើបកគំហើញ ការរិះរក និងការដោះស្រាយ ជាជាងទន្ទេញចាំរត់មាត់ |
| ៩ | កិច្ចការសិស្សធ្វើគឺត្រូវដូចគ្នា ឬស្រដៀងគ្នានឹងកិច្ចការក្នុងសង្គមជាក់ស្តែង ជាពិសេសភាពស្មុគ្រស្មាញរបស់វា |
| ១០ | អ្នករៀនទទួលយោបល់ត្រឡប់អំពីការអនុវត្តការងាររបស់គេ ហើយគេអាចសម្របគោលវិធីរបស់គេតាមជាក់ស្តែង |

# មនុស្សនិយម




មនុស្សនិយម ឬ Humanism (Carl Rogers et al. 1983); (Abraham Maslow) គឺជាគោលវិធីបែបសិស្សមជ្ឈមណ្ឌលមួយ ដែលសង្កត់ធ្ងន់លើភាពដោយឡែកៗរបស់អ្នករៀនម្នាក់ៗ និងសក្តានុពលដែលគេមានទីទៃៗពីគ្នា។ មនុស្សនិយម មានលក្ខណៈសំគាល់ដូចតទៅ៖

| | |
|---|---|
| ១ | ចំណុចផ្តោតគឺលើភាពដោយឡែករបស់សិស្សម្នាក់ៗ ជាមនុស្សម្នាក់ដែលមានការគិត ចំណូលចិត្តដោយឡែករបស់គេ ហើយអ្វីដែលសំខាន់គឺត្រូវបំពេញឱ្យបាននូវអ្វីដែលគេត្រូវការ ដើម្បីឆ្លើយតបការគិត ចំណូលចិត្ត និងវិធីរៀនរបស់គេម្នាក់ៗ |
| ២ | ការអប់រំមិនមែនគ្រាន់តែដើម្បីឱ្យមានការរីកចម្រើនផ្នែកបញ្ញាទេ ប៉ុន្តែត្រូវឱ្យរីកចម្រើនទាំងស្មារតី សតិអារម្មណ៍ សង្គម និងរាងកាយរបស់គេផងដែរ |
| ៣ | លើកទឹកចិត្តសិស្សឱ្យរៀនសូត្រ ដើម្បីជាប្រយោជន៍នៃការរៀនសូត្រនេះផង និងដើម្បីការរីកចម្រើនជាលក្ខណៈ ឬជាកម្រិតបុគ្គលផង មិនមែនតែដើម្បីពិន្ទុ ឬលទ្ធផលសិក្សាដែលល្អទេ (Intrinsic Motivation) |
| ៤ | ជួយសិស្សឱ្យសម្រេចបានភាពជាមនុស្សពេញលេញរបស់គេ (Self Auctualization) |
| ៥ | គ្រូត្រូវយកគិតពីការគិត និងស្ថានភាពរបស់សិស្សជាគោល ហើយគោរពគេជាមនុស្សម្នាក់ដែលមានគំនិត និងអារម្មណ៍របស់គេ |
| ៦ | គ្រូដើរតួជាអ្នកសម្របសម្រួល ឬជាមគ្គុទេសន៍ ជាជាងបុគ្គលដែលមានអំណាចបែបប្រពៃណី ហើយត្រូវលើកទឹកចិត្តឱ្យមានការរិះរក និងសាកល្បងអ្វីថ្មី |
| ៧ | ត្រូវបង្កើតឱ្យមានបរិយាកាសដែលអំណោយផល និងគាំទ្រដល់ការរៀន ហើយមិនត្រូវរំខាន ឬបង្អាក់ការរៀនទេ |
| ៨ | សិស្សមានសេរីភាពពេញលេញក្នុងការរៀនសូត្រ (គេអាចជ្រើសរើសអ្វីដែលគេចង់រៀន វិធីបង្រៀន និងរៀន ពេលណាត្រូវរៀន ជាការលើកកម្ពស់ និងបណ្តុះនូវស្វ័យភាព និងទំនួលខុសត្រូវពេញលេញរបស់គេ) |
| ៩ | យោបល់ត្រឡប់ត្រូវមានលក្ខណៈដោយឡែកសម្របតាមភាពដោយឡែកៗរបស់សិស្សម្នាក់ៗ ដើម្បីគាំទ្រការរីកចម្រើនរបស់សិស្សជាមនុស្សម្នាក់ |
| ១០ | ថ្នាក់រៀនត្រូវមានលក្ខណៈប្រជាធិបតេយ្យ ត្រង់ថាសម្លេង យោបល់ និងតម្លៃរបស់សិស្សម្នាក់ត្រូវតែទទួលបានការយកចិត្តទុកដាក់ខ្ពស់បំផុត |

## ប្រយោលនិយម




ប្រយោលនិយម ឬ Pragmatism ( John Dewey 1859-1952 ) ក្នុងបរិបទអប់រំផ្តោតលើភាពជាក់ស្តែង និងបទពិសោធន៍ផ្ទាល់ ដែលអាចយកមកច្របាច់បញ្ចូលក្នុងសកម្មភាពបង្រៀន និងរៀនប្រកបដោយប្រសិទ្ធភាព។ ប្រយោលនិយមមានលក្ខណៈសំគាល់ដូចតទៅ៖

| | |
|---|---|
| ១ | ត្រូវធានាថាសម្ភារៈឧបទេស និងឯកសារបង្រៀន និងរៀនទាំងអស់មានសារៈប្រយោជន៍ និងជាប់ពាក់ព័ន្ធដល់ជីវិតរបស់សិស្ស ដើម្បីឱ្យសិស្សអាចផ្សារភ្ជាប់បាន និងមានចិត្តចង់រៀន។ |
| ២ | ត្រូវច្របាច់បញ្ចូលចំណាប់អារម្មណ៍របស់សិស្សទៅក្នុងកម្មវិធីសិក្សាលម្អិត ដូចជាការសន្ទនា ការអង្កេត ការពង្រីកគំនិតបន្ត និងការបញ្ចេញមតិយោបល់នានា នឹងធ្វើឱ្យមេរៀន និងការរៀនកាន់តែមានភាពទាក់ទាញ |
| ៣ | ត្រូវផ្តោតលើការរៀនតាមការបង្កើតឱ្យមានបទពិសោធន៍ផ្ទាល់ តាមរយៈសកម្មភាពរៀន ឬការធ្វើពិសោធន៍ជាគម្រោង ធ្វើយ៉ាងណាឱ្យសិស្សរៀនតាមរយៈការអនុវត្តផ្ទាល់ |
| ៤ | ផ្សារភ្ជាប់បញ្ញតិពីមេរៀន និងមុខវិជ្ជាផ្សេងៗដើម្បីឱ្យមានចំណេះដឹង និងការយល់ជារួមមួយ ទាក់ទងទៅនឹងជីវិត និងពិភពលោកជាក់ស្តែង |
| ៥ | ផ្តោតលើការប្រើប្រាស់ចំណេះដឹងក្នុងសង្គម និងជីវិតជាក់ស្តែងហើយគ្រូបង្រៀនត្រូវសម្របវិធីសាស្ត្របង្រៀនឱ្យស្របតាមតម្រូវការជាក់ស្តែងរបស់សិស្ស ត្រៀមពួកគេឱ្យចេះដោះស្រាយបញ្ហាជាក់ស្តែងក្នុងជីវិត និងសង្គម |
| ៦ | គ្រូដើរតួជាអ្នកសម្របសម្រួល និងជាមគ្គុទេសន៍ការរៀន ជួយសិស្សឱ្យរៀន និងចេះគិតវិភាគស៊ីជម្រៅបានដោយខ្លួនឯង |
| ៧ | ត្រូវផ្តល់ឱកាសឱ្យបានច្រើនសម្រាប់សិស្សបានអនុវត្តផ្ទាល់លើខ្លឹមសារដែលរៀន ឬដោះស្រាយបញ្ហាជាក់ស្តែងក្នុងបរិបទជីវិត និងសង្គម ធ្វើយ៉ាងណាឱ្យគេរៀនដោយមិនដឹងខ្លួន |
| ៨ | លើកទឹកចិត្តការងារជាក្រុម ឬរៀនជាមួយដៃគូ ដើម្បីឱ្យគេពូកែទំនាក់ទំនង និងពិភាក្សាដោះស្រាយបញ្ហាជាមួយគ្នា |
| ៩ | លើកកម្ពស់ការយល់ដឹងថាបញ្ហាក្នុងជីវិត និងសង្គមជាក់ស្តែងកើតឡើងពីប្រភពច្រើនជាងមួយ ហើយការដោះស្រាយក៏ត្រូវមើលឱ្យច្រើនជាមួយប្រភពដែរ ដូចនេះការរៀនគឺត្រូវសំយោគមេរៀន និងមុខវិជ្ជាផ្សេងៗជាមួយគ្នា |
| ១០ | ទ្រឹស្តីប្រយោលនិយមមិនជឿថា គោលបំណងនៃការអប់រំ គឺត្រូវកំណត់ទុកជាមុនទេ |

## ឥន្ទ្រិយារម្មណ៍និយម




ឥន្ទ្រីយារម្មណ៍និយម ឬ Sensory Theory ( Laird 1985 ) ជាទ្រឹស្តីអប់រំដែលផ្តោតលើសារៈសំខាន់ក្នុងការប្រើប្រាស់ឥន្ទ្រីយារម្មណ៍ទាំងអស់ ឬវិញ្ញាណទាំងអស់ (កាយវិញ្ញាណ ចក្ខុវិញ្ញាណ ឃានវិញ្ញាណ ជីវ្ហាវិញ្ញាណ សោតវិញ្ញាណ) របស់អ្នកសិក្សា ដើម្បីលើកកម្ពស់ការរៀន និងការយល់ដឹងរបស់គេ។ ឥន្ទ្រីយារម្មណ៍និយមមានលក្ខណៈសំគាល់ដូចតទៅ៖

| | |
|---|---|
| ១ | ការរៀនតាមពហុវិញ្ញាណ៖ សិស្សត្រូវប្រើប្រាស់វិញ្ញាណទាំងអស់របស់គេ រួមទាំងការធ្វើសកម្មភាព និងចលនាដើម្បីបង្កើតជាបរិយាកាសសិក្សាដែលសមប្រកបបំផុតសម្រាប់ការសិក្សា |
| ២ | ការចូលរួមសកម្ម៖ សិស្សត្រូវចូលរួមសកម្មជានិច្ច ដើម្បីរៀនតាមរយៈការអនុវត្តផ្ទាល់ ហើយត្រូវប្រើឱ្យអស់នូវវិញ្ញាណរបស់គេ |
| ៣ | ការយល់ដឹងកម្រិតខ្ពស់៖ សិស្សយល់ ចេះ និងដឹងក្នុងកម្រិតខ្ពស់កាលណាគេបានប្រើប្រាស់វិញ្ញាណរបស់គេទាំងអស់ក្នុងការបកប្រែធាតុចូល ឬរំញោចឱ្យចេញជាចំណេះដឹង |
| ៤ | ការអភិវឌ្ឍពេញលេញ៖ គ្រប់ភាគីពាក់ព័ន្ធត្រូវដឹងពីសារៈសំខាន់ និងតួនាទីរបស់វិញ្ញាណទាំងអស់ដែលមនុស្សម្នាក់ៗមាន និងពិសោធន៍នានាដែលបង្កើតឡើងតាមការប្រើប្រាស់វិញ្ញាណទាំងអស់នោះ រួមទាំងបញ្ញាការគិត រាងកាយ និងសតិអារម្មណ៍ផងដែរ |
| ៥ | ការអប់រំបរិយាប័ន្ន៖ ប្រើវិធីសាស្ត្រពហុវិញ្ញាណជួយឱ្យអ្នកសិក្សាដែលមានលក្ខណៈពិសេសដោយឡែកៗរបស់គេបានទទួលឱកាសក្នុងការបង្កើតចំណេះដឹង និងការយល់ដឹងបានពេញលេញ |
| ៦ | បរិយាកាសសិក្សាដែលផ្តល់ការរំញោចដល់វិញ្ញាណ៖ បរិយាកាសិក្សាត្រូវតែមានលទ្ធភាពផ្តល់រំញោចផ្សេងៗរបស់អ្នកសិក្សា តែមិនត្រូវរំញោចខ្លាំងជ្រុល និងធ្វើឱ្យសិស្សបែកអារម្មណ៍ទេ |
| ៧ | គ្រូជាអ្នកសម្របសម្រួល៖ គ្រូនាំផ្លូវសិស្សរៀន ដោយប្រើប្រាស់វិញ្ញាណទាំងអស់ដែលសិស្សមាន និងផ្តល់សម្ភារៈឧបទេស និងឱកាសសមស្រប |
| ៨ | ចង្វាក់សិក្សាបែបធម្មជាតិ៖ ត្រូវគោរពល្បឿនធម្មជាតិនៃការសិក្សា ហើយត្រូវចៀសវាងការប្រើប្រាស់វិធីផ្សេងៗ ដែលបង្ខំសិស្សឱ្យរហ័សផលិតលទ្ធផលសិក្សាពេក |
| ៩ | ការរៀនបែបស្រមើស្រមៃ៖ លើកទឹកចិត្តសិស្សឱ្យចេះស្រមើស្រមៃ និងមានការគិតបែបចំរុះតាមរយៈការបង្កើតបទពិសោធន៍ដែលប្រើប្រាស់វិញ្ញាណទាំងអស់ដែលគេមាន |
| ១០ | ការចូលរួមរបស់មាតាបិតា៖ ផ្តល់ឱកាសឱ្យមាតាបិតាសិស្សបានចូលរួមក្នុងការដឹងដោយវិញ្ញាណផងដែរនូវអ្វីដែលសិស្សត្រូវធ្វើនៅផ្ទះទាក់ទងការសិក្សារបស់គេ |

# តំណភ្ជាប់និយម




តំណភ្ជាប់និយម ឬ Connectivism ( William James ( 1842 to 1910 ); Charles Sanders Peirce ( 1839 to 1914 ); George H. Mead ( 1863 to 1931 ); John Dewey ( 1859 to 1952 ); W.V. Quine ( 1908 to 2000 ); C.I. Lewis ( 1883 to 1964 ) ) មានលក្ខណៈសំគាល់ដូចតទៅ៖

| | |
|---|---|
| ១ | ចំណេះដឹងគឺជាផលិតផលនៃការតភ្ជាប់ជាបណ្តាញរវាងធាតុចូល និងចម្លើយ របស់អ្នកសិក្សា |
| ២ | បច្ចេកវិទ្យាដើរតួសំខាន់ក្នុងការសិក្សារៀនសូត្រ និងចែករំលែកការសិក្សារៀនសូត្រ |
| ៣ | ការរៀនកើតឡើងតាមរយៈការភ្ជាប់ខ្លឹមសារ (ព័ត៌មាន ឬធាតុចូល) ត្រូវរៀនឈានទៅការស្ថាបនាចំណេះដឹង និងក្រោយ បំផុតការពង្រីកចំណេះដឹង |
| ៤ | ដើម្បីចំណេះដឹងអាចកើតឡើងបាន ការដំណើការព័ត៌មាន ឬធាតុចូល ត្រូវតែយកលំនាំតាមរបៀបដែលកោសិកាខួរក្បាល និងខួរក្បាលដំណើរការដែរ |
| ៥ | ការរៀនត្រូវផ្តោតលើការបង្កើត ឬសំគាល់គំរូ (ទាមទារឱ្យធ្វើសកម្មភាពដដែលៗច្រើនដង) ហើយដែលអាចសម្របទទួលព័ត៌មាន ឬធាតុចូលថ្មី |
| ៦ | ការដំណើការព័ត៌មាន ឬធាតុចូល គឺអាស្រ័យលើធាតុផ្សំដែលសាមញ្ញៗ |
| ៧ | ចំណេះដឹង ឬ «ប្រព័ន្ធ» កើតឡើងពេលណាដំណោះស្រាយមួយត្រូវបានរកឃើញ ( តំណភ្ជាប់សសៃប្រសាទ ត្រូវបានបង្កើតឡើង ) |
| ៨ | ការតភ្ជាប់ព័ត៌មាន ឬធាតុចូល អាចកើតឡើងច្រើនក្នុងពេលតែមួយ ( Parallel Distriubuted Processing ) |
| ៩ | ភាពខ្លាំងនៃការភ្ជាប់គ្នារវាងព័ត៌មាន ឬធាតុចូល អាចផ្លាស់ប្តូរ មិននៅថេរហូតទេ អាស្រ័យលើភាពញឹកញាប់នៃការទទួលព័ត៌មាន ឬធាតុចូល និងវិធីផ្តល់យោបល់ត្រឡប់ |
| ១០ | តំណភ្ជាប់កម្រិតខ្ពស់អាចកើតឡើងបានលុះត្រាតែតំណភ្ជាប់កម្រិតទាបមានច្រើន និងមាំទាំ |

# ទ្រឹស្តីសកម្មភាព




ទ្រឹស្តីសកម្មភាព ឬ Activity Theory ( Lev Vygotsky, Alexei Leont'ev and Sergei Rubinstein; 1980s ) គឺជាក្របខណ្ឌទូលាយដែលត្រូវបានប្រើប្រាស់សម្រាប់សិក្សាប្រព័ន្ធផ្សេងៗ ដូចជាសកម្មភាពនានារបស់មនុស្សក្នុងបរិបទវប្បធម៌និងសង្គម។ ទ្រឹស្តីនេះមានលក្ខណៈសំគាល់ដូចតទៅ៖

| | |
|---|---|
| ១ | ទ្រឹស្តីសកម្មភាពគឺផ្តោតលើបញ្ញតិនៃវត្ថុមួយ ឬវត្ថុបំណងមួយដែលបណ្តាលចិត្តឱ្យមានជាសកម្មភាព។ មេរៀនត្រូវមានគោលបំណង និងវត្ថុបំណង ដែលគាំទ្រដោយសកម្មភាពនានាច្បាស់លាស់។ |
| ២ | ទ្រឹស្តីសកម្មភាពផ្តោតលើតួនាទីរបស់វត្ថុ និមិត្តសញ្ញា និងឧបករណ៍ដែលមានតម្លៃវប្បធម៌ ក្នុងការសម្របសម្រួលសកម្មភាព។ ក្នុងការរៀន និងការបង្រៀន គ្រូត្រូវប្រើសម្ភារៈឧបទេសដែលមានតម្លៃវប្បធម៌ ដើម្បីឱ្យសិស្សរៀនបានជក់ចិត្ត និងការបង្រៀនមានប្រសិទ្ធភាព។ |
| ៣ | ទ្រឹស្តីសកម្មភាពយកចិត្តទុកដាក់លើកិច្ចការជារួម ឬប្រព័ន្ធសកម្មភាព ដោយរួមបញ្ចូលទាំងការធ្វើការជាក្រុម និងជាអង្គភាព មិនមែនផ្តោតលើតែបុគ្គលម្នាក់ទេ។ ការបង្រៀន និងរៀនត្រូវផ្តោតលើសកម្មភាពជាក្រុម ដូចក្នុងសង្គមវប្បធម៌ជាក់ស្តែង។ |
| ៤ | ទ្រឹស្តីសកម្មភាពយកចិត្តទុកដាក់លើប្រវត្តិនៃការរីកចម្រើនរបស់សកម្មភាព និងវិធីដែលសកម្មភាពទាំងនេះវិវត្តន៍ |
| ៥ | សកម្មភាពរបស់មនុស្សត្រូវកើតឡើងក្នុងរង្វង់បរិបទសង្គម ហើយត្រូវសង្កេតលើឥទ្ធិពលដែលកត្តាសង្គមមានលើសកម្មភាពទាំងនេះ។ សកម្មភាពរៀន និងបង្រៀន ត្រូវតែឆ្លុះបញ្ចាំងតថភាពនៃសង្គមជាក់ស្តែង ដើម្បីជាការលើកទឹកចិត្តសិស្សឱ្យមានជំនាញ និងបំណិនដែលអាចយកទៅប្រើប្រាស់បានក្នុងសង្គមជាក់ស្តែងដែរ។ |
| ៦ | គ្រូអាចប្រើប្រាស់វិធីផ្ទុយក្នុងការជ្រើសរើសធនធាន ឬឯកសារបង្រៀន ដើម្បីឱ្យសិស្សរៀនគិត វិភាគ និងពិភាក្សាបានស៊ីជម្រៅ។ |
| ៧ | មេរៀននានាត្រូវរៀបចំឡើងដើម្បីលើកទឹកចិត្តសិស្ស និងរាវរកគំនិតថ្មីៗ លើកកម្ពស់ភាពច្នៃប្រឌិត និងនវានុវត្តន៍។ |
| ៨ | សកម្មភាពរៀន និងបង្រៀននានាត្រូវបញ្ចូលនូវទស្សនៈផ្សេងៗ ដើម្បីជួយសិស្សឱ្យយល់ឬសគល់បញ្ហាថាមិនមែនសាមញ្ញដូចមើលឃើញពីសំបកក្រៅទេ ធ្វើដូចនេះសិស្សនឹងមានបំណិនទន់ ចេះយល់ចិត្តអ្នកផ្សេងទៀត និងមិនរហ័សវាយតម្លៃមនុស្ស ឬស្ថានការណ៍ |
| ៩ | ការប្រើប្រាស់បច្ចេកវិជ្ជា និងសម្ភារៈឧបទេសជំនួយការរៀន និងបង្រៀនក្នុងថ្នាក់រៀន នឹងជួយឱ្យការរៀន និងយល់របស់សិស្សកើតឡើងបានងាយស្រួលជាងមុន ហើយបន្ថយគម្លាតរវាងទ្រឹស្តីនិងការអនុវត្តផ្ទាល់ |
| ១០ | គ្រូបង្រៀនត្រូវគិតពីគោលដៅនៃការអប់រំទាំងមូល គ្រូនឹងអាចកំណត់បាន និងដោះស្រាយបញ្ហានានាដែលជះឥទ្ធិពលមិនល្អដល់ការរៀន និងបង្រៀន |

## វិធីសាស្ត្រត្រាប់តាម




| | |
|---|---|
| ១ | ណែនាំសិស្សឱ្យស្គាល់ពីវិធីសាស្ត្រត្រាប់តាម៖ ចាប់ផ្តើមដោយពន្យល់ពីបញ្ញត្តិនៃវិធីសាស្ត្រធ្វើត្រាប់តាមឱ្យសិស្សបានយល់។ សិស្សត្រូវមើល ឬស្តាប់គ្រូជាគំរូ មុននឹងគេអាន ឬសូត្រ ឬធ្វើតាមរហូតរត់មាត់ ឬចាំស្ទាត់ |
| ២ | បង្ហាញជាគំរូ៖ គ្រូធ្វើជាគំរូមុន (អាន ឬធ្វើឱ្យមើល) មួយៗ និងច្បាស់ៗ ដើម្បីឱ្យសិស្សមើលហើយត្រៀមធ្វើតាម។ |
| ៣ | ត្រាប់តាមជាក្រុម៖ បន្ទាប់ពីការបង្ហាញរបស់គ្រូ សិស្សទាំងអស់គ្នាចាប់ផ្តើមធ្វើតាមគ្រូដំណាកគ្នាតែម្តង។ ការធ្វើរួមគ្នាគឺដើម្បីកុំឱ្យសិស្សភ័យ ឬខ្លាចពីការធ្វើខុស។ ជាទូទៅគ្រូជាអ្នកផ្តល់ចង្វាក់សម្រាប់សិស្សធ្វើតាមរួមគ្នានេះ។ |
| ៤ | ត្រាប់ជាបុគ្គល៖ បន្ទាប់ពីធ្វើត្រាប់តាមជាក្រុមហើយ សិស្សចាប់ផ្តើមមានទំនុកចិត្ត និងសេចក្តីក្លាហានអាចធ្វើត្រាប់តាមម្តងម្នាក់ៗ។ ការធ្វើដូចនេះ គ្រូមានឱកាសកែកំហុស បើមាន នៅកម្រិតបុគ្គល។ |
| ៥ | ត្រាប់ដោយជំនួសពាក្យគន្លឹះ៖ គ្រូអាចប្តូរពាក្យគន្លឹះ ដោយចង្អុរ ឬលើកបង្ហាញ ហើយសិស្សអាន ឬធ្វើតាមដោយជំនួសពាក្យចាស់ជាមួយពាក្យគន្លឹះថ្មីដែលគ្រូលើកបង្ហាះញ ឬចង្អុល។ |
| ៦ | ត្រាប់ជាសំណួរចម្លើយ៖ ប្រើសំណួរនិងចម្លើយ ហើយសួរឆ្លើយដោយវិធីត្រាប់តាមស្រដៀងគ្នានឹងអ្វីដែលបានធ្វើពីខាងដើមមក។ |
| ៧ | យោបល់ត្រឡប់ និងកែកំហុស៖ គ្រូកែកំហុសភ្លាមៗ និងផ្តល់យោបល់ត្រឡប់ភ្លាមៗដែរ ដើម្បីជានាឱ្យបានសុក្រិតភាពនៃការរៀន។ នេះជាចំណុចសំខាន់ដើម្បីបង្កើតជាទម្លាប់ និងនាំឱ្យសិស្សពូកែខាងផ្នែកភាសាផងដែរ។ |
| ៨ | ហាត់ត្រាប់ជាគូ និងជាក្រុម៖ គ្រូលើកទឹកចិត្តសិស្សឱ្យហាត់ត្រាប់ក្នុងលក្ខណៈជាគូៗ និងក្រោយមកប្របាច់ពីរគូ ឬបីគូចូលគ្នាជាក្រុម ហើយបន្តហាត់ត្រាប់។ |
| ៩ | បង្កើនកម្រិតលំបាក៖ ពេលសិស្សចាំរត់មាត់អ្វីដែលគេត្រូវរៀនកម្រិតងាយស្រួលហើយ គ្រូបង្កើនកម្រិតលំបាក ហើយចាប់ផ្តើមធ្វើដូចពីខាងដើមមកជាថ្មី។ អ្វីដែលត្រូវធ្វើគឺធ្វើយ៉ាងណាឱ្យការត្រាប់តាមនេះមានលក្ខណៈធម្មជាតិ និងមិនដូចមនុស្សយន្តពេក។ |
| ១០ | វាយតម្លៃ៖ យូរម្តងត្រូវឱ្យសិស្សសូត្រឡើងវិញអ្វីដែលគេបានរៀនចេះរួចហើយ ដើម្បីកុំឱ្យគេភ្លេច និងដើម្បីឱ្យគេកាន់តែចេះច្បាស់។ បន្ទាប់មកនាំសិស្សឆ្លុះបញ្ចាំងឡើងវិញពីវិធីរៀន និងបង្រៀនតាំងជំហ៊ានទី១ រហូតដល់ជំហ៊ានបន្តបន្ទាប់ ដើម្បីកែលម្អការរៀន និងបង្រៀន។ |

## វិធីសាស្ត្ររៀនជាគម្រោង




| | |
|---|---|
| ១ | ចាប់ផ្តើមដោយមានគោលដៅបញ្ចប់ច្បាស់លាស់៖ កំណត់វត្ថុបំណងនៃការបង្រៀន និងរៀន ក៏ដូចជាលទ្ធផលសិក្សារំពឹងទុកដែលសិស្សត្រូវសម្រេចឱ្យបាននៅពេលចប់ការងារគម្រោងនីមួយៗឱ្យបានច្បាស់លាស់ |
| ២ | ជ្រើសរើសបញ្ហា ឬសំណួរ៖ ចូរជ្រើសរើសបញ្ហា ឬសំណួរដ៏ប្រកបដោយអត្ថន័យជាក់ស្តែងមួយដែលការសិក្សាជាគម្រោងត្រូវដោះស្រាយ ដោយនាំសិស្ស និងអ្នកពាក់ព័ន្ធចូលរួមអនុវត្ត |
| ៣ | ត្រៀមជំហ៊ានអនុវត្ត៖ រៀបផែនការលម្អិតសម្រាប់ការរៀនជាគម្រោង ដោយបញ្ជាក់ច្បាស់តាំងពីពេលវេលា ធនធានត្រូវការ និងតួរនាទីរបស់សិស្ស គ្រូ និងរាល់ភាគីពាក់ព័ន្ធ |
| ៤ | សម្របសម្រួលការរិះរកជាប់ជាប្រចាំ៖ ដឹកនាំសិស្សអនុវត្តដំណើរការលម្អិត (Extended Process) នៃការចោទសួរប្រដេញប្រភពបញ្ហា កំណត់ធនធាន ប្រើប្រាស់ព័ត៌មានដោះស្រាយ ហើយសម្របតាមជាក់ស្តែង ដើម្បីឱ្យយល់ស៊ីជម្រៅ |
| ៥ | ពិនិត្យតាមដាន និងគាំទ្រ៖ ត្រួតពិនិត្យជាប្រចាំដំណើរការអនុវត្តជាក់ស្តែងរបស់សិស្ស ហើយផ្តល់ការគាំទ្រដែលចាំបាច់នានាដល់សិស្សក្នុងការអនុវត្តកិច្ចការ ឬសកម្មភាពគម្រោង ធ្វើយ៉ាងណាឱ្យគេមិនខុសផ្លូវ និងខាតពេលវេលា |
| ៦ | វាយតម្លៃលទ្ធផល៖ អ្វីដែលសិស្សសម្រេចបានជាជំហ៊ានៗត្រូវតែទទួលការវាយតម្លៃជាបណ្តើរៗពីអ្នកដឹកនាំគម្រោង ហើយត្រូវផ្តោតលើដំណើរការអនុវត្តជាក់ស្តែង និងលទ្ធផលទទួលបានបណ្តើរៗ និងលទ្ធផលសម្រេចចុងក្រោយ |
| ៧ | ឆ្លុះបញ្ចាំងពីបទពិសោធន៍៖ លើកទឹកចិត្តសិស្សឱ្យឆ្លុះបញ្ចាំងពីបទពិសោធន៍ការសិក្សារៀនសូត្ររបស់គេ។ ការឆ្លុះបញ្ចាំងគឺជាផ្នែកសំខាន់សម្រាប់គ្រូបង្រៀន និងអ្នកបណ្តុះបណ្តាលគ្រូបង្រៀន ក្នុងការកែលម្អបំណិនសម្របសម្រួលការអនុវត្តការរៀនជាគំរោង |
| ៨ | បង្ហាញជាសាធារណៈ៖ ផ្តល់ឱកាសដល់សិស្សទាំងអស់គ្នាដើម្បីធ្វើបទបង្ហាញការងារ និងលទ្ធផលដែលគេសម្រេចបានជាសាធារណៈ។ ការធ្វើដូចនេះ និងធ្វើឱ្យគេបានទទួលធាតុចូលពីសាធារណៈជនមកវិញផង និងបានកែលម្អបំណិនធ្វើបទបង្ហាញរបស់គេផង |
| ៩ | កែសម្រួល និងកែលម្អ៖ យកធាតុចូលពីគ្រប់ភាគីពាក់ព័ន្ធមកដឹកនាំសិស្សកែសម្រួលវិធីអនុវត្តកិច្ចការ និងការងារគម្រោង ដើម្បីឱ្យការយល់របស់គេកាន់តែមានគុណភាពល្អប្រសើរឡើង។ |







រូបភាពទី...៖ លំដាប់លំដោយ និងសមាសធាតុនៃវិធីសាស្រ្ត គោលវិធី ឌីសាញ និងជំហ៊ានរបស់ លោក ជេគ រីឆាតស៍ និង ធីអូដរ៍ រ៉ចែរស៍ (២០០១)


ទម្រង់កិច្ចតែងការ
Method
Approach
Design
Procedure
វិធីសាស្ត្រ
គោលវិធី
ឌីសាញ
កិច្ចតែងការ (លំដាប់លំដោយសកម្មភាពរៀន និងបង្រៀន)
ទ្រឹស្ដីនៃចំណេះដឹង
ទ្រឹស្ដីការរៀនសូត្រចំណេះដឹង
១.គោលបំនង និងវត្ថុបំណង ២.គំរូកម្មវិធីសិក្សាលម្អិត ៣. សកម្មភាពរៀន និងបង្រៀន
៤.តួនាទីសិស្ស ៥.តួនាទីគ្រូ ៦.តួនាទីឯកសារជំនួយការរៀន សម្ភារៈឧបទេស


សំណួរ-ចម្លើយ




ខ្ញុំបាទ ប្រាក់ ឧុទ្ធី នាយកវិទ្យាល័យ
សម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន ព្រែកតាទែន
ភូមិព្រែកក្តី ឃុំព្រែកតាទែណ ស្រុកពញាឮ ខេត្តកណ្តាល

**ប្រវត្តិការសិក្សា**

- សញ្ញាបត្របមធ្យមសិក្សាកំរិត១ (១៩៨៦)
- បញ្ចប់ការបណ្តុះបណ្តាលគ្រូ(៧+៣) (១៩៨៨)
- សញ្ញាបត្រមធ្យមសិក្សាគរុកោសល្យ (១៩៩៤)
- បរិញ្ញាបត្រ វិទ្យាសាស្ត្រអប់រំ (២០០៧)
- សាលាភូមិន្ទរដ្ឋបាល វិញ្ញាបនបត្របញ្ជាក់ការសិក្សា (២០១៨)

(បានទទួលការបណ្តុះបណ្តាលឯកទេស **រដ្ឋបាលទូទៅ** រយៈពេល៩០ម៉ោងដោយជោគជ័យ)

- បរិញ្ញាបត្រ ភារគណៈគ្រប់គ្រងតាមសាលារៀន (២០២១)

**ស្នាដៃការងារ**

- មេដៃមាសការងារ (បីគ្រឿង)

គ្រូបង្រៀន១គ្រឿង នាយក១គ្រឿង ការងារសង្គម១គ្រឿង

**ទូរស័ព្ទ៖** 012 281 581






**វិទ្យាល័យសម្តេចអគ្គមហាសេនាបតី តេជោហ៊ុន សែន ព្រែកតាទែន**

មានទីតាំងនៅភូមិព្រែកក្តី ឃុំព្រែកតាទែន

ស្រុកពញាឮ ខេត្តកណ្តាល

មានចម្ងាយ២១គីឡូម៉ែត្រពីរាជធានីភ្នំពេញ

តាមដងផ្លូវលេខជាតិ៥

ឆ្នាំ១៩៨៨ដល់១៩៩១ជាសាលាឧបសម្ពន្ធសាលាកំរិត១ព្រែកព្នៅ

ឆ្នាំ១៩៩១ដល់២០១១ ជាអនុវិទ្យាល័យ

ឆ្នាំ២០១១ដល់បច្ចុប្បន្ន ជាវិទ្យាល័យ

## សាលារៀនមានប្រសិទ្ធភាព( ៥ស្តង់ដា )

### ប្រធានបទ

### VIII. ការបង្រៀន និងរៀនតាមប្រើឌីជីថល

I.សេចក្តីផ្តើម

II.គោលបំណង

III.សកម្មភាព

IV.សេចក្តីសន្និដ្ឋាន

## I.សេចក្តីផ្តើម

វិទ្យាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ព្រែកតាទែន ជាកន្លែងទទួលសិស្សឱ្យចូលរៀនចាប់ពីថ្នាក់ទី៧ ដល់ថ្នាក់ទី១២ ទៅតាមកម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា។ដើម្បីឆ្លើយតបតាមការរីកចំរើនផ្នែកវិទ្យាសាស្ត្រ វិទ្យាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ព្រែកតាទែន បានរៀបចំការបង្រៀន និងរៀនតាមប្រើឌីជីថល ។

## II.គោលបំណង

ឱ្យគ្រូបង្រៀន ប្រើវិធីបង្រៀនបែបថ្មី ដោយឱ្យមេរៀន(សន្លឹកកិច្ចការ)សិស្សយកទៅរៀនមុន តាមផ្ទាល់ ឬតាមប្រព័ន្ធអនឡាញ គ្រូបង្រៀនគ្រាន់តែសម្របសម្រួលលើខ្លឹមសារមេរៀនបន្ថែមដល់សិស្សមិនទាន់យល់។

ឱ្យសិស្សចេះរៀនដោយខ្លួនឯងមុន (សន្លឹកកិច្ចការ) នឹងមកជួបគ្រូបង្រៀន សិស្សចេះឆ្លើយសំណួរ ដោះស្រាយលំហាត់ សិស្សហ៊ានឡើងបកស្រាយមេរៀន។

III.**សកម្មភាព**

## VIII. ការបង្រៀន និងរៀនតាមប្រើឌីជីថល

*__កិច្ចការគ្រូបង្រៀន__*

*១. គ្រូមុខវិជ្ជាត្រូវស្វ័យសិក្សាសន្លឹកកិច្ចការទាំង៥ផ្នែក ដូចសិស្សដែរ ដើម្បី៖ ក)បានស្វែងយល់ពីសារៈសំខាន់ និងផលប្រយោជន៍របស់ឯកសារក្នុងការបង្វឹកសិស្សឱ្យចេះរៀនពីរបៀបរៀនដោយខ្លួនឯងជំនួសការដាស់តឿន និងប្រាប់ពីគ្រូ និងសមាជិកគ្រួសារ ខ) បានយល់ខ្លឹមសារមេរៀន និងលំនាំបង្រៀន ពីសន្លឹកកិច្ចការទាំង៥ប្រភេទ គ)បានរៀនពីវិធីសាស្ត្របង្រៀនមួយចំនួន សម្រាប់ជួយសិស្សចេះស្វ័យសិក្សា និងការបង្រៀនដោយប្រើឌីជីថល*

*២. គ្រូមុខវិជ្ជាត្រូវជួយកែសម្រួល លំនាំបង្រៀន និងខ្លឹមសារមេរៀន ដើម្បីបំពេញបន្ថែម ឱ្យបានសមស្របជាមួយស្ថានភាពសិស្ស និងថ្នាក់រៀនរបស់គាត់*

*៣. គ្រូមុខវិជ្ជាអាចចូលរួមផលិតឯកសារជួយសិស្សរៀន និងជួយគ្រូបង្រៀន ដើម្បីបានរៀនសូត្រពីវិធីបង្រៀនថ្មីៗទៀត ដូចជា៖ ការរៀនសម្របតាមសិស្ស*

*__កិច្ចការសិស្ស__*

*__១. ដំណាក់កាលទី១__៖ គ្រូបង្រៀនមុខវិជ្ជាផ្ដល់ (ក)សន្លឹកកិច្ចការទន់ដែលបានផលិត ដោយក្រុមការងារបច្ចេកទេសក្រសួង និងក្រុមបច្ចេកទេសមហាវិទ្យាល័យអប់រំ សម្របសម្រួលដោយក្រុមបច្ចេកទេសនាយកដ្ឋានធានាគុណភាព និងផ្នែកពាក់ព័ន្ធ) សម្រាប់សិស្សស្វ័យសិក្សាក្នុងមួយឆ្នាំសិក្សា ដើម្បីសិស្សបានរៀនមុនពេលរៀនជាមួយគ្រូផ្ទាល់ និង(ខ) សន្លឹកកិច្ចការថតចម្លង មួយខែម្តងសម្រាប់សិស្សដែលមិនទាន់មានឧបករណ៍បច្ចេកវិទ្យា ដើម្បីបានរៀនមុនពេលរៀនជាមួយគ្រូបង្រៀនផ្ទាល់។ __គ្រូត្រូវផ្តល់ព័ត៌មានត្រឡប់ទៅសិស្សវិញឱ្យទាន់ពេលវេលា__*

*២. __ដំណាក់កាលទី២__៖ គ្រូបង្រៀនរៀបចំសកម្មភាពបង្រៀនសិស្ស (ក)ពីចម្ងាយ/អនឡាញសម្រាប់ជួយសិស្សដែលមិនទាន់យល់ច្បាស់ពីការស្វ័យសិក្សាសន្លឹកកិច្ចការទាំង៤ប្រភេទ និង(ខ)ជួបផ្ទាល់នៅថ្នាក់រៀន និងនៅកន្លែងផ្សេងទៀត អាចជាបុគ្គលក្រុមតូច និងក្រុមធំ ដើម្បីជួយសិស្សដែលជួបការលំបាក ក្នុងការយល់ខ្លឹមសារមេរៀន រួមជាមួយការឆ្លើយសំណួរ ធ្វើលំហាត់ និងដោះស្រាយចំណោទ។ __គ្រូត្រូវផ្តល់ព័ត៌មានត្រឡប់ទៅសិស្សវិញឱ្យទាន់ពេលវេលា__*

*៣. __ដំណាក់កាលទី៣__៖ គ្រូបង្រៀនជួយសិស្សរៀនចម្រុះមុខវិជ្ជា តាមរយៈកិច្ចការគម្រោងដើម្បីសិស្សបានរៀនដោយផ្សារភ្ជាប់ខ្លឹមសារមេរៀន ក្នុងកម្មវិធីសិក្សាគោល ទៅនឹងសកម្មភាពជាក់ស្ដែងក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ដើម្បីបង្កើនការរកចំណូល។ __គ្រូត្រូវផ្តល់ព័ត៌មានត្រឡប់ទៅសិស្សវិញឱ្យទាន់ពេលវេលា__*

*កិច្ចការគ្រូបង្រៀន*

*១. គ្រូមុខវិជ្ជាត្រូវស្ម័យសិក្សាសន្លឹកកិច្ចការទាំង៥ផ្នែក ដូចសិស្សដែរ ដើម្បី៖ ក)បានស្វែងយល់ពីសារៈសំខាន់ និងផលប្រយោជន៍របស់ឯកសារក្នុងការបង្វឹកសិស្សឱ្យចេះរៀនពីរបៀបរៀនដោយខ្លួនឯងជំនួសការដាស់តឿន និងប្រាប់ពីគ្រូ និងសមាជិកគ្រួសារ ខ)បានយល់ខ្លឹមសារមេរៀន និងលំនាំបង្រៀន ពីសន្លឹកកិច្ចការទាំង៥ប្រភេទ គ)បានរៀនពីវិធីសាស្ត្របង្រៀនមួយចំនួន សម្រាប់ជួយសិស្សចេះស្វ័យសិក្សា និងការបង្រៀនដោយប្រើឌីជីថល*

**ការសិក្សាសន្លឹកកិច្ចការ កម្រិត0**
លទ្ធផលរំពឹងទុក៖
សិស្សសម្គាល់៖ ពីរបៀបរៀបចំ និងចំណុចសំខាន់របស់មេរៀន ក្នុងសៀវភៅសិក្សាគោល

**ការសិក្សាសន្លឹកកិច្ចការ កម្រិត១**
លទ្ធផលរំពឹងទុក៖
សិស្សប្រមូល៖ ទិន្នន័យនិងព័ត៌មាន ពីក្នុងសៀវភៅសិក្សាគោល មួយមេរៀន

**ការសិក្សាសន្លឹកកិច្ចការ កម្រិត២**
លទ្ធផលរំពឹងទុក៖
សិស្សយល់៖ បញ្ញត្តិមេរៀនរួមមានៈ និយមន័យ រូបមន្ត ក្បួន និងគំនិតសំខាន់ មួយមេរៀន

**ការសិក្សាសន្លឹកកិច្ចការ កម្រិត៣**
លទ្ធផលរំពឹងទុក៖
សិស្សហ្វឹកហាត់៖ ដោយឆ្លើយ/សួរសំណួរ ធ្វើ/បង្កើតលំហាត់ និងដោះស្រាយ/បង្កើតចំណោទមួយមេរៀន

**ការសិក្សាសន្លឹកកិច្ចការ កម្រិត៤**
លទ្ធផលរំពឹងទុក៖
សិស្សស្វ័យវាយតម្លៃ៖ លទ្ធផលសិក្សាមួយមេរៀន ដែលសិស្សបានរៀនកន្លងមក

**ការសិក្សាសន្លឹកកិច្ចការ កម្រិត0**
លទ្ធផលរំពឹងទុក៖
សិស្សសម្គាល់៖ ពីរបៀបរៀបចំ និងចំណុចសំខាន់របស់មេរៀន ក្នុងសៀវភៅសិក្សាគោល










**ការសិក្សាសន្លឹកកិច្ចការ កម្រិត១**

**លទ្ធផលរំពឹងទុក៖**

សិស្សប្រមូល៖ ទិន្នន័យនិងព័ត៌មាន ពីក្នុងសៀវភៅសិក្សាគោល មួយមេរៀន













ចំពោះគ្រូបង្រៀន
ទី១
ទី២
ទី៣
5 / 9
សំណួរស្វ័យសិក្សា
សម្រាប់សិស្សរៀននៅតាមផ្ទះ ដោយប្រើសៀវភៅសិក្សាគោល
អរគុណ


ជំពូកទី១
ពិភពលោក
សំណួរ
ចម្លើយ
មេរៀនទី១
មូលដ្ឋានប្រវត្តិវិទ្យា
ជំពូកទី១
ពិភពលោក
សំណួរ
ចម្លើយ
មេរៀនទី១
មូលដ្ឋានប្រវត្តិវិទ្យា



| | |
|---|---|
| | • យុគថ្មរំលោះ។ |
| ២. តើជីវភាពសង្គមមនុស្សក្នុងសម័យបុរេប្រវត្តិមានស្ថានភាពដូចម្ដេច? | ២. ជីវភាពសង្គមមនុស្សក្នុងសម័យបុរេប្រវត្តិ៖ |

# អរគុណ

ចំពោះប្អូន
បានខិតខំស្វ័យសិក្សាឆ្លើយសំណួរខាងលើ។

៩



| | |
|---|---|
| | |
| ២. តើជីវភាពសង្គមមនុស្សក្នុងសម័យបុរេប្រវត្តិមានស្ថានភាពដូចម្ដេច? | |

## របាយការណ៍លទ្ធផលស្វ័យសិក្សារបស់សិស្ស

| | |
|---|---|
| ចំនួនសំណួរដែលបានឆ្លើយ ដោយមានទំនុកចិត្តខ្ពស់ជាទីបំផុត | ............/ ៨ សំណួរ |
| ចំនួនសំណួរដែលបានឆ្លើយ តែមិនសូវមានទំនុកចិត្តខ្លាំងទេ | ............/ ៨ សំណួរ |
| ចំនួនសំណួរដែលមិនបានឆ្លើយ ដោយសារតែមិនយល់សោះ | ............/ ៨ សំណួរ |
| រយៈពេលឆ្លើយសំណួរទាំងអស់ គិតជាចំនួនម៉ោង (ប៉ាន់ស្មាន) | ប្រហែល១ម៉ោង |

៩

**១.អំណានស្ទាត់៖**

អោយសិស្សយកចិត្តអានខ្លឹមសារមេរៀនមុនពេលជួបគ្រូមានដូចជា៖ពាក្យគន្លឹះ និយមន័យ ប្រយោគ ល្បះ ឃ្លា អត្ថបទ រូបមន្ត ......អោយបានបានច្បាស់ ត្រូវ លឿន ចាំហើយយល់ ន័យ ។

**២.សរសេរតាមអាន៖**

អោយសិស្សបានហ្វឹកហាត់សរសេរនូវពាក្យគន្លឹះ និយមន័យ ប្រយោគ ល្បះ ឃ្លា អត្ថបទ រូបមន្ត..ពិសេសស្តាប់ន័យ ស្គាល់ពាក្យ ស្គាល់ន័យ យល់ន័យ របស់បញ្ញត្តិមេរៀនអោយកាន់តែប្រសើរ មុនពេលជួបគ្រូ។







៣.សំនួរផ្ទាល់មាត់៖

អោយសិស្សយកចិត្តទុកដាក់អានអោយយល់កាន់តែច្បាស់លើចំណុចសំខាន់ៗនៃខ្លឹមសាមេរៀនត្រង់បញ្ញត្តិនីមួយៗថាចង់បង្ហាញពីអ្វី ។ ឧទាហរណ៍៖ មេរៀនមជ្ឈមណ្ឌលប្រសាទសិស្សរៀនចប់ពួកគាត់ចេះប្រើមួកសុវត្ថភាពពលជិះម៉ូជិតឆ្ងាយនិងជិះកង់ហាត់ប្រាណពាក់មួកសុវត្ថភាព មិនផឹកគ្រឿងស្រវឹង មិនប្រើសារជាតុញៀន មិនលេងទូរស័ព្ទក្នុងរឿងឥតបប្រយោជន៍(ដល់ពាក់កណ្ដាលយប់) មិនជក់បារី មិនប្រើថ្នាំងងុយគេងព្រឹកញាប់ និងបរិភោគអាហារដែលមានតុល្យភាព លំហាត់ប្រាណទៀងទាត់..។





៤.លំហាត់ហ្វឹកហាត់លើបញ្ញត្តិមេរៀន៖

វាស់ស្ទង់ពីសមត្ថភាពរៀននិងបង្រៀនក្នុងមួយមេរៀន(ងាយស្រួលជួយសិស្សនិងជួយពង្រឹកសមត្ថភាពគ្រូខ្លួនឯង)
+សិស្សប៉ុន្មាននាក់ដែល យល់ច្បាស់និងអនុវត្តន៍ វិភាគ វាយតម្លៃ)ទៅលើខ្លឹមសារមេរៀនដែលរៀនរួចហើយ។
+ប៉ុន្មាននាក់មិនទាន់ យល់ច្បាស់និងអនុវត្តន៍ វិភាគ វាយតម្លៃ) ទៅលើខ្លឹមសារមេរៀនដែលរៀនរួចហើយ។
+ប៉ុន្មាននាក់ដែល មិនយល់សោះអនុវត្តន៍ វិភាគ វាយតម្លៃ) ទៅលើខ្លឹមសារមេរៀនដែលរៀនរួចហើយ។

៥.អនុវត្តន៍កិច្ចការស្រាវជ្រាវ៖

គឺវាយតម្លៃទៅលើបំណិនរបស់សិស្សជាបុគ្គល ជាក្រុម ជាថ្នាក់ នៃខ្លឹមសារបញ្ញត្តិសំខាន់របស់មេរៀន។
ដោយបង្កើតជាតារាងកត់ត្រារួមមាន៖

| លរ | ឈ្មោះសិស្ស | ភេទ | ថ្នាក់ទី | មេរៀន | ការងារប្រតិបត្ត | ទីតាំង | អ្នកចូលរួម |
|---|---|---|---|---|---|---|---|
| ១ | កន រចនា | ស | ៩គ | ២ | | ក្នុងគ្រួសារភូមិព្រៃកក្តី | ម្ដាយនិងមិត្តរួមថ្នាក់ គ្រូ |
| | | | | | | | |

***<u>កិច្ចការគ្រូបង្រៀន</u>***

*២. គ្រូមុខវិជ្ជាត្រូវជួយកែសម្រួល លំនាំបង្រៀន និងខ្លឹមសារមេរៀន ដើម្បីបំពេញបន្ថែម ឱ្យបានសមស្របជាមួយស្ថានភាពសិស្ស និងថ្នាក់រៀនរបស់គាត់*

*៣. គ្រូមុខវិជ្ជាអាចចូលរួមផលិតឯកសារជួយសិស្សរៀន និងជួយគ្រូបង្រៀន ដើម្បីបានរៀនសូត្រពីវិធីបង្រៀនថ្មីៗទៀត ដូចជា៖ ការរៀនសម្របតាមសិស្ស*

***<u>កិច្ចការសិស្ស</u>***

*<u>១. ដំណាក់កាលទី១</u>៖ គ្រូបង្រៀនមុខវិជ្ជាផ្តល់ (ក)សន្លឹកកិច្ចការទន់ដែលបានផលិត ដោយក្រុមការងារបច្ចេកទេសក្រសួង និងក្រុមបច្ចេកទេសមហាវិទ្យាល័យអប់រំ សម្របសម្រួលដោយក្រុមបច្ចេកទេសនាយកដ្ឋានធានាគុណភាព និងផ្នែកពាក់ព័ន្ធ) សម្រាប់សិស្សស្វ័យសិក្សាក្នុងមួយឆ្នាំសិក្សា ដើម្បីសិស្សបានរៀនមុនពេលរៀនជាមួយគ្រូផ្ទាល់ និង(ខ) សន្លឹកកិច្ចការថតចម្លង មួយខែម្តងសម្រាប់សិស្សដែលមិនទាន់មានឧបករណ៍បច្ចេកវិទ្យា ដើម្បីបានរៀនមុនពេលរៀនជាមួយគ្រូបង្រៀនផ្ទាល់។ <u>គ្រូត្រូវផ្តល់ព័ត៌មានត្រឡប់ទៅសិស្សវិញឱ្យទាន់ពេលវេលា</u>*











*<u>កិច្ចការសិស្ស</u>*

*២. <u>ដំណាក់កាលទី២</u>៖ គ្រូបង្រៀនរៀបចំសកម្មភាពបង្រៀនសិស្ស (ក)ពីចម្ងាយ/អនឡាញសម្រាប់ជួយសិស្សដែលមិនទាន់យល់ច្បាស់ពីការស្វ័យសិក្សាសន្លឹកកិច្ចការទាំង៤ប្រភេទ និង(ខ)ជួបផ្ទាល់នៅថ្នាក់រៀន និងនៅកន្លែងផ្សេងទៀត អាចជាបុគ្គលក្រុមតូច និងក្រុមធំ ដើម្បីជួយសិស្សដែលជួបការលំបាកក្នុងការយល់ខ្លឹមសារមេរៀន រួមជាមួយការឆ្លើយសំណួរ ធ្វើលំហាត់ និងដោះស្រាយចំណោទ។ <u>គ្រូត្រូវផ្តល់ព័ត៌មានត្រឡប់ទៅសិស្សវិញឱ្យទាន់ពេលវេលា</u>*



















*<u>កិច្ចការសិស្ស</u>*

*៣. <u>ដំណាក់កាលទី៣</u>៖ គ្រូបង្រៀនជួយសិស្សរៀនចម្រុះមុខវិជ្ជា តាមរយៈកិច្ចការគម្រោងដើម្បីសិស្សបានរៀនដោយផ្សារភ្ជាប់ខ្លឹមសារមេរៀន ក្នុងកម្មវិធីសិក្សាគោល ទៅនឹងសកម្មភាពជាក់ស្តែងក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ដើម្បីបង្កើនការរកចំណូល។ <u>គ្រូត្រូវផ្តល់ព័ត៌មានត្រឡប់ទៅសិស្សវិញឱ្យទាន់ពេលវេលា</u>*



IV.**សេចក្តីសន្និដ្ឋាន**

ការរៀន និងបង្រៀនតាមគន្លងជីវិតថ្មី

- បានធ្វើឱ្យលទ្ធផលសិក្សារបស់បានល្អជាងមុន ដោយសិស្សចេះរៀនខ្លួនឯងមុនមកជួបគ្រូ តាមរយៈសន្លឹកកិច្ចការ

កម្រិតទី១ ទី២ ទី៣ ទី៤ សិស្សមានផែនការសិក្សាប្រចាំឆ្នាំបានដឹងលឺពីមាតាបិតារបស់ខ្លួន សិស្សរៀនផ្សាភ្ជាប់នឹងបំណិនរកចំណូល។

- គ្រូបង្រៀនបានខិតខំបំពេញការងាររបស់ខ្លួនបានល្អជាងមុន ចេះរកវិធីបង្រៀនសិស្ស ចេះជួយសិស្សរៀនយឺត ចេះជួយសិស្សឱ្យមានបំណិនរកចំណូល។

# សូមអរគុណ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

មន្ទីរអប់រំយុវជន និង កីឡា ខេត្តកំពង់ចាម
ការិយាល័យអប់រំយុវជន និង កីឡា ស្រុកស្រីសន្ធរ
វិទ្យាល័យ ព្រៃកដំបូក
លេខទូរស័ព្ទ ០៩២ ៦៣២ ៥៨៨
Email mokbora88@gmail.com

# ករណីសិក្សា របស់ វិទ្យាល័យ ព្រៃកដំបូក

ប្រធានបទ

# ការបង្រៀន និង រៀន តាមបែប គន្លងជីវិតថ្មីនៃការសិក្សា



ខ្ញុំបាទ ម៉ុក បូរ៉ា នាយក
វិទ្យាល័យ ព្រែកដំបូក ឃុំព្រែកដំបូក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម
ទូរស័ព្ទ៖ 092 632588
Email mokbora88@gmail.com

ប្រវត្តិការសិក្សា៖
ក.ទទួលបានសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ឆ្នាំ ១៩៨៤
ខ.ទទួលបានសញ្ញាបត្រមធ្យសិក្សាទុតិយភូមិ ឆ្នាំ១៩៩៣
គ.ទទួលបានសញ្ញាបត្របរិញ្ញាបត្រ អក្សរសាស្ត្រឆ្នាំ ២០១៦
ឃ.ទទួលបាន សញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់អក្សរសាស្ត្រ ឆ្នាំ២០១៨
ច.ទទួបានបរិញ្ញាបត្រ អប់រំ នៅសកលវិទ្យាល័យភូមិន្ទភ្នំពេញឆ្នាំ២០២១
ឆ.បច្ចុប្បន្នបន្ត ជាបេក្ខជន និសិត្ស បរិញ្ញបត្រ ជាន់ខ្ពស់ផ្នែកអប់រំ
ប្រវត្តិការងារ៖
១. នៅឆ្នាំ ១៩៨៤ ជាគ្រូបឋមសិក្សា
២. នៅឆ្នាំ ១៩៨៩ ជាគ្រូមធ្យមសិក្សាបឋមភូមិ
៣. នៅឆ្នាំ ១៩៩០ ជាគ្រូមធ្យមសិក្សាទុតិយភូមិ
មានតួនាទីជានាយករង ចាប់ពីឆ្នាំ១៩៨៧
មានតួនាទីជានាយកវិទ្យាល័យ ឆ្នាំ២០០៩.






## វិទ្យាល័យ ព្រែកដំបូក

មានទីតាំងនៅភូមិព្រែកដំបូកក្រោម
ឃុំព្រែកដំបូក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម

**សាវតាសាលា:**

ឆ្នាំ១៩៨៨ដល់១៩៩០ជាឧបសម្ព័ន្ធសាលាកំរិត១ស្រីសរឈរ
ឆ្នាំ១៩៨៨ដល់២០០៦ ជាអនុវិទ្យាល័យព្រែកដំបូក
ឆ្នាំ២០០៧ ដល់បច្ចុប្បន្ន ជា វិទ្យាល័យ ព្រែកដំបូក
ឆ្នាំ២០១៧ ចូលក្នុងគម្រោងកែលម្អការអប់រំមធ្យមសិក្សា

## ចំណុចសំខាន់របស់គ្រូបង្រៀនដែលនាំឲ្យសិស្សរៀនចេះ

**ការរៀន និងបង្រៀនតាម គន្លងជីវិតថ្មី**

- គ្រូបានធ្វើផែនការបង្រៀន
- គ្រូបង្រៀន បានធ្វើកិច្ចតែងការបង្រៀន តាមទម្រង់ប្រពៃណី ឬ តាមទម្រង់បែបថ្មី
- ការបង្រៀន និង រៀន សិស្ស
- ការធ្វើតេស្ត ម៉ត់ចត់ ប្រចាំខែ ឆមាស និង ដើមឆ្នាំ
- គ្រូបានយកលទ្ធផលមកឆ្លុះបញ្ចាំង ពីលទ្ធផលការសិក្សា របស់សិស្ស ធៀបនឹង ការបង្រៀន និងរៀន
- គ្រូ បានជួយ ផ្សព្វផ្សាយលទ្ធផលសិក្សាសិស្ស ម្នាក់ៗ
- មានការប្រជុំ រកមធ្យោបាយជួយសិស្សមានបញ្ហាប្រឈម ហើយឬនៅ ?

## វិទ្យាល័យព្រែកដំបូកបាន អនុវត្ត (៥ស្តង់ដាធំៗ)
## ដើម្បីសម្រេច សាលារៀនមានប្រសិទ្ធភាព

# ប្រធានបទ
# ការរៀន និងបង្រៀនតាមគន្លងជីវិតថ្មីនៃការសិក្សា

I.សេចក្តីផ្តើម

II.គោលបំណង

III.សកម្មភាព

.កិច្ចការទី១ .បង្រៀន (គ្រូបង្រៀន និងក្រុមបច្ចេសទេស)

.កិច្ចការទី២ .រៀន (សិស្ស)

.កិច្ចការទី៣ .បង្រៀន និង រៀន

IV.សេចក្តីសន្និដ្ឋាន

## I.សេចក្តីផ្តើម

វិទ្យាល័យព្រែកដំបូក បានអនុវត្តគម្រោងកែលម្អការអប់រំចំណេះទូទៅនៅមធ្យមសិក្សា នឹងបន្តការងារ(យុទ្ធសាស្រ្តសហគមន៍សាលារៀន)ស្តង់ដាសហគមន៍សាលារៀនដែលមាន៥ស្តង់ដា និងមាន៧0សូចនាករ ត្រូវបានវិទ្យាល័យ ព្រែកដំបូក យកមកអនុវត្តឱ្យបានល្អតាមស្តង់ដានីមួយៗ ក្នុងនោះក៏មានការរៀន និងបង្រៀន តាមគន្លងជីវិតថ្មី ។

---

## II.គោលបំណង

**ជួយសិស្សឱ្យចេះរៀន ដោយស្វ័យ សិក្សាខ្លួនឯងមុននឹងមកជួបគ្រូផ្ទាល់រឺជួបតាមអនឡាញ តាមរយៈប្រើសន្លឹកកិច្ចការកម្រិតទី១ ទី២ ទី៣ ទី៤ និងជួយសិស្សឱ្យមានបំណិនរកចំណូល។**

## III.សកម្មភាព

.កិច្ចការទី១ .បង្រៀន (គ្រូបង្រៀន និងក្រុមបច្ចេសទេស)

.កិច្ចការទី២ .រៀន (សិស្ស)

.កិច្ចការទី៣ .បង្រៀន និង រៀន

---

កិច្ចការទី១ .បង្រៀន (គ្រូបង្រៀន និងក្រុមបច្ចេសទេស)

- ❖ ក្រុមបច្ចេកទេសប្រជុំគ្រូតាមមុខវិជ្ជា តាមកម្រិតថ្នាក់
- ប្រជុំ រៀបចំកម្មវិធីសិក្សាប្រចាំឆ្នាំតាមកម្រិតថ្នាក់
- ប្រជុំ រៀបចំសន្លឹកកិច្ចការទី១ ទី២ ទី៣ ទី៤ តាមកម្រិតថ្នាក់
- ប្រជុំ រៀបចំកម្មវិធីសិក្សាប្រចាំសប្តាហ៍តាមកម្រិតថ្នាក់
- ប្រជុំ រៀបចំគម្រោងបង្រៀនមួយមេរៀនមានច្រើនម៉ោង
- ប្រជុំ រៀបចំផែនការបង្រៀន(៣ឆ្នាំ ១ឆ្នាំ ៣ខែ)
- ប្រជុំ ធ្វើកិច្ចព្រមព្រៀងប្រចាំឆ្នាំរបស់គ្រូម្នាក់ៗ
- គ្រូធ្វើសំណើសុំចុះជួយអធិការកិច្ចការបង្រៀន





**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**គម្រោងកែលម្អការអប់រំចំណេះទូទៅ**
**អនុវិស័យមធ្យមសិក្សាចំណេះទូទៅ**

**បំណែងចែកកម្មវិធីសិក្សាលម្អិតប្រចាំឆ្នាំ**

មុខវិជ្ជា៖ ប្រវត្តិវិទ្យា
ថ្នាក់ទី៖ ៧
ចំនួនម៉ោងសិក្សាសរុបប្រចាំឆ្នាំ៖ ៧៦ ម៉ោង

| ខែ | សប្តាហ៍ | ម៉ោង | ចំណងជើង (ជំពូក / មេរៀន / ខ្លឹមសាររង) | លទ្ធផលសិក្សារំពឹងទុកនៃកម្មវិធីសិក្សាលម្អិត | ទំព័រ | |
|---|---|---|---|---|---|---|
| | | | | | ស.ស | ស.គ |
| មករា | ២ | ១ម៉ (ម៉ទី១) | ជំពូកទី២ ប្រវត្តិសាស្រ្តកម្ពុជាសម័យបុរាណ<br>មេរៀនទី១ បុរេប្រវត្តិកម្ពុជា ១.ដើមកំណើតដីខ្មែរ | – បង្ហាញពីសម័យបុរេប្រវត្តិនៅលើព្រួញកាល | ១១៦ | |
| | | ១ម៉(ម៉ទី២) | ២.ដើមកំណើតនៃជនជាតិខ្មែរ | – បង្ហាញពីសម័យបុរេប្រវត្តិនៅលើព្រួញកាល | ១១៧ | |
| | ៣ | ១ម៉(ម៉ទី៣) | ៣.ផែនទីស្ថានីយបុរេប្រវត្តិសាស្រ្តកម្ពុជា | – បង្ហាញពីទីតាំងនៃស្ថានីយ រយៈពេលយុគសម័យនិងជីវភាពរស់នៅក្នុងបុរេប្រវត្តិកម្ពុជា | ១១៨ | |
| | | ១ម៉(ម៉ទី៤) | ៤.យុគសម័យនិងស្ថានីយបុរេប្រវត្តិសាស្រ្តខ្មែរ | – បង្ហាញពីទីតាំងនៃស្ថានីយ រយៈពេលយុគសម័យនិងជីវភាពរស់នៅក្នុងបុរេប្រវត្តិកម្ពុជា | ១១៩ | |
| | ៤ | ១ម៉(ម៉ទី៥) | ៥.អរិយធម៌ខ្មែរសម័យបុរេប្រវត្តិសាស្រ្ត | – បង្ហាញពីទីតាំងនៃស្ថានីយ រយៈពេលយុគសម័យនិងជីវភាពរស់នៅក្នុងបុរេប្រវត្តិកម្ពុជា | ១២០ | |
| | | ១ម៉(ម៉ទី៦) | ប្រឡងប្រចាំខែមករា | | | |

| | | | | | | |
|---|---|---|---|---|---|---|
| កុម្ភៈ | ១ | ១ម៉ (ម៉ទី៧) | មេរៀនទី២ អាណាចក្រភ្នំ<br>១.ទីតាំងភូមិសាស្រ្តនិងកំណើតនគរភ្នំ | – បង្ហាញពីដើមកំណើតនិងទីតាំងភូមិសាស្រ្តនគរភ្នំ | ១២១ | |
| | | ១ម៉ (ម៉ទី៨) | ២.មូលហេតុឥណ្ឌាមកនៅនគរភ្នំ | – បង្ហាញមូលហេតុនៃការមកដល់នគរភ្នំរបស់ឥណ្ឌា | ១២២ | |
| | ២ | ១ម៉ (ម៉ទី៩) | ៣.ព្រះរាជាល្បីៗសម័យនគរភ្នំ | – បង្ហាញមូលហេតុនៃការមកដល់នគរភ្នំរបស់ឥណ្ឌា | ១២៣ | |
| | | ១ម៉ (ម៉ទី១០) | ៤.ការដួលរលំនៃអាណាចក្រភ្នំ | – បង្ហាញពីមូលហេតុនៃសង្រ្គាមផ្ទៃក្នុងនិងជីវភាពរស់នៅរបស់ប្រជាជននៅនគរភ្នំ | ១២៤ | |
| | ៣ | ១ម៉ (ម៉ទី១១) | ៥.អរិយធម៌នគរភ្នំ | – បង្ហាញពីមូលហេតុនៃសង្រ្គាមផ្ទៃក្នុងនិងជីវភាពរស់នៅរបស់ប្រជាជននៅនគរភ្នំ | ១២៥ | |
| | | ១ម៉ (ម៉ទី១២) | មេរៀនទី៣ អាណាចក្រចេនឡា<br>១.ទីតាំងភូមិសាស្រ្ត | – បង្ហាញសម័យចេនឡាលើព្រួញកាលនៃប្រវត្តិសាស្រ្តខ្មែរ | ១២៦ | |
| | ៤ | ១ម៉ (ម៉ទី១៣) | ២.ព្រះរាជាល្បីៗនៅអាណាចក្រចេនឡា | – បង្ហាញសម័យចេនឡាលើព្រួញកាលនៃប្រវត្តិសាស្រ្តខ្មែរ | ១២៧ | |
| | | ១ម៉(ម៉ទី១៤) | ប្រឡងប្រចាំខែកុម្ភៈ | | | |

| | | | | | | |
|---|---|---|---|---|---|---|
| មីនា | ១ | ១ម៉ (ម៉ទី១៥) | ៣.ការបែកបាក់អាណាចក្រចេនឡា | – បង្ហាញពីមូលហេតុនៃការរីកចម្រើននិងស្រុតចុះនៃសង្គមចេនឡា | ១២៨ | |
| | | ១ម៉ (ម៉ទី១៦) | ៤.ចេនឡាដីគោករដ្ឋឯករាជ្យ<br>៥.ចេនឡាទឹកលិចក្រោមអំណាចជ្វា | – បង្ហាញពីមូលហេតុនៃការរីកចម្រើននិងស្រុតចុះនៃសង្គមចេនឡា | ១២៩ | |
| | ២ | ១ម៉ (ម៉ទី១៧) | ៦.អរិយធម៌ចេនឡា | បង្ហាញជីវភាពរស់នៅរបស់ប្រជាជននិងលក្ខណៈសង្គមចេនឡា | ១៣០ | |
| | | ១ម៉ (ម៉ទី១៨) | ៦.អរិយធម៌ចេនឡា(តចប់) | – បង្ហាញជីវភាពរស់នៅរបស់ប្រជាជននិងលក្ខណៈសង្គមចេនឡា | ១៣១ | |
| | ៣ | ១ម៉ (ម៉ទី១៩) | ជំពូកទី៣ ប្រវត្តិសសាស្ត្រតំបន់ចិននិងឥណ្ឌា<br>មេរៀនទី១ ប្រទេសចិនបុរាណ<br>១.ប្រភពប្រវត្តិសាស្ត្រចិន | – បង្ហាញពីទិដ្ឋភាពសំខាន់របស់ចិន | ១៣៤ | |
| | | ១ម៉ (ម៉ទី២០) | ២.រាជវង្សដើម<br>៣.រាជវង្សស៊ូ | – បង្ហាញពីសង្គមចិន | ១៣៥ | |
| | ៤ | ១ម៉ (ម៉ទី២១) | ៤.ចិនបុរាណ | – បង្ហាញពីជីវភាពរបស់ប្រជាជននិងសង្គមចិន | ១៣៦ | |
| | | ១ម៉ (ម៉ទី២២) | ប្រឡងប្រចាំខែមិនា | | | |
| | | វិស្សមកាលតូច | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| មេសា | ៣ | ១ម៉ (ម៉ទី២៣) | ៤.ចិនបុរាណ(តចប់) | – បង្ហាញពីជីវភាពរបស់ប្រជាជននិងសង្គមចិន | ១៣៧ | |
| | | ១ម៉ (ម៉ទី២៤) | មេរៀនទី២ ប្រទេសឥណ្ឌាបុរាណ<br>១.ទីតាំងភូមិសាស្ត្រនិងជនជាតិឥណ្ឌា<br>២.អរិយធម៌នៅតាមដងទន្លេឥណ្ឌូស | – បង្ហាញពីទិដ្ឋភាពសំខាន់នៃប្រទេសឥណ្ឌា | ១៣៨ | |
| | ៤ | ១ម៉ (ម៉ទី២៥) | ៣.ការលុកលុយរបស់ពួកអារ្យ៉ន | – បង្ហាញពីសង្គមឥណ្ឌា | ១៣៩ | |
| | | ១ម៉ (ម៉ទី២៦) | ៤.អរិយធម៌ឥណ្ឌាបុរាណ | – បង្ហាញពីជីវភាពរស់នៅនិងសង្គមរបស់ឥណ្ឌាបុរាណ | ១៤០ | |
| ឧសភា | ១ | ១ម៉ (ម៉ទី២៧) | ៤.អរិយធម៌ឥណ្ឌាបុរាណ(តចប់) | – បង្ហាញពីជីវភាពរស់នៅនិងសង្គមរបស់ឥណ្ឌាបុរាណ | ១៤១ | |
| | | ១ម៉ (ម៉ទី២៨) | មេរៀនទី៣ រដ្ឋជ្វា<br>១.ស្ថានភាពប្រវត្តិសាស្ត្ររវាងខ្មែរនិងជ្វា | – បង្ហាញពីព្រឹត្តិការណ៍សង្គមនៃរដ្ឋជ្វា | ១៤២ | |
| | ២ | ១ម៉ (ម៉ទី២៩) | ២.ឥទ្ធិពលសាសនាអ៊ីស្លាម | – បង្ហាញពីព្រឹត្តិការណ៍សង្គមនៃរដ្ឋជ្វា | ១៤៣ | |
| | | ១ម៉ (ម៉ទី៣០) | ៣.ឥទ្ធិពលក្រុមហ៊ុនឥណ្ឌាខាងកើតលើកោះជ្វា | – បង្ហាញពីព្រឹត្តិការណ៍សង្គមនៃរដ្ឋជ្វា | ១៤៤ | |
| | ៣ | ១ម៉ (ម៉ទី៣១) | ៤.អរិយធម៌កោះជ្វា | – បង្ហាញពីជីវភាពរស់នៅនិងងសង្គមរបស់ប្រជាជនជ្វា | ១៤៥ | |
| | | ១ម៉ (ម៉ទី៣២) | មេរៀនទី៤ រដ្ឋមន<br>១.ស្ថានភាពជនជាតិមននិងខ្មែរ | – បង្ហាញពីព្រឹត្តិការណ៍សំខាន់ៗនៃសង្គមជនជាតិមន | ១៤៦ | |
| | ៤ | ១ម៉ (ម៉ទី៣៣) | ២.រដ្ឋមន | – បង្ហាញពីព្រឹត្តិការណ៍សំខាន់ៗនៃសង្គមជនជាតិមន | ១៤៧ | |
| | | ១ម៉ (ម៉ទី៣៤) | ប្រឡងប្រចាំខែឧសភា | | | |

| | | | | | | |
|---|---|---|---|---|---|---|
| មិថុនា | ១ | ១ម៉ (ម៉ទី៣៥.៣៦) | ប្រឡងឆមាសលើកទី១ | | | |
| | ២ | ១ម៉ (ម៉ទី៣៧) | ៣.ព្រឹត្តិការណ៍រវាងមន ភូមានិង សៀម | – បង្ហាញពីជីវភាពនិងព្រឹត្តិការណ៍សង្គមនៃជនជាតិមន | ១៤៨ | |
| | | ១ម៉ (ម៉ទី៣៨) | ៣.ព្រឹត្តិការណ៍រវាងមន ភូមានិង សៀម(តចប់) | – បង្ហាញពីជីវភាពនិងព្រឹត្តិការណ៍សង្គមនៃជនជាតិមន | ១៤៩ | |
| | ៣ | ១ម៉ (ម៉ទី៣៩) | ជំពូកទី១ សម័យបុរាណនិងប្រទេសដទៃ<br>មេរៀនទី១ មូលដ្ឋាននៃប្រវត្តិវិទ្យា<br>១.ប្រវត្តិវិទ្យាជាអ្វី? | – ពណ៌នាពីមូលដ្ឋាននៃប្រវត្តិវិទ្យា | ៧៦ | |
| | | ១ម៉(ម៉ទី៤០) | ២.កាលវិទ្យា | – ពណ៌នាពីមូលដ្ឋាននៃប្រវត្តិវិទ្យា | ៧៧ | |
| | ៤ | ១ម៉ (ម៉ទី៤១) | ៣.បុរេប្រវត្តិសាស្ត្រ | – ពណ៌នាពីជីវភាពរស់នៅរបស់មនុស្សក្នុងយុគសម័យនីមួយៗ | ៧៨.៧៩ | |
| | | ១ម៉ (ម៉ទី៤២) | ប្រឡងប្រចាំខែមិថុនា | | | |
| កក្កដា | ១ | ១ម៉ (ម៉ទី៤៣) | មេរៀនទី២ ប្រទេសអេហ្ស៊ីបបុរាណ<br>១.ស្ថានភាពភូមិសាស្ត្រអេហ្ស៊ីប | – បង្ហាញទីតាំងសំខាន់ៗរដ្ឋអេហ្ស៊ីប | ៨០ | |
| | | ១ម៉ (ម៉ទី៤៤) | ២.ប្រវត្តិសាស្ត្រអេហ្ស៊ីប | – បង្ហាញពីទិដ្ឋភាពសំខាន់ៗអេហ្ស៊ីប | ៨១ | |
| | ២ | ១ម៉ (ម៉ទី៤៥) | ២.ប្រវត្តិសាស្ត្រអេហ្ស៊ីប(តចប់) | – បង្ហាញពីទិដ្ឋភាពសំខាន់ៗអេហ្ស៊ីប | ៨២ | |
| | | ១ម៉ (ម៉ទី៤៦) | ៣.វណ្ណៈសង្គម | – ពណ៌នាពីទិដ្ឋភាពសង្គមនិងជីវភាពរបស់ប្រជាជនអេហ្ស៊ីប | ៨៣ | |
| | ៣ | ១ម៉ (ម៉ទី៤៧) | ៤.សាសនាអេហ្ស៊ីបបុរាណ | – បង្ហាញពីទីតាំងនិងសារៈសំខាន់នៃអច្ឆរិយវត្ថុលើពិភពលោក(ប្រាសាទពីរ៉ាមីត) | ៨៤.៨៥ | |
| | | ១ម៉ (ម៉ទី៤៨) | មេរៀនទី៣ រដ្ឋនៅតំបន់មេសូប៉ូតាមី<br>១.ទីតាំងភូមិសាស្ត្រនិងកុលសម្ព័ន្ធ | – ពណ៌នាពីទិដ្ឋភាពសំខាន់ៗនៃតំបន់មេសូប៉ូតាមី | ៨៦ | |
| | ៤ | ១ម៉ (ម៉ទី៤៩) | ២.រដ្ឋសំខាន់ៗនិងនយោបាយវាតទី | – បង្ហាញពីសង្គមនៃតំបន់មេសូប៉ូតាមី | ៨៧ | |
| | | ១ម៉ (ម៉ទី៥០) | ប្រឡងប្រចាំខែកក្កដា | | | |

| | | | | | | |
|---|---|---|---|---|---|---|
| សីហា | ១ | ១ម៉ (ម៉ទី៥១) | ៣.អរិយធម៌មេសូប៉ូតាមី | – បង្ហាញពីជីវភាពរស់នៅរបស់ប្រជាជនតំបន់មេសូប៉ូតាមី | ៨៨.៨៩ | |
| | | ១ម៉ (ម៉ទី៥២) | មេរៀនទី៤ ជនជាតិដើមអ៊ីស្រាអែល<br>១.ប្រវត្តិទឹកដីនិងជនជាតិហេប្រឺ | – បង្ហាញពីលក្ខណៈសង្គមហេប្រឺ | ៩០ | |
| | ២ | ១ម៉(ម៉ទី៥៣) | ២.សម័យកាលសំខាន់ៗ | – បង្ហាញពីទិដ្ឋភាពសង្គមទូទៅនៃរដ្ឋអ៊ីស្រាអែល | ៩១ | |
| | | ១ម៉(ម៉ទី៥៤) | ៣.អរិយធម៌ហេប្រឺ | – បង្ហាញពីទីតាំងនៃអច្ឆរិយវត្ថុពិភពលោក | ៩២ | |
| | ៣ | ១ម៉ (ម៉ទី៥៥) | មេរៀនទី៥ រដ្ឋផេនីស៊ី<br>១.ទីតាំងភូមិសាស្ត្ររបស់រដ្ឋផេនីស៊ី | – បង្ហាញពីទិដ្ឋភាពសំខាន់ៗនៃរដ្ឋផេនីស៊ី | ៩៣ | |
| | | ១ម៉(ម៉ទី៥៦) | ២.ជីវភាពនយោបាយ | – បង្ហាញពីជីវភាពប្រជាជនផេនីស៊ី | ៩៤ | |
| | ៤ | ១ម៉ (ម៉ទី៥៧) | ៣.អរិយធម៌ប្រទេសផេនីស៊ី | – បង្ហាញទីតាំងអច្ឆរិយវត្ថុនានៅលើសកលលោកនិងជីវភាពរស់នៅរបស់ប្រជាជនផេនីស៊ី | ៩៥.៩៧ | |
| | | ១ម៉ (ម៉ទី៥៨) | ប្រឡងប្រចាំខែសីហា | | | |
| កញ្ញា | ១ | ១ម៉ (ម៉ទី៥៩) | មេរៀនទី៦ ប្រទេសក្រិកបុរាណ<br>១.ស្ថានភាពភូមិសាស្ត្រនិងប្រជាជន | – ពណ៌នាពីទិដ្ឋភាពសំខាន់ៗនៃក្រិកបុរាណ | ៩៨ | |
| | | ១ម៉ (ម៉ទី៦០) | ២.បុរីឬរដ្ឋនានាក្នុងប្រទេសក្រិក | – បង្ហាញពីជីវភាពរស់នៅរបស់ប្រជាជនក្រិកបុរាណ | ៩៩.១០០ | |
| | ២ | ១ម៉ (ម៉ទី៦១) | ៣.អរិយធម៌ក្រិក | – បង្ហាញពីទីតាំងនៃអច្ឆរិយវត្ថុនិងការបង្កើតថ្មីៗនៃជនជាតិក្រិក | ១០១.១០៣ | |
| | | ១ម៉ (ម៉ទី៦២) | មេរៀនទី៧ ចក្រភពរ៉ូម<br>១.ស្ថានភាពភូមិសាស្ត្រអ៊ីតាលីបុរាណ | – បង្ហាញពីទិដ្ឋភាពសំខាន់ៗនៃអ៊ីតាលី | ១០៤ | |
| | ៣ | ១ម៉(ម៉ទី៦៣) | ២.ព្រឹត្តិការណ៍នយោបាយ | – បង្ហាញពីព្រឹត្តិការណ៍សំខាន់ៗនៅអ៊ីតាលី | ១០៥.១០៦ | |
| | | ១ម៉ (ម៉ទី៦៤) | ៣.អរិយធម៌រ៉ូម | – បង្ហាញពីអរិយធម៌និងជីវភាពរស់នៅរបស់ជនជាតិអ៊ីតាលីបុរាណ | ១០៧.១០៩ | |
| | ៤ | ១ម៉ (ម៉ទី៦៥.៦៦) | ប្រឡងឆមានលើកទី២ | | | |

| | | | | | | |
|---|---|---|---|---|---|---|
| តុលា | ១ | ១ម៉<br>(ម៉ទី៦៧) | មេរៀនទី៨ អរិយធម៌អាមេរិកបុរាណ<br>១.ចក្រភពម៉ាយ៉ា | – ពណ៌នាពីជីវភាពនិងសង្គមរស់នៅរបស់ប្រជាជនក្នុងអាមេរិកកណ្តាល | ១១០.<br>១១១ | |
| | | ១ម៉ (ម៉ទី៦៨) | ២.ចក្រភពអាស្តែក | – ពណ៌នាពីជីវភាពនិងសង្គមរស់នៅរបស់ប្រជាជនក្នុងអាមេរិកកណ្តាល | ១១២ | |
| | ២ | ១ម៉ (ម៉ទី៦៩) | ៣.ចក្រភពអាំងកា | – បង្ហាញពីសារៈសំខាន់នៃអច្ឆរិយវត្ថុនៃមនុស្សលោក។ | ១១៣ | |
| | | ១ម៉ (ម៉ទី៧០) | រំលឹកមេរៀនសាឡើងវិញ | | | |
| | ៣ | ១ម៉ (ម៉ទី៧១) | រំលឹកមេរៀនសាឡើងវិញ | | | |
| | | ១ម៉ (ម៉ទី៧២) | រំលឹកមេរៀនសាឡើងវិញ | | | |
| | ៤ | ១ម៉ (ម៉ទី៧៣) | រំលឹកមេរៀនសាឡើងវិញ | | | |
| | | | វិស្សមកាលធំ | | | |

ថ្ងៃ.................ខែ...............ឆ្នាំ................ព.ស ២៥៦៥
ព្រែកតាទែន ថ្ងៃទី.........ខែ...............ឆ្នាំ២០២២

| | | |
|---|---|---|
| បានឃើញ និង ឯកភាព<br>នាយករង<br>អេង ម៉េងតេក | បានពិនិត្យត្រឹមត្រូវ<br>ប្រធានក្រុមបច្ចេកទេស<br>អ៊ុំ សុធារី | គ្រូមុខវិជ្ជា<br>ឃឹម ប្រុស |

## ៣. ដំណើរការរៀន និង បង្រៀនបែបថ្មី ឆ្នាំ២០២២

ផ្តោតលើសន្លឹកកិច្ចការៈ កម្រិតដំបូង០ និងកម្រិតទី១.២.៣.៤.និង ៥

១.សិស្សស្វ័យសិក្សា ប្រើសន្លឹកកិច្ចការ មុនពេលជួបគ្រូ (៣០%)

២.សិស្សស្វ័យសិក្សា ប្រើសន្លឹកកិច្ចការនិងស្រាវជ្រាវតាម វីដេអូឃ្លីប និង ឆាតសួរ គ្រូ មុនពេលជួបគ្រូក្នុងថ្នាក់ (៤០% )

៣.សិស្សជួបគ្រូផ្ទាល់ពិភាក្សា ពីលទ្ធផលស្វ័យសិក្សាសន្លឹកកិច្ចការ (៣០%)

## ការសិក្សាសន្លឹកកិច្ចការ កម្រិត០

លទ្ធផលរំពឹងទុក៖

សិស្សសម្គាល់៖ ពីរបៀបរៀបចំ និងចំណុចសំខាន់របស់មេរៀនក្នុងសៀវភៅសិក្សាគោល

**សិស្សស្វ័យសិក្សា** (*មុនពេលជួបគ្រូ*)

- របៀបបុរាណ៖ *គ្មាន*
- របៀបសម័យ៖ *សិស្សស្វ័យសិក្សាសន្លឹកកិច្ចការកម្រិត០ តាមកម្មវិធី Google Form*

បន្ទាប់មក

**សិស្សជួបគ្រូផ្ទាល់** (*ក្រោយស្វ័យសិក្សា*)

- របៀបបុរាណ៖ *សិស្សជួបគ្រូផ្ទាល់ នៅថ្នាក់រៀន (តាមកាលវិភាគ)*
- របៀបសម័យ៖ *សិស្សជួបគ្រូផ្ទាល់ តាមអនឡាញ (ប្រើកម្មវិធី Zoom ឬ Google Meet)*

## ការសិក្សាសន្លឹកកិច្ចការ កម្រិត១

លទ្ធផលរំពឹងទុក៖

សិស្សប្រមូល៖ ទិន្នន័យនិងព័ត៌មាន ពីក្នុងសៀវភៅសិក្សាគោល មួយមេរៀន

**សិស្សស្វ័យសិក្សា** (*មុនពេលជួបគ្រូ*)

- របៀបបុរាណ៖ *សិស្សយកសន្លឹកកិច្ចការកម្រិត១ ពីសាលានិងប្រគល់កិច្ចការមកឲ្យគ្រូវិញ (តាមកាលវិភាគសាលាកំណត់)*
- របៀបសម័យ៖ *សិស្សស្វ័យសិក្សាសន្លឹកកិច្ចការកម្រិត១ តាមកម្មវិធី Google Form*

បន្ទាប់មក

**សិស្សជួបគ្រូផ្ទាល់** (*ក្រោយស្វ័យសិក្សា*)

- របៀបបុរាណ៖ *សិស្សជួបគ្រូផ្ទាល់ នៅថ្នាក់រៀន (តាមកាលវិភាគ)*
- របៀបសម័យ៖ *សិស្សជួបគ្រូផ្ទាល់ តាមអនឡាញ (ប្រើកម្មវិធី Zoom ឬ Google Meet)*

## ការសិក្សាសន្លឹកកិច្ចការ កម្រិត២ (កំពុងអនុវត្ត)

**លទ្ធផលរំពឹងទុក៖**

សិស្សយល់៖ បញ្ញត្តិមេរៀនរួមមានៈ និយមន័យ រូបមន្ត ក្បួន និង គំនិតសំខាន់ មួយមេរៀន

សិស្ស<u>ស្វ័យសិក្សា</u> (*មុនពេលជួបគ្រូ*)

- របៀបបុរាណ៖ *សិស្ស<u>យក</u>សន្លឹកកិច្ចការកម្រិត២ ពីសាលានិង<u>ប្រគល់</u>កិច្ចការមកគ្រូវិញ (តាមកាលវិភាគសាលាកំណត់)*
- របៀបសម័យ៖ *សិស្សស្វ័យសិក្សាសន្លឹកកិច្ចការកម្រិត២ <u>តាមកម្មវិធី</u> Google Form*

បន្ទាប់មក

សិស្ស<u>ជួបគ្រូផ្ទាល់</u> (*ក្រោយស្វ័យសិក្សា*)

- របៀបបុរាណ៖ *សិស្សជួបគ្រូផ្ទាល់ <u>នៅថ្នាក់រៀន</u> (តាមកាលវិភាគ)*
- របៀបសម័យ៖ *សិស្សជួបគ្រូផ្ទាល់ <u>តាមអនឡាញ</u> (ប្រើកម្មវិធី Zoom ឬ Google Meet)*

## ការសិក្សាសន្លឹកកិច្ចការ កម្រិត៣ (រង់ចាំសិន)

**លទ្ធផលរំពឹងទុក៖**

សិស្សហ្វឹកហាត់៖ ដោយឆ្លើយ/សួរសំណួរ ធ្វើ/បង្កើតលំហាត់ និងដោះស្រាយ/បង្កើតចំណោទ មួយមេរៀន

សិស្ស<u>ស្វ័យសិក្សា</u> (*មុនពេលជួបគ្រូ*)

- របៀបបុរាណ៖ *សិស្ស<u>យក</u>សន្លឹកកិច្ចការកម្រិត៣ ពីសាលានិង<u>ប្រគល់</u>កិច្ចការមកគ្រូវិញ (តាមកាលវិភាគសាលាកំណត់)*
- របៀបសម័យ៖ *សិស្សស្វ័យសិក្សាសន្លឹកកិច្ចការកម្រិត៣ <u>តាមកម្មវិធី</u> Google Form*

បន្ទាប់មក

សិស្ស<u>ជួបគ្រូផ្ទាល់</u> (*ក្រោយស្វ័យសិក្សា*)

- របៀបបុរាណ៖ *សិស្សជួបគ្រូផ្ទាល់ <u>នៅថ្នាក់រៀន</u> (តាមកាលវិភាគ)*
- របៀបសម័យ៖ *សិស្សជួបគ្រូផ្ទាល់ <u>តាមអនឡាញ</u> (ប្រើកម្មវិធី Zoom ឬ Google Meet)*

**ការសិក្សាសន្លឹកកិច្ចការ កម្រិត៤ (វង់ចាំសិន)**

លទ្ធផលរំពឹងទុក៖
សិស្សស្វ័យវាយតម្លៃ៖ លទ្ធផលសិក្សាមួយមេរៀន ដែលសិស្សបានរៀនកន្លង

សិស្ស<u>ស្វ័យសិក្សា</u> (*មុនពេលជួបគ្រូ*)

- របៀបបុរាណ៖ *សិស្ស<u>យក</u>សន្លឹកកិច្ចការកម្រិត៣ ពីសាលានិង<u>ប្រគល់</u>កិច្ចការមកគ្រូវិញ (តាមកាលវិភាគសាលាកំណត់)*
- របៀបសម័យ៖ *សិស្សស្វ័យសិក្សាសន្លឹកកិច្ចការកម្រិត៣ <u>តាមកម្មវិធី</u> Google Form*

បន្ទាប់មក

សិស្ស<u>ជួបគ្រូផ្ទាល់</u> (*ក្រោយស្វ័យសិក្សា*)

- របៀបបុរាណ៖ *សិស្សជួបគ្រូផ្ទាល់ <u>នៅថ្នាក់រៀន</u> (តាមកាលវិភាគ)*
- របៀបសម័យ៖ *សិស្សជួបគ្រូផ្ទាល់ <u>តាមអនឡាញ</u> (ប្រើកម្មវិធី Zoom ឬ Google Meet)*

---

**ការសិក្សាសន្លឹកកិច្ចការ កម្រិត០**
លទ្ធផលរំពឹងទុក៖
សិស្សសម្គាល់៖ ពីរបៀបរៀបចំ និងចំណុចសំខាន់របស់មេរៀន ក្នុងសៀវភៅសិក្សាគោល

**ការសិក្សាសន្លឹកកិច្ចការ កម្រិត១**
លទ្ធផលរំពឹងទុក៖
សិស្សប្រមូល៖ ទិន្នន័យនិងព័ត៌មាន ពីក្នុងសៀវភៅសិក្សាគោល មួយមេរៀន

**ការសិក្សាសន្លឹកកិច្ចការ កម្រិត២**
លទ្ធផលរំពឹងទុក៖
សិស្សយល់៖ បញ្ញត្តិមេរៀនរួមមាន: និយមន័យ រូបមន្ត ក្បួន និងគំនិតសំខាន់ មួយមេរៀន

**ការសិក្សាសន្លឹកកិច្ចការ កម្រិត៣**
លទ្ធផលរំពឹងទុក៖
សិស្សហ្វឹកហាត់៖ ដោយឆ្លើយ/សួរសំណួរ ធ្វើ/បង្កើតលំហាត់ និងដោះស្រាយ/បង្កើត ចំណោទមួយមេរៀន

**ការសិក្សាសន្លឹកកិច្ចការ កម្រិត៤**
លទ្ធផលរំពឹងទុក៖
សិស្សស្វ័យវាយតម្លៃ៖ លទ្ធផលសិក្សា មួយមេរៀន ដែលសិស្សបានរៀនកន្លងមក



ជំពូកទី១

ពិភពលោក

| សំណួរ<br>គ្រូបង្រៀនដាក់ឱ្យសិស្សស្វ័យសិក្សា ដោយប្រើសៀវភៅសិក្សាគោល | ចម្លើយ<br>សិស្សឆ្លើយបានដោយសារការស្វ័យសិក្សា ផ្អែកលើសៀវភៅសិក្សាគោល |
|---|---|
| មេរៀនទី១ មូលដ្ឋានប្រវត្តិវិទ្យា | |
| ខ្លឹមសារទី១ | ប្រវត្តិវិទ្យាជាអ្វី? |
| ១. ប្រវត្តិវិទ្យាជាអ្វី? | |
| ២. ដើម្បីចងក្រងប្រវត្តិវិទ្យាបាន តើគេពឹងផ្អែកលើឯកសារអ្វីខ្លះ? | |
| ៣. តើប្រវត្តិវិទ្យាមានសារៈសំខាន់ដូចម្តេចខ្លះ? | |



| ខ្លឹមសារទី២ | ផ្លូវសំខាន់ៗនិងនយោបាយពាណិជ្ជ |
|---|---|
| ១. ចូរប្អូនរៀបរាប់អំពីផ្លូវសំខាន់ៗនៅតំបន់មេសូប៉ូតាមី។ | |
| ២.តើជនជាតិស៊ុយមែបានរកឃើញអ្វីខ្លះ? | |
| ៣. ចូរនិយាយអំពីជីវភាពរស់នៅរបស់ប្រជាជននៅផ្លូវកាល់ដេ ឬអាកាត។ | |
| ៤. តើព្រះរាជាអង្គណាដែលល្បីជាងគេនៅផ្លូវកាល់ដេ ឬអាកាត? ព្រោះអ្វី? | |
| ៥.តើជនជាតិអាស៊ីរីមានលក្ខណៈដូចម្តេច? | |
| ខ្លឹមសារទី៣ | អរិយធម៌មេសូប៉ូតាមី |
| ១. តើអរិយធម៌មេសូប៉ូតាមីមានលក្ខណៈដូចម្តេច? | |




**កម្មវិធីបង្រៀនពីចម្ងាយប្រចាំសប្ដាហ៍តាមខែ** មុខវិជ្ជា ប្រវត្តិវិទ្យា ថ្នាក់ទី៧

| ខ្លឹមសាររៀននិងបង្រៀន | កមរា | | | | កុម្ភៈ | | | | មីនា | | | | មេសា | | | | ឧសភា | | | | មិថុនា | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ |
| ជំពូកទី១ ពិភពលោក | | | | | | | | | | | | | | | | | | | | | | | | |
| មេរៀនទី១ មូលដ្ឋាននៃប្រវត្តិវិទ្យា | | | | | | | | | | | | | | | | | | | | | | | | |
| ១. ប្រវត្តិវិទ្យាជាអ្វី (ចូរប្រាប់និយមន័យប្រវត្តិវិទ្យា។) | | ✓ | | | | | | | | | | | | | | | | | | | | | | |
| ២. ឯកសារប្រវត្តិវិទ្យា (តើឯកសារប្រវត្តិវិទ្យាមានប៉ុន្មានផ្នែកសំខាន់ៗ គឺអ្វីខ្លះ?) | | ✓ | | | | | | | | | | | | | | | | | | | | | | |
| ៣. សារៈសំខាន់នៃប្រវត្តិវិទ្យា (តើប្រវត្តិវិទ្យាផ្តល់សារៈសំខាន់អ្វីខ្លះ?) | | ✓ | | | | | | | | | | | | | | | | | | | | | | |
| ៤. កាលវិទ្យា (ចូរប្រាប់និយមន័យកាលវិទ្យា។) | | ✓ | | | | | | | | | | | | | | | | | | | | | | |
| ៥. របៀបចែកកាល (តើគេចែកកាលជាជាអ្វីខ្លះ?) | | ✓ | | | | | | | | | | | | | | | | | | | | | | |
| ៦. បុរេប្រវត្តិសាស្ត្រ (តើគេចែកបុរេប្រវត្តិសាស្ត្រជាប៉ុន្មានយុគសម័យ? គឺអ្វីខ្លះ?) | | | ✓ | | | | | | | | | | | | | | | | | | | | | |
| ៧. ជីវភាពប្រជាជន (ចូររៀបរាប់ពីចំណុចសំខាន់ៗអំពីជីវភាពសង្គម នៅបុរេប្រវត្តិសាស្ត្រ) | | | ✓ | | | | | | | | | | | | | | | | | | | | | |
| ៨. ប្រវត្តិសាស្ត្រអេស៊ីប (ចូរប្រាប់ពីការធ្លាក់ចុះអេស៊ីបបុរាណ។) | | | ✓ | | | | | | | | | | | | | | | | | | | | | |

| | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| មេរៀនទី២ ប្រទេសអេស៊ីបបុរាណ | | | | | | | | | | | | | | | | | | | | | | | | |
| ១. ស្ថានភាពភូមិសាស្ត្រ (ចូរបង្ហាញពីទីតាំងភូមិសាស្ត្រប្រទេសអេស៊ីបបុរាណ?) | | | | | ✓ | | ✓ | ✓ | | | | | | | | | | | | | | | | |
| ២. ប្រវត្តិសាស្ត្រអេស៊ីប (ចូរបង្ហាញពីចំណុចសំខាន់ៗនៃការស្រាវជ្រាវប្រវត្តិសាស្ត្រអេស៊ីប។) | | | | | ✓ | | ✓ | ✓ | | | | | | | | | | | | | | | | |
| ៣. ប្រវត្តិសាស្ត្រអេស៊ីប (ចូររៀបរាប់ពីដំណើរប្រវត្តិសាស្ត្រអេស៊ីបសំខាន់ៗ។) | | | | | ✓ | | ✓ | ✓ | | | | | | | | | | | | | | | | |
| ៤. ប្រវត្តិសាស្ត្រអេស៊ីប (ចូរប្រាប់ពីការធ្លាក់ចុះអេស៊ីបបុរាណ។) | | | | | | ✓ | ✓ | ✓ | | | | | | | | | | | | | | | | |
| ៥. វណ្ណៈសង្គម (ចូរប្រាប់ពីវណ្ណៈសង្គមអេស៊ីបបុរាណ។) | | | | | | ✓ | ✓ | ✓ | | | | | | | | | | | | | | | | |
| ៦. សាសនាអេស៊ីបបុរាណ (ចូរប្រាប់ពីភ័ស្តុតាង ជំនឿសាសនាជនជានអេស៊ីបបុរាណ។) | | | | | | ✓ | ✓ | ✓ | | | | | | | | | | | | | | | | |
| មេរៀនទី៣ រដ្ឋនៅតំបន់មេសូប៉ូតាមី | | | | | | | | | | | | | | | | | | | | | | | | |
| ១. ទីតាំងភូមិសាស្ត្រនិងកុលសម្ព័ន្ធ (ចូរប្រាប់ពីទីតាំងភូមិសាស្ត្រ និងអាកាសធាតុតំបន់មេសូប៉ូតាមី។) | | | | | | | | | ✓ | | | | | | | | | | | | | | | |
| ២. ទីតាំងភូមិសាស្ត្រនិងកុលសម្ព័ន្ធ (ចូរប្រាប់ពី កុលសម្ព័ន្ធរស់នៅតំបន់មេសូប៉ូតាមី។) | | | | | | | | | ✓ | | | | | | | | | | | | | | | |
| ៣. រដ្ឋសំខាន់ៗនិងនយោបាយវាតទី (ចូរប្រាប់ឈ្មោះរដ្ឋសំខាន់ៗនៅតំបន់មេសូប៉ូតាមី។) | | | | | | | | | ✓ | | | | | | | | | | | | | | | |
| ៤. អរិយធម៌មេសូប៉ូតាមី (ចូរប្រាប់ពីគំនិតសំខាន់ៗ អំពីនយោបាយ សង្គម វប្បធម៌និងច្បាប់ សាសនានិងជំនឿ។) | | | | | | | | | ✓ | | | | | | | | | | | | | | | |

| | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| មេរៀនទី៤ ជនជាតិដើមអ៊ីស្រាអែល | | | | | | | | | | | | | | | | | | | | | | | | |
| ១. ប្រវត្តិទឹកដីនិងជនជាតិហេប្រឺ (ចូររៀបរាប់លំដាប់លំដោយសង្ខេប ប្រវត្តិទឹកដីនឹងជនជាតិហេប្រឺ។) | | | | | | | | | | ✓ | | ✓ | | | | | | | | | | | | |
| ២. សម័យកាលសំខាន់ៗ (ចូរប្រាប់ពីព្រឹត្តិការណ៍សំខាន់ៗក្នុងសម័យកាលរុងរឿងរបស់កុលសម្ព័ន្ធហេប្រឺ។) | | | | | | | | | | ✓ | | ✓ | | | | | | | | | | | | |
| ៣. សម័យកាលសំខាន់ៗ (ចូរប្រាប់ពីព្រឹត្តិការណ៍សំខាន់ៗក្នុងសម័យកាលចុះខ្សោយ របស់កុលសម្ព័ន្ធហេប្រឺ។) | | | | | | | | | | | ✓ | ✓ | | | | | | | | | | | | |
| ៤. អរិយធម៌ហេប្រឺ (ចូររៀបរាប់ពីចំណុចសំខាន់ៗអំពីអរិយធម៌ហេប្រឺ។) | | | | | | | | | | | ✓ | ✓ | | | | | | | | | | | | |
| មេរៀនទី៥ រដ្ឋផេនីស៊ី | | | | | | | | | | | | | | | | | | | | | | | | |
| ១. ទីតាំងភូមិសាស្ត្ររបស់រដ្ឋផេនីស៊ី (ចូរប្រាប់ពីទីតាំងភូមិសាស្ត្រ របស់រដ្ឋផេនីស៊ី។) | | | | | | | | | | | | | | | ✓ | ✓ | | | | | | | | |
| ២. ជីវភាពនយោបាយ (ចូររៀបចំចំណុចសំខាន់ៗ អំពីជីវភាពនយោបាយ របស់រដ្ឋផេនីស៊ី។) | | | | | | | | | | | | | | | ✓ | ✓ | | | | | | | | |
| ៣. អរិយធម៌ប្រទេសផេនេស៊ី (តើអរិយធម៌ប្រទេសផេនីស៊ីចែកជាប៉ុន្មានផ្នែក? គឺអ្វីខ្លះ?) | | | | | | | | | | | | | | | ✓ | ✓ | | | | | | | | |

| | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| មេរៀនទី៦ប្រទេសក្រិចបុរាណ | | | | | | | | | | | | | | | | | | | | | | | | |
| ១. ស្ថានភាពភូមិសាស្ត្រនិងប្រជាជន(ចូរប្រាប់ពីទីតាំងភូមិសាស្ត្ររបស់ប្រទេសក្រិកបុរាណ។) | | | | | | | | | | | | | | | | | ✓ | ✓ | | | | | | |
| ២. បុរីប្ញរដ្ឋនានាក្នុងប្រទេសក្រិក(ចូររៀបរាប់ពីឈ្មោះបុរីរដ្ឋនៅក្នុងប្រទេសក្រិក។) | | | | | | | | | | | | | | | | | ✓ | ✓ | | | | | | |
| ៣. អរិយធម៌ក្រិក(ចូររៀបរាប់ពីអរិយធម៌ក្រិក។) | | | | | | | | | | | | | | | | | ✓ | ✓ | | | | | | |
| មេរៀនទី៧ ចក្រភពរ៉ូម | | | | | | | | | | | | | | | | | | | | | | | | |
| ១. ស្ថានភាពភូមិសាស្ត្រអ៊ីតាលីបុរាណ(ចូរប្រាប់ពីទីតាំងភូមិសាស្ត្ររបស់ចក្រភពរ៉ូម។) | | | | | | | | | | | | | | | | | | | ✓ | | | | | |
| ២. ព្រឹត្តិការណ៍នយោបាយ | | | | | | | | | | | | | | | | | | | ✓ | | | | | |
| ៣. អរិយធម៌រ៉ូម | | | | | | | | | | | | | | | | | | | ✓ | | | | | |
| មេរៀនទី៨ អរិយធម៌អាមេរិកបុរាណ | | | | | | | | | | | | | | | | | | | | | | | | |
| ១. ចក្រភពម៉ាយ៉ា | | | | | | | | | | | | | | | | | | | | ✓ | | | | |
| ២. ចក្រភពអាស្តែក | | | | | | | | | | | | | | | | | | | | ✓ | | | | |
| ៣. ចក្រភពអាំងកា | | | | | | | | | | | | | | | | | | | | ✓ | | | | |

| ជំពូកទី២ ប្រវត្តិសាស្ត្រកម្ពុជា | កក្កដា | | | | សីហា | | | | កញ្ញា | | | | តុលា | | | | វិច្ឆិកា | | | | ធ្នូ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | 1 | 2 | 3 | 4 | 1 | 2 | 3 | 4 | 1 | 2 | 3 | 4 | 1 | 2 | 3 | 4 | 1 | 2 | 3 | 4 | 1 | 2 | 3 | 4 |
| មេរៀនទី១ បុរេប្រវត្តិវិទ្យា | | | | | | | | | | | | | | | | | | | | | | | | |
| ១. ដើមកំណើតដីខ្មែរ | ✓ | | ✓ | | | | | | | | | | | | | | | | | | | | | |
| ២. ដើមកំណើតនៃជនជាតិខ្មែរ | ✓ | | ✓ | | | | | | | | | | | | | | | | | | | | | |
| ៣. ផែនទីស្ថានីយបុរេប្រវត្តិសាស្ត្រកម្ពុជា | ✓ | | ✓ | | | | | | | | | | | | | | | | | | | | | |
| ៤. យុគសម័យនិងស្ថានីយបុរេប្រវត្តិសាស្ត្រខ្មែរ | | ✓ | ✓ | | | | | | | | | | | | | | | | | | | | | |
| ៥. អរិយធម៌ខ្មែរសម័យបុរេប្រវត្តិសាស្ត្រ | | ✓ | ✓ | | | | | | | | | | | | | | | | | | | | | |
| មេរៀនទី២ អាណាចក្រភ្នំ (៥០-៥៥០ឆ្នាំនៃគ.ស) | | | | | | | | | | | | | | | | | | | | | | | | |
| ១. ទីតាំងភូមិសាស្ត្រនិងកំណរកំណើតនគរភ្នំ | | | | | ✓ | | ✓ | | | | | | | | | | | | | | | | | |
| ២. មូលហេតុឥណ្ឌានៅនគរភ្នំ | | | | | ✓ | | ✓ | | | | | | | | | | | | | | | | | |
| ៣. ព្រះរាជាល្បីៗសម័យអាណាចក្រភ្នំ | | | | | ✓ | | ✓ | | | | | | | | | | | | | | | | | |
| ៤. ការដួលរលំនៃអាណាចក្រភ្នំ | | | | | | ✓ | ✓ | | | | | | | | | | | | | | | | | |
| ៥. អរិយធម៌នគរភ្នំ | | | | | | ✓ | ✓ | | | | | | | | | | | | | | | | | |
| មេរៀនទី៣ អាណាចក្រចេនឡា (៥៥០-៨០២ឆ្នាំនៃគ.ស) | | | | | | | | | | | | | | | | | | | | | | | | |
| ១. ទីតាំងភូមិសាស្ត្រ | | | | | | | | | ✓ | ✓ | | | | | | | | | | | | | | |
| ២. ព្រះរាជាណាចក្រល្បីៗនៅអាណាចក្រចេនឡា | | | | | | | | | ✓ | ✓ | | | | | | | | | | | | | | |
| ៣. ការបែងចែកអាណាចក្រចេនឡា | | | | | | | | | ✓ | ✓ | | | | | | | | | | | | | | |
| ៤. ចេនឡាដីគោករដ្ឋឯករាជ្យ | | | | | | | | | ✓ | ✓ | | | | | | | | | | | | | | |
| ៥. ចេនឡាទឹកលិចក្រោមអំណាចជ្វា | | | | | | | | | ✓ | ✓ | | | | | | | | | | | | | | |
| ៦. អរិយធម៌ចេនឡា | | | | | | | | | ✓ | ✓ | | | | | | | | | | | | | | |

